ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# **កំណត់ហេតុជាលាយលក្ខណ៍អក្សរ**
# **នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"**
## **សាធារណៈ**

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩**

**សវនាការលើកទី៧៦**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CATWRIGHT)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក លឹម ស៊ុយហុង

កញ្ញា ណាតាសា វិស៊ែល រីសឺ

*(Ms. Natacha WEXELS-RISER)*

លោក ម៉ាតេអូ គ្រីស្ពារ *(Mr. Matteo Crippa)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក វីលៀម ស្មីត *(Mr.William SMITH)*

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រ៉ូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

លោក ចាន់ រ៉ាវុធ

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

កញ្ញា ទី ស្រ៊ុនណា

លោក គង់ ពិសី

កញ្ញា ម៉ុច សុវណ្ណារី

លោក ហុង គីមសួន

លោក ការីម ខាន *(Mr. Karim KHAN)*

លោកស្រី ស៊ីលឃិ ស្ទូតហ្ស៊ីនស្គី

*(Ms. Silke STUDZINSKY)*

លោកស្រី ម៉ាទីន ហ្សាកកាំង

*(Ms. Martine JACQUIN)*

លោក ហ្វីលីព កាណុន

*(Mr. Philippe CANNONE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក ហ្វីលីព កាណុន | បារាំង |
| លោក ហុង គឹមសួន | ខ្មែរ |
| លោកស្រី ម៉ាទីន ហ្សាកកាំង | បារាំង |
| លោក ការីម ខាន | អង់គ្លេស |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោកស្រី ស៊ីលយិ ស្ទួតហ្សីនស្គី | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលមកកាន់បន្ទប់សវនាការ)*

[០៩:០០:១២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគីដែលត្រូវបានអញ្ជើញចូលរួមនៅក្នុងដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន, ភាគីដែលត្រូវចូលរួមនៅក្នុងដំណើរការនីតិវិធីសវនាការនៅក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួន។

**ប្រធានអង្គជំនុំ៖**

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទៅកាន់ឈើរាំងរង់ក្រចកសេះ ដែលរៀបចំទុកសម្រាប់ជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះ។

*(ជនជាប់ចោទដើរមកកាន់ឈើរាំងរង់ក្រចកសេះ)*

ជាកិច្ចបន្ត សូមអញ្ជើញមេធាវីការពារក្ដីអន្តរជាតិឡើងធ្វើសេចក្ដីថ្លែង សេចក្ដីសន្និដ្ឋានបិទកិច្ចពិភាក្សាដេញដោល-- បញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។

សូមអញ្ជើញ!

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន, អរុណសួស្ដី អស់លោក លោកស្រីចៅក្រម និងអង្គសវនាការជាទីគោរព ។ មុនពេលខ្ញុំចាប់ផ្ដើមនូវការថ្លែងរបស់ខ្ញុំ ខ្ញុំចង់ជម្រាបអង្គសវនាការថា នៅក្នុងពេលដែលខ្ញុំផ្ដល់សេចក្ដីសន្និដ្ឋាន ខ្ញុំចង់ចាក់នូវខ្សែរូបភាពយន្តដែល លោក លោកស្រីចៅក្រម ទទួលបានរួចហើយ ដូច្នេះខ្ញុំសូមការអនុញ្ញាតពី លោក លោកស្រីចៅក្រម ក្នុងការចាក់វីដេអូនេះ នៅពេលនេះតែម្ដង។

**ប្រធានអង្គជំនុំ៖**

ជំនុំជម្រះអនុញ្ញាតតាមការស្នើសុំនេះ។ ហើយមន្ត្រីផ្នែកខាងសោតទស្សន៍រៀបចំចាត់ចែងតាមការស្នើសុំរបស់មេធាវីការពារក្ដីក្នុងការបញ្ចាំងនូវខ្សែវីដេអូលើកញ្ចក់អេក្រង់ទូរទស្សន៍ នាដំណើរការ

សវនាការនាពេលនេះ។

[០៩:០៣:៤០]

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជម្រាបខាងផ្នែកបច្ចេកទេសសោតទស្សន៍ទៅតាមហ្នឹង ហើយខ្ញុំ នឹងជម្រាបថា នៅដំណាក់កាលណា ដែលខ្ញុំចង់ចាក់ផ្សាយទៅលើខ្សែរូបភាពវីដេអូនេះ ។

លោក លោកស្រីចៅក្រម ជាទីគោរព, ជាបឋម ខ្ញុំសូមអភ័យទោសចំពោះអ្នកបកប្រែ ដោយសារតែវាទាក់ទងទៅនឹងបញ្ហាច្បាប់នៅទីនេះ។ ហើយយើងខ្ញុំបានធ្វើការរៀបចំនឹងពិនិត្យទៅលើចំណុចល្អិតល្អន់ បន្ទាប់ពីលោក ការ សាវុត្ថ បានធ្វើសេចក្ដីថ្លែង។ ដូច្នេះនៅទីនេះ ខ្ញុំមានការសរសេរកត់ត្រានូវចំណុចមួយចំនួន ដែលខ្ញុំបានបញ្ជូនទៅជូនមន្ត្រីបកប្រែរួចហើយ ដូច្នេះនឹងព្យាយាមនិយាយឲ្យបានយឺតតាម ដែលអាចធ្វើទៅបាន ។

លោក លោកស្រីចៅក្រម លោកប្រធានជាទីគោរព, ប្រសិនបើខ្ញុំលើកសេចក្ដីថ្លែងរបស់ខ្ញុំហួសពីរយៈពេលកំណត់នោះ ខ្ញុំសូមឲ្យលោកប្រធានអនុគ្រោះដល់ខ្ញុំចំពោះករណីនេះ។

ចំពោះសេចក្ដីថ្លែងរបស់ខ្ញុំ និងការដាក់ជូននូវសន្និដ្ឋានរបស់ខ្ញុំ។ ជាបឋមខ្ញុំសូមសំដៅនូវសេចក្ដីថ្លែងអំណរគុណទៅដល់ភាគីទាំងអស់ដែលបានធ្វើការងារយ៉ាងសស្រាក់សស្រាំជាមួយនឹងយើងខ្ញុំ អស់រយៈពេលជាច្រើនខែរួចមកហើយ។ ដើម្បីអាចឲ្យយើងរៀបចំការបើកនូវសវនាការនេះបាន ហើយសេចក្ដីសន្និដ្ឋានរបស់ខ្ញុំដែលខ្ញុំដាក់ជូននាពេលនេះចំពោះមុខអង្គសវនាការ វាក៏មានការជួយជ្រោមជ្រែងពីកម្មសិក្សាការី និងអ្នកច្បាប់ទាំងឡាយនៅក្នុងក្រុមរបស់ខ្ញុំ ដែលបានចូលរួមនៅក្នុងការរៀបចំនូវសេចក្ដីព្រាងនៃសេចក្ដីសន្និដ្ឋាននេះ ដែលខ្ញុំនឹងដាក់ជូនអង្គសវនាការនាពេលនេះ។ ហើយខ្ញុំសូមសម្ដែងការថ្លែងអំណរគុណយ៉ាងច្រើនទៅដល់ក្រុមការងារដែលបានផ្ដល់ជំនួយមកដល់ខ្ញុំនេះ។

ខ្ញុំក៏ចង់បង្ហាញជូនដល់អង្គសវនាការ សូមអភ័យទោសផងដែរ លោកស្រី កានីហ្សារេស ដោយសារតែគាត់មានបញ្ហាសុខភាព លោកស្រីមិនអាចមកចូលរួមនៅក្នុងថ្ងៃនេះបានឡើយ។ ខ្ញុំសូមអភ័យទោសទៅលើបញ្ហានេះហើយខ្ញុំសង្ឃឹមថា លោកស្រីនឹងជាសះស្បើយពីបញ្ហាសុខភាពរបស់លោកស្រីនាពេលឆាប់ៗនេះ។

លោក លោកស្រីចៅក្រម អង្គសវនាការជាទីគោរព, ខ្ញុំសូមលើកឡើងនូវចំណុចមួយចំនួន។ នេះ គឺជាសេចក្ដីសន្និដ្ឋានរបស់ខ្ញុំចុងក្រោយក្នុងនាមជាមេធាវីក្នុង។ រយៈពេលដែលខ្ញុំធ្វើការងារសាម

សិបជាងឆ្នាំ ខ្ញុំបានធ្វើការស្បថ ហើយខ្ញុំបានបំពាក់សម្លៀកបំពាក់របស់ខ្ញុំក្នុងនាមមេធាវី។ ហើយនៅដំណាក់កាលនេះ គឺវាជាដំណាក់មួយសំខាន់សម្រាប់វិជ្ជាជីវនិងរបស់មនុស្សម្នាក់។ ហើយលោក លោកស្រីដឹងហើយ ខ្ញុំនឹងទៅបំពេញការងារនូវតុលាការលីបង់ ដែលអគ្គលេខាធិការអង្គការសហប្រជាជាតិបានស្នើសុំឱ្យខ្ញុំបំពេញការងារជាប្រធានអង្គភាពការពារក្តីនៅទីនោះ។ ដូច្នេះ ចំណុចនេះមានន័យថា ខ្ញុំនឹងបន្តវិជ្ជាជីវរបស់ខ្ញុំបន្តទៀត នៅក្នុងតុលាការយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ។

ដូច្នេះ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន លោក លោកស្រីចៅក្រម ដោយសារតែស្ថានភាពពិសេសនេះ និងស្ថានភាពផ្តល់ខ្លួនរបស់ខ្ញុំទៅលើការងារទាំងអស់នេះ។ នៅក្នុងពេលដែលខ្ញុំធ្វើសេចក្តីថ្លែងបញ្ចប់ ខ្ញុំសូមធ្វើការឧទ្ទិសទៅដល់ការងារទាំងអស់នេះ ជូនកូនចៅរបស់ខ្ញុំ ហើយខ្ញុំក៏ឧទ្ទិសការងារ ដែលខ្ញុំបានបំពេញទាំងអស់នេះជូនអ្នកជំនាន់ក្រោយក្មេងៗទាំងអស់ទៀត ដើម្បីឱ្យគាត់សិក្សាទៅលើបទពិសោធទាំងអស់នេះ។ ជាពិសេស ចំពោះស្ត្រីជាមេធាវី ស្ត្រីទាំងឡាយដែលគាត់បំពេញការងារនៅទីនេះផងដែរ។ ហើយខ្ញុំដឹងថា ក្រុមមេធាវីរបស់លោកស្រីពិតជាមានមោទនភាពចំពោះការងាររបស់ លោកស្រីណាស់ ហើយខ្ញុំដឹងថា ពួកគេយល់ទៅលើតម្លៃទាំងអស់នេះ។ ហើយវាជាការបញ្ជាក់នូវវិជ្ជាជីវរបស់លោក លោកស្រី ដែលបានបំពេញការងារនៅទីនេះ។

នៅពេលដែលយើងខ្ញុំមកបំពេញការងារជាមេធាវីការពារក្តី ការងារនេះ គឺជាការងារមួយដែលវាសំខាន់ និងធ្ងន់សន្ធាប់ផងដែរ។ នៅពេលដែលខ្ញុំក្រោកឈរការពារក្តីទៅលើបុគ្គលម្នាក់ ដែលរងនូវការដាក់បន្ទុកទៅលើអង្គហេតុជាច្រើន ហើយនៅពេលដែលខ្ញុំឈរនៅទីនេះ នៅជិតជនជាប់ចោទ ដោយសារតែមានការចោទប្រកាន់ថា គាត់បានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលយើងអាចស្រមើស្រមៃថាដូច្នោះ គឺ “ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ”។

[០៩:១០:២២]

យើងសូមស្រមើស្រមៃថា គាត់ប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ នៅពេលដែលខ្ញុំឮចំណុចទាំងអស់នេះរបស់លោកស្រី អានទ្រូស្ស ក្នុងសម្តីជាសហព្រះរាជអាជ្ញា គឺនៅពេលដែលខ្ញុំឮនោះ គឺថាវាហាក់ដូចជាមិនមានការលើកឡើងអំពីមនុស្សធម៌ចំពោះជនជាប់ចោទ ដែលជនជាប់ចោទបានផ្តល់ជូននូវការរៀបរាប់អំពីអង្គហេតុ និងបញ្ជាក់ជូនអំពីបទចោទដែលដាក់បន្ទុកទៅលើគាត់ ជូនខាងព្រះរាជអាជ្ញា។ ហើយដោយសារតែមានការចោទប្រកាន់ទាំងអស់នេះហើយ ទើបខ្ញុំមកធ្វើការការពារក្តីនៅទីនេះផងដែរ។ ប៉ុន្តែទោះបីជាកាតព្វកិច្ច និងការងារទាំងអស់នេះ ហើយទោះបីជាអ្វីដែលខ្ញុំធ្វើនេះក្នុងនាម

ជាការការពារទៅដល់មនុស្សធម៌ក៏ដោយ គឺយើងដឹងថាបុគ្គលនៅទីនេះ គឺជាបុគ្គលមួយរូបដែលគាត់ត្រូវបានលើកឡើងដោយជនរងគ្រោះថា បានប្រព្រឹត្តអំពើចំពោះអ្នកទាំងអស់នេះ។

ដូច្នេះ ការគោរពនិងសេចក្តីមេត្តារបស់ខ្ញុំក្នុងនាមជាមនុស្សធម៌ ក្នុងលក្ខណៈមនុស្សធម៌ គឺបានជំរុញឲ្យខ្ញុំធ្វើនូវសេចក្តីថ្លែងសន្និដ្ឋានបញ្ចប់នាពេលនេះ។ ខ្ញុំមានការរីករាយនៅពេលដែលខ្ញុំស្តាប់ឮនូវសេចក្តីសន្និដ្ឋានគ្រប់ភាគីទាំងអស់ ដែលបានលើកឡើងថា សវនាការដែលកាត់ក្តីទៅលើកូនក្តីរបស់ខ្ញុំ គឺជាផ្លូវមួយឈានទៅដល់ការស្វែងរកយុត្តិធម៌ ដូច្នេះសូមឲ្យយើងគោរពទៅលើយន្តការនេះ។

បានន័យថា ទឹកភ្នែកមួយដំណក់ គឺវាជាការជាសម្រក់ចំពោះឧក្រិដ្ឋកម្ម និងការឈឺចាប់ទាំងឡាយដែលបានកើតឡើង ទោះបីជាមានការពិភាក្សានិងលើកឡើងទៅលើចំណុចទាំងអស់នេះក៏ដោយ ខ្ញុំមានការថ្លែងអំណរគុណ ដែរថាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីគាត់មកទីនេះ ដើម្បីការពារប្រយោជន៍ដល់ជនរងគ្រោះ ខ្ញុំមានការថ្លែងអំណរគុណ។ ខ្ញុំដឹងថា មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលលោកលោកស្រីបានលើកឡើងហើយថា ដំណាក់កាលនេះ ឬក៏សវនាការនេះ គឺជាដំណាក់កាលចាប់ផ្តើម ហើយយើងមិនដឹងថា តើយើងត្រូវដើរទៅតាមផ្លូវណា? ហើយការដែលយើងដើរទាំងអស់គ្នានេះហើយ យើងបានព្យាយាមធ្វើយ៉ាងណា ថាឲ្យដំណើរការទាក់ទងទៅនឹងសវនាការទាំងអស់នេះ គឺជាសវនាការទីមួយ ក្នុងនាមជាតុលាការអន្តរជាតិ ដែលថាជនរងគ្រោះគាត់មានសិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណី។

ដូច្នេះ យើងគួរតែរីករាយ និងគោរពទៅលើស្នាដៃ និងចំណុចនេះទាំងអស់គ្នា ហើយយើងគួរតែធ្វើការប្រារព្ធ និងគោរពទៅលើចំណុចដែរថា នៅពេលនេះយើងឈានទៅដល់ដំណាក់កាលចុងក្រោយនៃសវនាការរបស់យើងទាំងអស់គ្នាហើយ។ ថាតើមានមនុស្សប៉ុន្មាននាក់ដែលគាត់បានលើកឡើងថា សវនាការនេះមិនអាចកើតឡើងនោះទេ ដោយសារតែមានការលំបាកលំបិន ជាច្រើនទាក់ទងទៅនឹងតុលាការនេះ។ ប៉ុន្តែយ៉ាងណាក៏ដោយ យើងឃើញទាំងអស់គ្នាហើយថា មានតុលាការនេះ នាពេលនេះ ហើយខ្ញុំសូមថ្លែងអំណរគុណចំពោះការចូលរួមរបស់ភាគីទាំងឡាយ ហើយយើងដឹងហើយ យើងបានជួបប្រទះនូវភាពស្មុគស្មាញដែលយើងប្រឈមមុខទាំងអស់ ហើយយើងត្រូវដោះស្រាយ។ ប៉ុន្តែ យ៉ាងណាក៏ដោយ យើងមិនទាន់ឈានដល់ដំណាក់កាលបញ្ចប់នៅឡើយនោះទេ។ ប៉ុន្តែ នៅក្នុងដំណាក់កាលនេះ ចាប់ពីពេលនេះទៅ យើងនឹងបញ្ចប់នូវសវនាការមួយនេះ។

[០៩:១៥:៣៣]

នៅក្នុងថ្ងៃនេះ យើងអាចនិយាយថា សវនាការមួយនេះ គឺវានឹងពង្រឹងក្នុងការចំណារទុកនៅក្នុង

ប្រវត្តិសាស្ត្រនៃតុលាការអន្តរជាតិដែលបានកើតឡើងនៅក្នុងរបប ឬក៏សម័យយើងនេះ។ ហើយទោះបីជាគេបានលើកឡើងថា យុត្តិធម៍គ្រាន់តែជាដំណាក់កាលចាប់ផ្តើមក៏ដោយ ប៉ុន្តែ យើងដឹងថា វាមានឡើងទាំងអស់គ្នានោះហើយ សម្រាប់យើងទាំងអស់គ្នានោះហើយ។ ហើយនៅពេលនេះ គឺយើងកំពុងតែព្យាយាមរកមធ្យោបាយល្អបំផុត ដើម្បីឲ្យយើងដើរទៅមុខទាំងអស់គ្នា។ ហើយដូចដែលយើងបានដឹងហើយថា មធ្យោបាយល្អបំផុត សម្រាប់សវនាការនិងសាលាក្តីនោះ គឺនៅចុងក្រោយយើងត្រូវតែរកឲ្យឃើញនូវភាពយុត្តិធម៌ និងយុត្តិធម៌។

លោក លោកស្រី ចៅក្រម គឺមិនពាក់ព័ន្ធទៅនឹងការធានាឲ្យមានការផ្សះផ្សាជាតិនោះទេ ប៉ុន្តែលោក លោកស្រី ចៅក្រម ត្រូវធានាឲ្យមានការអត់ឱនទោស ឬក៏ការអនុគ្រោះពីជនរងគ្រោះ។ មិនមាននរណាម្នាក់អាចឲ្យធ្វើឲ្យជនរងគ្រោះ គាត់អនុគ្រោះនោះទេ ។ ប៉ុន្តែ លោក លោកស្រីចៅក្រម ត្រូវធានាចំណុចនេះតាមរយៈការស្វែងរកយុត្តិធម៌ចំពោះគេ។ ដូច្នេះ វាបញ្ជាក់យ៉ាងច្បាស់ថា លោក លោកស្រីចៅក្រមនៅទីនេះមិនមែនដើម្បីបំបាត់នូវនិទ្ទណ្ឌភាពនោះទេ ប៉ុន្តែ វាជាកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាដែលត្រូវបំបាត់នូវនិទ្ទណ្ឌភាពនេះ ។

លោក លោកស្រី ចៅក្រម នៅទីនេះដើម្បីស្វែងរកយុត្តិធម៌ សម្រាប់យើងទាំងអស់គ្នា។ បានន័យថា យើងត្រូវបើកឲ្យមានដំណើរការនីតិវិធីតទល់គ្នា ដូចដែលខ្ញុំបានជម្រាបនៅក្នុងពេលដែលខ្ញុំបើកធ្វើសេចក្តីសន្និដ្ឋានបឋម។ បានន័យថា យើងទាំងអស់គ្នាចូលរួមនៅក្នុងសវនាការនេះទាំងអស់គ្នា ដែលវាមានលក្ខខណ្ឌជាច្រើន ហើយវាមានការកើតឡើងចំពោះប្រទេសកម្ពុជា និងប្រជាជនកម្ពុជា។ ហើយយើងត្រូវដឹងទាំងអស់គ្នាថា តើអ្វីទៅជាមន្ទីរស-២១?

[០៩:១៨:១៧]

ប៉ុន្តែយើងត្រូវដឹងថា ធាតុផ្សំមួយដ៏សំខាន់ និងជាធាតុផ្សំមូលដ្ឋាននោះ គឺសំឡេង និងការសម្តែងចេញពីអារម្មណ៍របស់ជនជាប់ចោទ។ ហើយយើងបានលើកឡើងថា ធ្វើយ៉ាងណាឲ្យជនជាប់ចោទមានសិទ្ធិក្នុងការបញ្ចេញនូវយោបល់និងសំឡេងរបស់គាត់ផងដែរ។

នៅពេលដែលយើងស្តាប់ឮសំឡេងរបស់ជនរងគ្រោះ ហើយនៅពេលដែលយើងឮការចោទប្រកាន់និងការថ្លែងរបស់ខាងសហព្រះរាជអាជ្ញា ហើយរួមទាំងសំឡេងរបស់ជនជាប់ចោទផងដែរនោះ គឺយើងទាំងអស់គ្នា លោក លោកស្រីចៅក្រម ត្រូវការស្វែងរកយុត្តិធម៌ចំពោះចំណុចទាំងអស់នេះ។

ចំណុចជាច្រើនបានលើកឡើង និងសរសេរ និងកត់ត្រាទុកអំពីឧក្រិដ្ឋកម្មដែលបានកើតឡើងទាំង

អស់នេះ។ ខ្ញុំសូមលើកឡើងនៅសៀវភៅ *ហ្គាប៉ុង* ដែលគាត់ជាចៅក្រមបារាំងមួយរូប។ សៀវភៅរបស់គាត់ គឺលើកឡើងអំពីឧក្រិដ្ឋកម្មដែលមិនអាចអត់ឱនឲ្យបាន។ គឺឧក្រិដ្ឋកម្មចំណងជើងនៃសៀវភៅនោះ គឺ "ឧក្រិដ្ឋកម្មមិនអាចអត់ឱន និងមិនបានគេចោទប្រកាន់"។ យើងដឹងហើយថា ប្រទេសដទៃទៀតបានធ្វើការសម្រេចថា តើយុត្តិធម៌ត្រូវរកតាមទម្រង់បែបណា? ហើយគេគិតថា ពេលខ្លះគេត្រូវអនុវត្តតាមរយៈគណៈកម្មាធិការស្វែងរកការពិត ដើម្បីស្វែងរកយុត្តិធម៌ នេះជាយន្តការរបស់គេមួយផងដែរ។

នៅពេលនេះ ខ្ញុំសូមផ្ដល់ជូនអស់លោក លោកស្រី ចៅក្រម នូវអត្ថបទចេញពីសៀវភៅរបស់លោក ដេសមិន ទូទូ គឺពាក្យទាំងឡាយដែលគាត់សរសេរនៅក្នុងសៀវភៅរបស់គាត់ នៅពេលដែលគណៈកម្មាធិការស្វែងរកការពិតនិងផ្សះផ្សាជាតិ គេបានបើកសវនាការនៅប្រទេសអាហ្វ្រិកខាងត្បូង។

នៅពេលដែលយើងស្ដាប់នូវសម្ដីរបស់ ដេសមិន ទូទូ ដែលគាត់បានរៀបរាប់នៅចំណុចមួយចំនួន ហើយវាយតំណាងនូវចំណុចដែលវាថ្លែងជូនចំពោះប្រជាជនទាំងឡាយ។ ដូច្នេះ គឺគាត់បានលើកឡើងហើយមានការសម្ដែងការអរគុណទៅលើចំណុចមួយចំនួន ដែលគាត់បានលើកឡើងថា មានប្រជាជន ជនរងគ្រោះរាប់ពាន់នាក់ដែលទទួលរងនូវអំពើហតហួតសិទ្ធិមនុស្សរបស់គាត់នៅក្នុងទសវត្សរ៍ទី៨០ ហើយនិងអំពើជាច្រើនដែលបានកើតឡើងនៅពេលនោះ។

[០៩:២១:៥៧]

យើងក៏មានការថ្លែងអំណរគុណចំពោះជនរាប់ពាន់នាក់ ដែលបានមកផ្ដល់សក្ខីកម្មនៅចំពោះមុខគណៈកម្មាធិការផ្សះផ្សាជាតិនិងស្វែងរកការពិតនេះផងដែរ។ អ្នកទាំងអស់នោះ គឺបានអនុញ្ញាតឲ្យមានយន្តការក្នុងការឈានទៅដល់ប្រជាធិបតេយ្យ។ ហើយវាជាព្រឹត្តការណ៍មួយដ៏សំខាន់នៅក្នុងប្រវត្តិ-សាស្ត្រ។ អ្នកទាំងអស់នោះបានធ្វើឲ្យមានការកកើតឡើងវិញនូវរបៀបរស់រានមានជីវិត និងការរស់នៅរបស់ប្រជាជនឡើងវិញ។ យើងត្រូវសរសើរនូវចំណុចទាំងអស់នេះ ដែលអ្នកទាំងអស់នោះគឺបានបង្កើតទៅលើគណៈកម្មាធិការស្វែងរកការពិតនិងផ្សះផ្សាជាតិ។ ដូច្នេះហើយចំណុចទាំងអស់នេះ គេមិនចាំបាច់ឲ្យមានការបើកសវនាការតាមផ្លូវតុលាការ ដែលវាចំណុចមួយមានការលំបាកផងដែរសម្រាប់ពួកគេ។ ហើយពេលខ្លះទៅវាពិបាកក្នុងការកំណត់ទៅលើសាក្សីដែលវាត្រូវការចំណាយពេលច្រើន ដើម្បីកោះហៅពួកគេមកផ្ដល់សក្ខីកម្ម។

អ្វីដែលគួរឲ្យភ្ញាក់ផ្អើលនោះ យើងប្រជាជនអាហ្វ្រិកខាងត្បូង គឺតំណាងនូវសេចក្ដីសង្ឃឹមចំពោះបុគ្គលទាំងឡាយដែលគាត់លិចលង់នៅក្នុងរបបកាប់សម្លាប់ ហើយនៅពេលនេះ ព្យាយាមធ្វើការដោះ-

ស្រាយតាមរយៈយន្តការសន្តិភាព។

លោក លោកស្រី ចៅក្រម ជាទីគោរព, យើងឃើញថាចំណុចជាច្រើនបានលើកឡើងនៅក្នុងសវនាការនេះ ហើយយើងមានសក្ខីកម្ម និងចម្លើយជាច្រើនដែលបានផ្តល់ជូននៅក្នុងសវនាការ។ ទោះបីជា យើងមិនមានយន្តការគណៈកម្មាធិការស្វែងរកការពិតនិងផ្សះផ្សាជាតិក៏ដោយ ប៉ុន្តែ យើងមានសវនាការនេះ។ វាជាកិត្តិយសរបស់ពលរដ្ឋកម្ពុជា និងប្រទេសនេះ ដែលបានធ្វើឲ្យមានមនុស្សជាច្រើនតាមដាននិងសង្កេតទៅលើសវនាការមួយនេះតាមរយៈកញ្ចក់ទូរទស្សន៍ ហើយអ្នកទាំងអស់នោះគាត់បានឃើញជាក់ស្តែងថា តើមានអ្វីលើកឡើងខ្លះនៅក្នុងសវនាការរបស់យើងនេះ? ដូច្នេះ យើងអាចនិយាយថា តុលាការមួយនេះគឺជាគំរូមួយសម្រាប់តុលាការផ្សេងៗផងដែរ។

នៅពេលនេះ ខ្ញុំសូមលើកឡើងទៅលើចំណុចខ្លឹមសារមួយចំនួនពាក់ព័ន្ធនៅទីនេះ ដូចដែលលោកលោកស្រីបានជ្រាបស្រាប់ទៅលើចំណុចទាំងអស់នេះ។ ខ្ញុំនឹងមិនគេចចេញពីសំណួរទាំងឡាយដែលចោទសួរមកកាន់យើងខ្ញុំកាលពីម្សិលមិញនោះទេ។ នៅពេលដែលភាគីរបស់ខ្ញុំ គឺមេធាវី ការ សាវុត្ថ គាត់បានថ្លែងនូវសេចក្តីបញ្ចប់របស់គាត់ យើងទាំងអស់គ្នាបានយល់ហើយទៅលើចំណុចទាំងអស់ហ្នឹង។ ហើយយើងមិនមែនព្យាយាមថា មិនចុះសម្រុងនិងមិនយល់ស្របទៅលើចំណុចទាំងឡាយនោះទេ យើងដឹងថាវាមានមែនចំពោះការមិនយល់ស្របគ្នាទៅលើអង្គហេតុមួយចំនួន។ ប៉ុន្តែ តួនាទីរបស់មេធាវីការពារក្តីគឺដើម្បីធ្វើយ៉ាងណាឲ្យយើងយល់ចំណុចនិងអង្គហេតុទាំងអស់គ្នា ហើយខ្ញុំអាចគិតថា ខាងសហព្រះរាជអាជ្ញាគឺកំពុងតែរៀបចំនូវការធ្វើសេចក្តីសន្និដ្ឋានតបរបស់គាត់។ ហើយខ្ញុំនិងលើកឡើងនូវចំណុចទាំងឡាយដែលយើងបានលើកឡើងទាំងអស់គ្នា កាលពីម្សិលមិញ ។

[០៩:២៧:០៨]

បញ្ហានិងអង្គហេតុទាំងអស់មួយចំនួន គឺវាជាអញ្ញត្រកម្ម ហើយយើងមិនអាចទទួលយកបានឡើយ។ ដូច្នេះ ខ្ញុំសូមលើកឡើងយោងទៅលើអ្វីដែលលោក ការ សាវុត្ថ បានលើកឡើងកាលម្សិលមិញ ហើយខ្ញុំនឹងលើកចំណុចនេះនៅពេលដែលខ្ញុំធ្វើសេចក្តីសន្និដ្ឋានតប។ ហើយខ្ញុំគិតថា សហព្រះរាជអាជ្ញាក៏កំពុងតែចាប់ផ្តើមរៀបចំនូវសេចក្តីថ្លែងតបរបស់គាត់ផងដែរ។ ក្នុងនាមជាសហព្រះរាជអាជ្ញាអន្តរជាតិ យើងឃើញថា យើងឃើញមាននូវយុត្តិសាស្ត្រអន្តរជាតិជាច្រើនទាក់ទងទៅនឹងពាក្យថា តើនរណាគេជាអ្នកទទួលខុសត្រូវខ្ពស់បំផុត?

ដូចដែលខ្ញុំបានលើកឡើង ហើយខ្ញុំក៏អរគុណផងដែរ ដែលសហព្រះរាជអាជ្ញាបានលើកឡើងថា

ច្បាប់ជាតិ គឺវាជាច្បាប់ធរមាន ដូច្នេះហើយយើងត្រូវអនុវត្ត។ ដូច្នេះ នៅក្នុងសវនាការនេះ ច្បាប់អន្តរជាតិបានយកមកបញ្ចូលនៅក្នុងច្បាប់ជាតិ។ កាតព្វកិច្ចដែលមានចំពោះកូនក្ដីរបស់ខ្ញុំគឺត្រូវលើកឡើងបញ្ហាចំពោះមុខ ហើយខ្ញុំត្រូវតែពិនិត្យទៅលើការកាត់ទោស ហើយនិងការអភ័យទោស។

ដោយហេតុដែលខ្ញុំបានពន្យល់យ៉ាងវែងឆ្ងាយទៅដល់ជនរងគ្រោះហើយថា គឺវាមានបញ្ហាមួយចំនួនដែលចម្រូងចម្រាស់គ្នា គឺយើងថា លោកបានបញ្ជាក់ថា មានទោសធ្ងន់ ប៉ុន្តែយើងយល់ថា គាត់ជាមនុស្សមិនមានពិរុទ្ធភាពនោះទេ។ ប៉ុន្តែ គាត់បានសារភាពពីពិរុទ្ធភាពមួយចំនួន នេះគឺជាការសម្ដែងជាសាធារណៈដែលថា ជនជាប់ចោទនឹងមិនត្រូវធ្វើការសារភាពទទួលទោសនោះទេ ក៏ប៉ុន្តែតើអ្នកជាអ្នកត្រូវតទល់ ឬក៏ជំទាស់ទៅនឹងទឹកភ្នែកដែលសម្រក់ដោយជនជាប់ចោទ? តើអ្នកជាអ្នកត្រូវតវ៉ា ឬក៏ប្រឆាំងទៅនឹងការសូមអភ័យទោស ដែលធ្វើឡើងដោយជនជាប់ចោទដែលគាត់បានធ្វើឡើងក្នុងពេលសម្ដែងឡើងវិញនៅស-២១? ថាតើអ្នកជាអ្នកត្រូវប្រឆាំងទៅនឹងខណៈពេលនៃការពិត?

ខណៈពេលនៃការពិតដែលយើងបានជួបប្រទះទាំងអស់គ្នា ដែលជនជាប់ចោទគាត់បានពិនិត្យពិច័យ ហើយជនរងគ្រោះក៏បានពិនិត្យពិច័យ ហើយចៅក្រមអង្កេតក៏បានពិនិត្យពិច័យទៅលើស្ថានភាពរបស់គាត់ដែរ។ នេះហើយជាពាក្យដែលខ្ញុំរង់ចាំស្ដាប់អស់រយៈពេលសាមសិបឆ្នាំមកហើយ នេះជាសម្ដីរបស់ជនរងគ្រោះ។ តើអ្នកណាជាអ្នកត្រូវជំទាស់ទៅនឹងបទពិសោធន៍ទាំងអស់ដែលយើងជួបប្រទះនេះ?

យើងគ្រប់ៗគ្នា គឺជាអ្នកដែលបានទទួលនូវការសម្ដែងដ៏ស្មោះត្រង់អស់ពីដួងចិត្ត ចេញពីមាត់របស់ជនជាប់ចោទ។

មេធាវី ស្ទួតហ្សីនស្គី, ខ្ញុំបានជំទាស់ទៅនឹងពាក្យសម្ដីរបស់លោកមួយចំនួន ប៉ុន្តែខ្ញុំសូមជម្រាបលោកស្រីថា នៅពេលដែលលោកមានមតិនោះ ហើយលោកស្រីបានសួរ ម៉ម ណៃ ហើយបានជំរុញការសួរដេញដោលនោះ ហើយបញ្ជាក់ថាសាក្សីនោះ ថាជាមនុស្សខ្លាំងម្នាក់នៅក្នុងរបបកុម្មុយនីស្ដហើយជារបបមួយដែលបានដួលរលំទៅហើយ។ យើងបានមើលឃើញទឹកភ្នែករបស់ ឌុច នៅពេលដែលក្នុងពេលចាប់ដំបូងនោះ ដែលយើងបានបង្ហាញសក្ខីកម្ម ដែលបញ្ជាក់ពីសាស្ត្រាចារ្យ ភីង តុន នោះ ហើយយើងបានពិនិត្យទាំងអស់គ្នាឃើញស្រាប់នោះដែរ។

[០៩:៣៣:០០]

ផ្អែកលើអ្វីៗ ដែលយើងបានជួបនេះ ខ្ញុំសូមបញ្ជាក់ថា ពិតហើយយើងបានព្យាយាម និងពិភាក្សាមួយការិយាសហព្រះរាជអាជ្ញា។ នេះហើយជាចំណុចដែលយើងត្រូវធ្វើ។ ចំពោះអ្នកទាំងអស់ដែលមក

ពីប្រព័ន្ធច្បាប់ខំមិនឡ ខ្ញុំមិនចាំបាច់ជម្រាបជូននោះទេ។ មិនបាច់បញ្ជាក់ឲ្យច្បាស់ទេ នៅពេលឯកសារមួយចំនួនដែលបញ្ជាក់ឲ្យមានការទទួលស្គាល់អង្គហេតុ ដែលយើងថាតើវាមានន័យដូចម្តេច? តើសំខាន់យ៉ាងម៉េច? យើងក៏ត្រូវតែរក្សាការពិភាក្សាជាមួយការិយាល័យសហព្រះរាជអាជ្ញាដែលថាការជំនុំជម្រះនេះ ចំពោះមុខអង្គជំនុំជម្រះ តើជនជាប់ចោទបានទទួលស្គាល់អំពីប្រវត្តិសាស្ត្រពិត ដើម្បីរកឲ្យឃើញការពិតទាំងអស់គ្នា ដើម្បីឲ្យមានឯកភាពជាតិ។ យើងត្រូវតែកសាងឯកភាព យើងមិនត្រូវធ្វើការប្រឆាំងគ្នាទៅវិញទៅមកទេ ទាំងអស់គ្នាយើងត្រូវតែកសាងរកឲ្យឃើញនូវការពិត ។

[០៩:៣៤:១០]

កាលពីម្សិលមិញនោះ នៅក្នុងសាលសវនាការ យើងទាំងអស់គ្នាបានឃើញបុរសម្នាក់ ដែលបានសម្តែងការសុំទោសដោយខ្លួនផ្ទាល់ចេញពីចិត្តរបស់គាត់ផ្ទាល់។ ចំពោះមុខលោកប្រធាន លោក លោកស្រី ចៅក្រម ខ្ញុំបានបញ្ជាក់ជូន លោក លោកស្រី ចៅក្រម ហើយនិងអយ្យការ ខ្ញុំបានលើកឡើងពីរឿង អុប្រ៊ៃណូវិច។ ប៉ុន្តែខ្ញុំបាននឹកឃើញបញ្ហានេះជាយូរមកហើយ ថាតើយើងត្រូវធ្វើដូចម្តេច?

នៅក្នុងការជំនុំជម្រះនេះ យើងអាចហៅបានទេ ឬថាតើនៅក្នុងរឿងក្តី អុប្រ៊ៃណូវិច នោះមានខ្លឹមសារដូចម្តេច? ដូច្នេះនៅក្នុងដំណាក់នេះ ខ្ញុំសូមស្នើឲ្យអង្គភាពសោតទស្សន៍ ដើម្បីបង្ហាញនូវរឿងក្តី អុប្រ៊ៃណូវិច អំពីសហព្រះរាជអាជ្ញាទល់នឹងជនជាប់ចោទ ដើម្បីឲ្យសាធារណជនបានដឹងច្បាស់អំពី ថាតើអ្វីយើងអាចបញ្ជាក់ ហើយរំពឹងឲ្យបានសមស្របអំពីការទទួលស្គាល់ពិរុទ្ធភាព ដែលជនជាប់ចោទបានសម្តែងនោះ?

[០៩:៣៥:៥៦]

*(ការចាក់បង្ហាញខ្សែវីដេអូអំពីរឿងក្តីរបស់ អុប្រ៊ៃណូវិច)*

*[ចៅក្រម៖ លោក ម៉ាគូសស្គី តើអយ្យការមានសេចក្តីសន្និដ្ឋានចោទប្រកាន់នោះទេ?*

*ម៉ាគូសស្គី៖បាទ, លោកប្រធានអង្គជំនុំជម្រះ លោកប្រធានអង្គជំនុំជម្រះ អស់លោក លោកស្រីចៅក្រមជាទីគោរព។ ក្នុងនាមជាមេបញ្ជាកការរងនៃកងពលតូចពីសម័យសង្គ្រាម និងក្នុងនាមជាមេបញ្ជាកងពលតូចបានមួយរយៈនោះ គាត់គឺជាមនុស្សម្នាក់ដែលមានការទទួលខុសត្រូវខ្ពស់បំផុត។ មេបញ្ជាការយោធាមានអំណាចក្នុងការសម្រេចអំពីអាយុជីវិតមនុស្សក្នុងកណ្តាប់ដៃរបស់ខ្លួន។ ខ្លួនមានអំណាចក្នុងការការពារភូមិដ្ឋានរបស់ខ្លួន ទីក្រុងរបស់ខ្លួន ប្រជាជនរបស់ខ្លួន ដែលមានប្រុស មានស្រីកុមារ។ ហេតុដូច្នេះហើយគាត់មានការទទួលខុសត្រូវមួយនេះ។ គាត់មានអំណាចរបស់គាត់ទាំងអស់*

នេះ។

លោក អុប្រ៊ើណូវិច បានវត្តមាននៅក្នុងតុលាការនេះ ហើយបានក្រោកក្រឡេកមើលខ្លួនគាត់ដោយភ្នែកគាត់ផ្ទាល់។ គាត់បានក្រឡេកមើលព្រលឹងរបស់ពួកគេ តើការផ្តន្ទាទោសកម្រិតណាដែលអាចសមល្មមនឹងបទឧក្រិដ្ឋនោះ? ប៉ុន្តែសម្រាប់ស្ថាប័នអយ្យការ អំណះអំណាងការពារជនជាប់ចោទលោក អុប្រ៊ើណូវិច គាត់មានគុណសម្បត្តិធំផេងពីព្រោះថាគាត់ជាជនជាប់ចោទក្នុងនាមជាមេបញ្ជាការនិងជាអ្នកទទួលខុសត្រូវយោធាម្នាក់ ខ្លួនមានឆន្ទៈហើយអាចនឹងធ្វើការងាររបស់ខ្លួនបាន។ យើងអាចនិយាយបានថា គាត់គឺជាមេបញ្ជាទីមួយ ហើយវាមានលក្ខណៈជាប្រវត្តិសាស្ត្រនៅក្នុងសាលាក្តីយូហ្គោស្លាវីចំពោះករណីនេះ។

នៅឆ្នាំ១៩៩៨ ខ្ញុំបានចូលរួមនៅក្នុងក្រុម ដែលមានភារកិច្ចធ្វើការស៊ើបអង្កេតក្នុង ស៊ីរ៉ិច ហើយខ្ញុំបានជួបលោក អុប្រ៊ើណូវិច នៅក្នុងការិយាល័យរបស់គាត់។ គាត់បានរងចាំទទួលបញ្ជាពីមេបញ្ជាការទាំងឡាយរបស់គាត់ ហើយត្រូវសហការហើយគាត់មានសហការជាមួយខ្ញុំ គាត់បានធ្វើសេចក្តីសង្ខេបចំពោះកងទ័ពរបស់គាត់ ហើយយើងមានកិច្ចសហការទាំងស្រុង ហើយយើងអាចធ្វើការងារ យើងអាចធ្វើការងាររបស់យើងដោយមិនមានការភ័យខ្លាចអ្វីទាំងអស់ ហើយក៏យើងមានមេបញ្ជាការម្នាក់មកពីសហរដ្ឋអាមេរិកជាមួយនោះផង។ នៅពេលខ្ញុំបានឃើញនូវនៅក្នុងអត្តចរិតរបស់លោក អុប្រ៊ើណូវិច ថាថ្ងៃណាមួយគាត់នឹងធ្វើអ្វីបានល្អ ហើយជាក់ស្តែងយើងបានជួបប្រទះហើយ ។ខ្ញុំសូមសរសើរ។

[០៩:៣៨:៥៦]

ប៉ុន្តែខ្ញុំគិតថា យើងក្រឡេកមើលគ្រប់ជ្រុងជ្រោយ លោក អុប្រ៊ើណូវិច បានផ្តល់នូវការពិតនៅក្នុងស្រ៊ិប្រ៊ិនិសា (Srebrenitsa) ហើយគឺជារបៀបមួយដែលស្មោះត្រង់ សាមញ្ញ ច្បាស់លាស់ គឺជាមេបញ្ជាទទួលខុសត្រូវនៅក្នុងសម័យសង្គ្រាមនៅក្នុងពេលនេះផងដែរ។ នៅពេលនេះដូចដែលខ្ញុំបាននិយាយរួចមកហើយ ការទម្លាយការពិតចំពោះមុខយូហ្គោស្លាវី ចំពោះសហគមន៍អ៊ីស្លាម ហើយនិងជនស៊ែប នោះគឺជាប្រវត្តិសាស្ត្រមួយសំខាន់ ដើម្បីកសាងសន្តិភាពនិងការផ្សះផ្សាជាតិ។ យើងទាំងអស់គ្នាបានជ្រាបរួចហើយ ថាគឺមេដឹកនាំមូស្លីម ហើយនិងបុគ្គលម្នាក់ជនស៊ីវិលក្តី ដែលខ្ញុំបានស្គាល់នោះ ក៏បាន គឺមានភាពធូរស្រាលកាលណាគេបានទទួលដឹងអំពីការពិត បានទទួលការពិតពីគាត់ដោយមិនមានការសង្ស័យអ្វីនោះ។ ការទទួលខុសត្រូវជាយោធា ហើយនិងអត្តចរិតរបស់គាត់ក្នុងន័យយោធា ប៉ុន្តែជាអកុសលគាត់ត្រូវតែធ្វើការតាមបញ្ជា មិនមែនជាកិត្តិយសទេដែលគាត់ត្រូវដកខ្លួនចេញ។ ជាក់ស្តែង ក្នុងពេល

*បច្ចុប្បន្ននេះ គាត់មិនបានធ្វើការវិភាគទានដល់យូហ្គោស្លាវី ប៉ុន្តែគាត់បានសម្រេចធ្វើអ្វីដែលមេបញ្ជាការបញ្ជាឲ្យគាត់ធ្វើ ហើយជាផ្នែកមួយនៃសង្គ្រាមចាប់តាំងពីឆ្នាំ១៩៩២ មក ។*

*ប៉ុន្តែគាត់បាននាំឲ្យយើងនូវថ្ងៃនេះអំពីអតីតយូហ្គោស្លាវីមកការជំនុំជម្រះ ដើម្បីឲ្យមានការផ្សះផ្សាជាតិកើតឡើង។ កងទ័ពដែលមានឋានៈដូចគាត់ គឺអាចប្រាប់ការពិត ហើយនិងមកបង្ហាញខ្លួនចំពោះមុខ ហើយនិងផ្តល់នូវមូលដ្ឋានមួយចំនួនដើម្បីឲ្យមានការផ្សះផ្សាជាតិ ។*

*យើងពិនិត្យមើលអត្តចរិតរបស់បុគ្គលម្នាក់ អំពីអតីតយូហ្គោស្លាវីនៅក្នុងតុលាការថ្ងៃនេះ ហើយនិងផ្តល់ឲ្យយើងមានសេចក្តីសង្ឃឹមថា គេនឹងប្រកាន់យកនូវអ្វីដែលចាប់ផ្តើម ហើយនិងនាំយកទៅផ្ទះវិញនូវអ្វីដែលគាត់បានទទួលនោះដែរ។ ជាពិសេសអ្វីដែលយើងបានទទួលនៅក្នុងសាលាក្តីនេះ នៅក្នុងរឿងក្តីនេះ គឺគាត់ជាមនុស្សម្នាក់ដែលគាត់បានឆ្លើយសំណួរ ហើយគាត់បានឆ្លើយសំណួរលោក កាណាវាស គាត់បានឆ្លើយយ៉ាងច្បាស់មិនមានការស្ទាក់ស្ទើរ ហើយមិនមានការដោះសា ហើយខ្ញុំមិនបានឃើញដោះសាអ្វីទេនៅថ្ងៃនេះនោះ។ អ្វីដែលជំរុញឲ្យគាត់ជឿ ទៅថាគាត់មិនទទួលការខុសត្រូវរបស់គាត់នោះទេ គាត់បានប្រាប់តុលាការយ៉ាងច្បាស់ៗ ។*

*[០៩:៤១:៤៣]*

*ហើយខ្ញុំបានពិនិត្យឃើញថា ថាមពលកម្លាំង ហើយនិងតម្លៃមួយ ដែលព្រះរាជអាជ្ញាបានឃើញអំពីស្ថានភាពនោះ ថាគាត់ជាអ្នកសហការភ័ស្តុតាង ដែលអាចនាំមកដល់ជនផ្សេងទៀតមកតុលាការនេះ គឺពាក្យមួយម៉ាត់ៗរបស់គាត់ គឺច្បាស់។ អ្វីដូច្នេះ អ្វីៗដែលគាត់បាននិយាយ គឺអាចជឿជាក់បាន ហើយគឺជាតម្លៃដ៏សំខាន់សម្រាប់អង្គជំនុំជម្រះ ដើម្បីជំនុំជម្រះលើអង្គហេតុ។*

*ខ្ញុំមិនមានការសង្ស័យអ្វីទេ គឺលោក អុប្រេីណូវិច គាត់នឹងផ្តល់សក្ខីច្បាស់លាស់ដូចនេះដែរ នៅក្នុងរឿងក្តីបន្ទាប់ទៀតនោះ ។*

*ស៊ែបី ត្រូវតែពិនិត្យថា តើអ្វីកើតឡើងនៅក្នុងការជំនុំជម្រះ? ថាតើអ្វីថាជនរួមជាតិដែលទទួលខុសត្រូវ គឺលោក អុប្រេីណូវិច ដែលចំពោះមុខ។ ដូច្នេះ ខ្ញុំមានការសង្ឃឹមថា គឺអាចជួយឲ្យពួកគេរំសាយចិត្តនៅក្នុងប្រទេសរបស់គេនោះ ហើយដែលថា គាត់ជាជនជាប់ចោទធ្ងន់ម្នាក់នៅក្នុងរឿងក្តីនេះ ហើយខ្ញុំស្គាល់ថា លោក អុប្រេីណូវិច និងប្រកាន់នូវពាក្យរបស់គាត់ ហើយនូវបញ្ហាមួយចំនួនពីអ្វីដែលគាត់បានធ្វើនៅក្នុងរឿងក្តីចំពោះមុខតុលាការនេះ។ ហើយជាពិសេស យើងនឹងមានប្រយោជន៍អំពីការស្តាប់មេបញ្ជាការ វីអ៊ែរអេស (VRS) ជាមេបញ្ជានៃកងពលតូច អំពីបញ្ហាយោធា អំពីការបញ្ជា អំពីការ*

ត្រួតពិនិត្យ និងការទទួលខុសត្រូវ។ គឺជាទស្សនទានតែមួយគត់ និងមិនគួរឲ្យជឿជាក់បាន ដែលអស់លោក លោកស្រីអាចទទួលបាន។

កងពលតូចនៃទាហានទាំងអស់ ខ្ញុំចង់សំដៅជាពិសេសទៅលើកងពលតូច ក្នុង វីអ័រអេស ត្រូវមានបញ្ជាការទាំងឡាយ ដែលលាក់ខ្លួននៅក្នុងរណ្តៅត្រង់សេ។ គឺសម្រាប់ករណីមួយចំនួន ភាគច្រើននៃជនទាំងនោះ។ ទន្ទឹមគ្នានោះ គឺជាមេបញ្ជាការនៃកងពលតូច ត្រូវតែទទួលខុសត្រូវលើអ្នកទាំងអស់នោះ ហើយនិងអ្នកទាំងអស់ ដែលនៅក្នុងការគ្រប់គ្រងរបស់គាត់ ។

យើងទាំងអស់គ្នាអាចឮ មេបញ្ជាណាម្នាក់ ការផ្តល់ចម្លើយដែលបញ្ជាក់អំពីការទទួលខុសត្រូវរបស់គាត់ក្នុងឋានៈជាមេបញ្ជា ហើយទោះបីជាមានការដាក់ឲ្យតទល់ក្នុងការចោទសួរនោះក៏ដោយ គាត់មិនដែលបានបដិសេធអំពីការទទួលខុសត្រូវជាមេបញ្ជានោះទេ។ ហើយអាចបង្ហាញជូនអង្គជំនុំជម្រះថាតើវាមានន័យដូចម្តេចនៅពេលនោះ? គឺបានច្បាស់ជាងអ្វីដែលអាចនឹងប្រាប់តាមបទបញ្ជាដែលគាត់ធ្វើនោះ។ ពីអ្នកជំនាញដែលបញ្ជាក់ខាងព្រះរាជអាជ្ញានេះ គឺវាមានតម្លៃណាស់សម្រាប់ពេលទៅអនាគតនោះ ។

[០៩:៤៥:00]

គាត់អាចប្រាប់យើងបានពិសេស។ ខ្ញុំមិនចូលទៅដល់លម្អិតពីព្រោះមិនសមស្របនៅពេលនេះ។ គាត់មានលទ្ធភាពប្រាប់យើងអំពីបញ្ហាសន្តិសុខ គឺជាបញ្ហាដ៏សំខាន់នៅក្នុងតួនាទីរបស់គាត់នោះ។ ដូចលោក លោកស្រីចៅក្រមបានដឹងហើយ គាត់បាននាំមកក្នុងរឿងក្តីនេះផងដែរ នូវភ័ស្តុតាង វត្ថុតាង សម្ភារៈមួយចំនួនដែលខ្ញុំនឹងជម្រាបជូន និងលម្អិតជូនតុលាការ ។

ដូច្នេះនៅពេលដែលយើងពិនិត្យមើលអំពើដ៏អាក្រក់របស់គាត់នោះ យើងនឹងសួរខ្លួនឯងថា ហើយបានដឹងគ្រប់គ្នាផងដែរ។ តើការកាត់ទោសបែបណាដែលអាចទៅធ្វើបាននោះ ហើយខ្ញុំសូមឲ្យមើលអនុសាសន៍របស់អយ្យការដែលថា អាចពី២០ ទៅ២៥ឆ្នាំ ដែលថាគាត់បានផ្តល់ការពិតមួយចំនួន ដល់អយ្យការថា ថ្ងៃមួយនៅពេលដែលយើងត្រូវប្រឈមមុខទៅនឹងហេតុការណ៍មួយទាក់ទងថាធ្វើម៉េច ដើម្បីឲ្យបានរស់រានមានជីវិតនោះ។ យើងមានរណ្តៅរួមជាច្រើនដែលជាលទ្ធផលនៃអំពើដែលគាត់បាន ធ្វើ ហើយដំណាក់កាលពេលនោះ គឺជាចំណុចមួយដែលអង្គជំនុំជម្រះដែលអាចទទួលបានអ្វីការពិតពី អតីតប្រទេសយូហ្គោស្លាវីនោះ។ ខ្ញុំកត់សម្គាល់ថា ដើម្បីជាផលប្រយោជន៍ដល់មូស្លីមទាំងឡាយ អាចនឹងធូរស្រាលអារម្មណ៍ដោយសារបានឃើញការពិតទាំងអស់នេះ បានឮការពិតទាំងអស់នេះ ។

*ឥឡូវពាក្យខ្ញុំថ្ងៃនេះ លោកអុប្រ៊ែណូវិច ក៏បានបញ្ជាក់ អ៊ីចឹងការសាលក្រមនោះក៏មិនអាចនាំអ្នកដែលស្លាប់ឱ្យរស់មកវិញ ប៉ុន្តែអាចធ្វើឱ្យរំសាយទុក្ខវេទនារបស់ស្ត្រី និងបុរស កុមារ ដែលស្លាប់នៅស្រិប្រិនិសា ហើយនិងអ្នកនៅរស់រានមានជីវិតនៅទីនោះផងដែរ ។*

*ប៉ុន្តែ ខ្ញុំមានសេចក្តីសង្ឃឹមដ៏ឆោតល្ងង់មួយចំនួន។ នៅឆ្នាំ១៩៩៨ ខ្ញុំ នៅពេលដែលគាត់ធ្វើការងារនៅ ស្វីស ហើយគាត់អាចនឹងផ្តល់នូវការសារភាពពិរុទ្ធភាពមួយដែលតុលាការអាចនឹងទទួលយកបាន។ នេះ គឺជាចំណុចមួយដ៏សំខាន់នៃដំណើរការនីតិវិធី ហើយខ្ញុំជឿជាក់ថា អង្គជំនុំជម្រះនឹងពិចារណាយ៉ាងស៊ីជម្រៅនូវស្ថានភាពនេះ។ សូមអរគុណ។ ]*

**លោក ហ្វេង់ស្វ័រ រូ៖**

ដូច្នេះ លោក លោកស្រីចៅក្រមបានជ្រាបហើយ តាមទស្សនៈរបស់ខ្ញុំ នេះគឺជាអ្វីដែលការជំនុំជម្រះនៅទីនេះគួរតែអនុវត្ត។ តាមទស្សនៈរបស់ខ្ញុំ វាអាចនឹងទប់ស្កាត់នូវអ្វីដែលបានកើតឡើងកាលពីល្ងាចម្សិលមិញ ដែលសហព្រះរាជអាជ្ញាបានលើកឡើងនោះ ។

[០៩:៤៨:៤៩]

ខ្ញុំក៏សូមអនុញ្ញាតពន្យល់ផងដែរ អ្នកដែលមិនថិតនៅក្នុងប្រព័ន្ធច្បាប់ខំមិនឡូ។ ខ្ញុំនឹកឃើញថាការិយាល័យសហព្រះរាជអាជ្ញា នៅក្នុងសេចក្តីសន្និដ្ឋានតបរបស់គាត់នោះនឹងព្យាយាមជម្រាបអង្គជំនុំជម្រះថា តាមពិតនៅក្នុងករណី អុប្រ៊ែណូវិច ហ្នឹងគាត់បានទទួលអ្វីៗទាំងអស់។ នេះមិនមែនជាការពិតទេក្នុងករណី អុប្រ៊ែណូវិច ត្រូវបានទទួលរងការចោទប្រកាន់ចំនួនប្រាំ។ ក្នុងរយៈពេលពីរឆ្នាំ គាត់មិនព្រមទទួលសារភាពពីទោសរបស់គាត់ទេ ប៉ុន្តែនៅពេលដែលមានការជំនុំជម្រះលើរូបគាត់នោះ នៅពេលដែលសាក្សីទីមួយបានមកផ្តល់សក្ខីកម្មគាត់បានមកជួបខាងអយ្យការ គឺនៅក្នុងពេលនោះហើយដែលគាត់បាននិយាយថា គាត់ចង់សម្តែងការសារភាពពិរុទ្ធភាពទាំងស្រុង។ ប៉ុន្តែ ខ្ញុំមិនចង់ឱ្យទទួលអង្គហេតុទាំងអស់ ឬក៏ទទួលទាំងអស់នូវអ្វីដែលចោទប្រកាន់ខ្ញុំនោះទេ នេះគឺកើតឡើងបន្ទាប់ពីការពិភាក្សាជាមួយអយ្យការរបស់គេនោះ។ អ្នកខ្លះហៅថា បានដោះស្រាយ អ្នកខ្លះឆ្លើយថា ដោះស្រាយបាន នេះជាពាក្យមួយដែលខ្ញុំមិនទទួលទេ។ នេះជាការពិភាក្សា ការសន្ទនារកដំណោះស្រាយ។ អ្នកវិជ្ជាជីវៈច្បាប់បានដឹងច្បាស់ហើយថាសហព្រះរាជអាជ្ញាចាប់ពីដំបូងឡើងនោះ ពេញចិត្តធ្វើការចោទប្រកាន់ជាច្រើននៅក្នុងការចោទប្រកាន់របស់ខ្លួន ទោះបីជាខ្លួនមិនជឿជាក់ថា រឿងហ្នឹងវាពិតក៏ដោយ។

តើអ្វីជាការពិភាក្សារវាងអយ្យការ និងមេធាវីការពារនោះវាអាចជារឿងអ្វី? វាអាចនឹងបង្ហាញ

ឲ្យព្រះរាជអាជ្ញាដឹងថា ការចោទប្រកាន់នៅក្នុងដីកាចោទប្រកាន់នេះគឺមិនច្បាស់លាស់ទេ ហើយយើងដឹងច្បាស់ថា កូនក្តីរបស់យើងនឹងមិនទទួលពីអ្វីដែលគាត់មិនបានធ្វើទេ នេះហើយជាការពិតនៅក្នុងរឿងក្តី។ លោក អុប្រេីណូវិច គាត់រងការចោទប្រកាន់ចំនួនប្រាំ ប្រាំបទចោទ។ ការសមគំនិតនៅក្នុងប្រល័យពូជសាសន៍មួយដែលសហព្រះរាជអាជ្ញាបានលើកលែងចោល បានទម្លាក់ចោលបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ហើយនិងសម្លាប់រង្គាល ក៏បានអយ្យការរក្សាទុក គឺបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ហើយនិងគឺត្រូវបានលើកលែងនោះដែរ។ បទមនុស្សឃាតក៏ត្រូវបានអយ្យការលើកលែងដែរ។

អ៊ីចឹងហើយគឺការសារភាពអំពីបទចោទទាំងប្រាំនេះ គឺជាកត្តាសំខាន់ នេះហើយដែលអយ្យការហើយនិងចៅក្រមបានបញ្ជាក់យ៉ាងច្បាស់ដែលថា គាត់បានទទួលសារភាពពុរុទ្ធភាពបែបនេះនោះ ដែលយើងអាចពិនិត្យឃើញស្រាប់នៅក្នុងឯកសារអ៊ីនធឺណែត កិច្ចព្រមព្រៀងរវាងភាគីទាំងពីរក៏បានដាក់ជូនទៅចៅក្រម ហើយចៅក្រមទាំងនោះបាននិយាយថា មែនការងារនោះពិតប្រាកដមែន ពីព្រោះជននេះបានឯកភាពទៅលើអ្វីៗទាំងអស់ គឺថាអ្វីដែលគាត់បដិសេធនោះ ចំណុចសំខាន់នោះគាត់បានទទួលផ្នែកសំខាន់នៃ-- ហើយការដែលទទួលស្គាល់ហ្នឹង គឺអាចនឹងជួយដល់ការផ្សះផ្សាជាតិ នេះគឺជាចៅក្រមដែលធ្វើការនៅក្នុងតុលាការព្រហ្មទណ្ឌសម្រាប់អតីតប្រទេសយូហ្គោស្លាវី គេបានបញ្ជាក់បែបនេះ។

[០៩:៥៣:០៨]

វាជាការពិតថាចំពោះមុខអង្គជំនុំជម្រះនេះយើងមានប្រព័ន្ធច្បាប់ស៊ីវិលឡូ ការសារភាពពិរុទ្ធភាពមិនមានចែងនៅក្នុងប្រព័ន្ធលម្អិតដូចដែលយើងពិភាក្សានោះទេ ប៉ុន្តែខ្ញុំដឹងហើយថាតើអ្វីជាកត្តារារាំងអំពីការប៉ុនប៉ងកុំឲ្យមានការសារភាពបែនេះនោះ ពីព្រោះវិធានផ្ទៃក្នុងនិយាយហើយ ដែលថាអ្វីដែលមិនមានចែងនៅក្នុងច្បាប់ជាតិ យើងត្រូវប្រើច្បាប់អន្តរជាតិមកអនុវត្ត។ តើវាមានឧបសគ្គអ្វីដែលថាមិនអាចធ្វើបាន? ឧបសគ្គនោះគឺ ការមិនមានឱកាសពីសហព្រះរាជអាជ្ញាដែលកត់ត្រាមិនត្រឹមត្រូវនៃប្រវត្តិសាស្រ្តដែលកើតឡើងនោះ។ វានាំឲ្យយើងមានការខកចិត្តចំពោះការសម្តែងមតិជាសាធារណៈចំពោះមតិដែលជនរងគ្រោះដែលថា គាត់មិនបាននិយាយអ្វីទាំងអស់ទេនោះ។ រហូតមកទល់ថ្ងៃម្សិលមិញហ្នឹង នៅក្នុងតុលាការនោះជនរងគ្រោះនិយាយថាគាត់មិនបាននិយាយអ្វីៗទាំងអស់ទេ ហើយទទួលស្គាល់ថាវាអាចមានប្រយោជន៍ចំពោះការផ្សះផ្សាជាតិ ប៉ុន្តែមិនទាំងស្រុងទេតើឲ្យជនជាប់ចោទនិយាយប៉ុនណាទៀត?

ជនជាប់ចោទដែលចាប់ពីដំបូងថ្ងៃដំបូងនៃដំណើរការក្តី គាត់បានជម្រាបសហចៅក្រមស៊ើបអង្កេតថា ខ្ញុំមានពិរុទ្ធភាព ខ្ញុំជាអ្នកទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងអស់ដែលបានកើតឡើង។ ប៉ុន្តែ

សហព្រះរាជអាជ្ញាបានសម្រេចធ្វើសេចក្តីសន្និដ្ឋាននូវទឡ្ហីករណ៍សាមញ្ញៗមួយចំនួន តាមទម្លាប់អាជីពរបស់ខ្លួនដែលបញ្ជាក់អំពីទស្សនវិទូ ទស្សនវិស័យដូចទៅ គឺថាគាត់ជាបិសាច ខ្ញុំនិយាយថា គាត់មិននិយាយថាគាត់ជាបិសាចទេ ប៉ុនគាត់និយាយបែបហ្នឹងក៏ដូចជានាំពាក្យដំបូងថា គាត់ជាបិសាច ហើយគាត់ថាគាត់ស្នើឲ្យមានការកាត់ទោស៤០ឆ្នាំជាប់ពន្ធនាគារ ហើយសាធារណជននឹងពេញចិត្ត។ នៅពេលដែលសហព្រះរាជអាជ្ញាទទួលស្គាល់បែបនេះ ពាក្យទាំងអស់នេះដែលមិនទាន់បានឮពីមុននេះគឺនោះគឺជាពាក្យសំខាន់មួយ ហើយយើងត្រូវតែលម្អិតឲ្យវែងជាហ្នឹងទៅទៀត យើងត្រូវតែព្យាយាមយល់អំពីយន្តការដែលនាំឲ្យជនម្នាក់ដែលជាជនដ៏ល្អដ៏ត្រឹមត្រូវនៅក្នុងករណីទាំងអស់ ហើយក្លាយទៅជាអ្នកធ្វើទារុណកម្ម។

លោកសហព្រះរាជអាជ្ញា នេះហើយជាចំណុចដែលខ្ញុំចង់ឮពីពាក្យរបស់លោក ពីព្រោះថាអ្វីៗក៏បាននិយាយដែរនៅក្នុងតុលាការនូរីមប៊ឺក គេនិយាយថា អ្នកទាំងនោះជាបិសាចគេចង់ថ្កោលទោសរបស់គេលើអ្នកនោះ ប៉ុន្តែមិនមែននូរីមប៊ឺកទេនេះជាកម្ពុជា ហើយនៅរ៉្វាន់ដាក៏មានករណីស្រដៀងគ្នានេះដែរ។ ដូច្នេះ ជាអ្វីជាឧទាហរណ៍ដែលយើងចង់បង្ហាញជាគំរូដែលយើងចង់បង្ហាញនោះ តើអ្វីជាមូលដ្ឋាននៃទឡ្ហីករណ៍របស់លោកដែលថាមិនទាក់ទងទៅនឹងអង្គហេតុឲ្យជាក់លាក់ ប៉ុន្តែយើងនិយាយអំពីបញ្ហាតើបញ្ហាវានៅត្រង់ណា?

[០៩:៥៧:១២]

អ្វីដែលលោក ដេវីដ ឆេនដ៏ល័រ និយាយនោះគឺថាបន្ទាប់ពីជាច្រើនខែក្រោយពីគិតមុននឹងសរសេរសៀវភៅរបស់គាត់នោះ គាត់បាននិយាយអំពីបទឧក្រិដ្ឋនៃការគោរពបញ្ជា ដែលមានន័យថា តើយើងក្លាយទៅជាឧក្រិដ្ឋជនដោយសារតែគោរពបញ្ជា។ ខ្ញុំនឹងចូលទៅដល់ចំណុចនេះនៅក្នុងសេចក្តីសន្និដ្ឋានមួយផ្នែកទៀតដែលខ្ញុំនឹងលើកឡើង បញ្ហានេះគឺវាហួសពីអ្វីពីការគោរពនោះទៀត គឺទាក់ទងទៅនឹងការគោរពបញ្ជាមេ គឺជាចំណុចមួយដែលសំខាន់បំផុត។

លោកសហព្រះរាជអាជ្ញា យើងបានិយាយថា យើងមិនចង់ឲ្យកូនក្តីរបស់យើងក្លាយជាអ្នកទទួលថ្មបាក់នោះទេ ខ្ញុំចង់ឲ្យលោកយល់ឲ្យបានច្បាស់អំពីចំណុចនេះ។ អ្វីដែលមានន័យនោះ នៅពេលដែលខ្ញុំប្រើពាក្យថា ទទួលថ្មបាក់នោះ ដូចដែលលោកបានដឹងច្បាស់ហើយថា អ្នកទទួលថ្មបាក់នោះគឺនៅក្នុងសង្គមមួយដែលសង្គមមួយ ដែលថាដូចមនុស្សម្នាក់ដែលទទួលនៅអំពើទាំងអស់គឺការឈឺចាប់ទាំងអស់នៃសង្គមតែម្នាក់ឯង គឺដាក់ទៅលើស្មា ឬក៏ទៅលើគី-- តាមទ្រឹស្តីហេប្រូគឺជាគំនិតដើមដែលថា សត្វ

មួយដែលត្រូវដឹកធ្ងន់ដោយលំបាក ហើយគាត់មិនមានការធ្វើអ្វីទាល់តែសោះ ប៉ុន្តែត្រូវទទួលការងារនោះដោយធ្ងន់ទៅវិញ ដូចជាសត្វពាហនៈដែលបម្រើមនុស្សបែបនោះដែរ អ៊ីចឹងហើយសង្កត់ធ្ងន់ទៅលើបុរសម្នាក់នេះថា ជាអ្នកទទួលថ្មបាក់នោះគឺ ការអះអាងបែបនេះមិនបានបញ្ជាក់អ្វីពីការពិត អំពីការកសាងនៅមនុស្សធម៌នោះទេ។ ឌុច មិនមែនត្រូវទទួលអ្វីៗទាំងអស់អំពីអំពើសោកនាដកម្មទាំងអស់ ដែលឋិតនៅលើស្មារបស់គាត់តែម្នាក់ឯងនោះទេ។

[០៩:៥៩:៤២]

តាមរយៈដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំបានឮថា ឮពាក្យពេចន៍ដែលបានលើកឡើងនិយាយអំពីទឹកភ្នែកក្រពើជាពាក្យពេចន៍មួយ ដែលរៀបរាប់ទាក់ទងទៅនឹងទឹកភ្នែករបស់ជនជាប់ចោទថា ជាទឹកភ្នែកក្រពើ ហើយនិងវិប្បដិសារីដែលជនជាប់ចោទសម្តែងដែរ។ ខ្ញុំឮពីសហព្រះរាជអាជ្ញា សេចក្តីថ្លែងរបស់សហព្រះរាជអាជ្ញា ដែលថាគាត់ខិតខំប្រឹងប្រែងដើម្បីទទួលបាននូវការតម្កើងគាត់ រៀបចំទំនាក់ទំនងជាមួយ ជិតដិតជាមួយនឹងថ្នាក់ដឹកនាំជាន់ខ្ពស់។ គាត់ផ្តល់ដំបូន្មានទៅឲ្យមេដឹកនាំជាន់ខ្ពស់ដោយមិនមានការភ័យខ្លាចអ្វីនោះទេ។ ហើយព្រះរាជអាជ្ញាក៏បានបន្ថែមផងដែរថា ជនជាប់ចោទគឺជាអ្នកដើរតាមគោលមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។

ខ្ញុំមិនដឹងថា ថាតើនៅក្នុងប្រទេសកម្ពុជា ខ្ញុំបានក៏បានឮផងដែរថា ជនជាប់ចោទពេញចិត្តធ្វើទារុណកម្ម បណ្តុះបណ្តាលមនុស្សឲ្យក្លាយជាអ្នកធ្វើទារុណកម្ម តាមរយៈឯកសារដែលមាននៅក្នុងសំណុំរឿង ដូចជាសេចក្តីថ្លែងទាក់ទងនឹងការដឹងគុណ។ ខ្ញុំក៏បានដឹងថាជនជាប់ចោទមានតួនាទីសំខាន់ៗដែលគាត់បានរៀបចំធ្វើឡើងជាមួយនឹង ស៊្វ មេ៉ត។ ប៉ុន្តែ ខ្ញុំអត់បានដឹងថា សហព្រះរាជអាជ្ញាបានស្នើសុំនូវតុលាការថា ស៊្វ មេ៉ត បានគាំទ្រទៅដល់ការអះអាងនេះទេ។ ខ្ញុំអត់បានដឹងរឿងនេះទេ ក៏ប៉ុន្តែ អ្វីដែលខ្ញុំបានដឹងនោះ គឺថាសេចក្តីថ្លែងបែបនេះ គឺថាវាមិនត្រឹមត្រូវទេ ដែលលើកឡើងដោយ អេតធេសាន់ ដែលជាបុគ្គលិករបស់ការិយាល័យសហព្រះរាជអាជ្ញា។

[១០:០២:១១]

ខ្ញុំគួរតែលើកឡើង ខ្ញុំនឹងលើកឡើងឲ្យបានច្រើននៅពេល អេតធេសាន់ នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្ញុំ។ ខ្ញុំសូមរំឭកឡើងថា ខ្ញុំនឹងជំទាស់តវ៉ាជាមួយនឹងអត្តចរិតរបស់គាត់ក្នុងនាមជាអ្នកជំនាញម្នាក់។ ខ្ញុំមិនបានដឹងថាតើអង្គជំនុំជម្រះបានដឹងដែរឬក៏យ៉ាងនោះទេ ប៉ុន្តែគាត់ក៏គួរដឹងថា នៅក្នុងសេចក្តីសម្រេចថ្មីៗនេះ សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា លើក អេតធេសាន់ មិនមែនជាអ្នក

ជំនាញទេ ដោយសារតែគាត់ធ្វើការឲ្យការិយាល័យសហព្រះរាជអាជ្ញា ។

ដូច្នេះ ខ្ញុំសូមទាញនូវសេចក្តីថ្លែងបញ្ជាក់របស់លោក អេតធេសាន់ ដែលជាសមាជិករបស់ការិយាល័យសហព្រះរាជអាជ្ញា ដែលគាត់មិនមែនជាអ្នកជំនាញនោះទេ។

ខ្ញុំបានឮថា សុន សេន និងជនជាប់ចោទ គឺថាគឺជាអ្នកប្រកៀកស្មាគ្នា។ ខ្ញុំនឹងលើកបញ្ហានេះនៅពេលក្រោយ។ ខ្ញុំឮពាក្យពេចន៍ដែលនិយាយថា ដូចជាជនជាប់ចោទ គឺជាអ្នកបង្កើតនូវបណ្តាញដ៏គួរភ័យខ្លាចនៅក្នុងប្រទេសកម្ពុជា ហើយលោកនឹងបង្ខំឲ្យមានការផ្សះផ្សាជាតិដោយសំអាងទៅលើការពិតទាំងអស់នេះ។

លោកព្រះរាជអាជ្ញា, តើ ឌុច ជា ប៉ុល ពត ឬក៏អី? តើ ឌុច បានក្លាយទៅជា ប៉ុល ពត ហើយឬនៅ? ខ្ញុំសូមទោសចំពោះជនរងគ្រោះនូវអ្វីដែលខ្ញុំនឹងនិយាយ ។ ប៉ុន្តែ ថាតើមានមនុស្សប៉ុន្មាននាក់ដែលស្លាប់នៅស-២១? មានតែដប់ពីរពាន់បីរយប៉ែតសិបនាក់(១២.៣៨០នាក់)។ ហើយចុះក្នុងប្រទេសកម្ពុជាទាំងមូលស្លាប់ប៉ុន្មាន? មួយចុចប្រាំពីរលាននាក់(១.៧លាន) ទាំងអស់រលីង? នេះមានន័យថា ស-២១ ទទួលខុសត្រូវតិចជាងមួយភាគរយនៃចំនួនមនុស្សស្លាប់នៅទូទាំងប្រទេសកម្ពុជា។ ហើយលោកជម្រាបជូនអង្គជំនុំជម្រះថា ឌុច បានចាប់ផ្តើមបង្កើតបណ្តាញគួរឲ្យភ័យខ្លាចនៅក្នុងប្រទេសកម្ពុជា។ ហេតុអីអាចនិយាយអ៊ីចឹងបាន? ហើយនិយាយថា គាត់គឺជាឧបករណ៍មួយដ៏មានប្រសិទ្ធភាពនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ នេះគឺជាពាក្យរបស់លោក ដែលថាគាត់ជាឧបករណ៍បម្រើមនោគមវិជ្ជាបក្សកុម្មុយនីស្តកម្ពុជាដ៏មានប្រសិទ្ធភាពនោះ ។

[១០:០៥:២៣]

លោកបានដកស្រង់សម្តីរបស់ខ្ញុំដែលនិយាយថា ដែលបាននិយាយនចំពោះមុខសវនាការនេះថា គឺតើគាត់ជាអ្នកដែលពង្រីកនូវភាពភ័យខ្លាចនៅក្នុងប្រទេសឬក៏អត់? តើ ឌុច--

[១០:០៥:៥៦]

លោកប្រធាន លោក លោកស្រីចៅក្រម, សូម្បីតែលោកបានឮសួរ បានស្តាប់ឮយ៉ាងច្រើនមកហើយ សម្រាប់ផ្នែករបស់ខ្ញុំនៅថ្ងៃនេះ។ ខ្ញុំនឹងមិនបំផ្លើស និយាយតែការពិត។ ខ្ញុំនឹងបម្រើការងារនេះដោយពិនិត្យមើលឡើងវិញនូវចំណុចសំខាន់ៗនៅក្នុងសវនាការដែលយើងបានយល់ស្របជាមួយគ្នា។ នោះមានន័យថា អ្វីដែលខ្ញុំនឹងធ្វើទាំងអស់នោះ គឺលើកឡើងសម្តីដែលពាក់ព័ន្ធបានមកពីជនជាប់ចោទហើយសម្រាប់អ្នកបកប្រែ ។

ខ្ញុំនឹងចូលទៅដល់ចំណុច២.២ នៃឯកសារដែលខ្ញុំបានផ្តល់ជូន គឺពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលខ្ញុំដកស្រង់អំពីសម្រង់ឯកសារនោះ។ ខ្ញុំចង់ ដើម្បីផ្តល់ជាប្រយោជន៍ដល់អង្គជំនុំជម្រះផង ទាក់ទងទៅនឹងសវនាការពីថ្ងៃដំបូងរបស់ ឌុច។

នៅក្នុងចំណុចនេះ លោក លោកស្រីចៅក្រមនឹងជ្រាប និងឃើញអំពីសេចក្តីថ្លែងរបស់ព្រះរាជអាជ្ញារបស់ អុប្រេីណូវិច ផងដែរ។ ហើយយើងក៏ឃើញសម្តីរបស់ជនជាប់ចោទនៅក្នុងថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ ផងដែរ។ ហើយបន្ថែមទៅលើចំណុចនេះ ការបាត់បង់ជីវិតមនុស្ស គឺគាត់បានលើកឡើងគឺមានប្រហែលជាមួយលានប្រាំពីរនាក់ ហើយក្នុងនាមជាបក្ខជន ខ្ញុំទទួលស្គាល់ថា ខ្ញុំទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយបក្សកុម្មុយនីស្តកម្ពុជានៅអំឡុងពេលនោះ។

ចំណុចទីពីរ ខ្ញុំក៏ចង់លើកឡើងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីរស-២១។ ហើយខ្ញុំទទួលស្គាល់តាមផ្លូវច្បាប់ទៅលើឧក្រិដ្ឋកម្មទាំងអស់នោះ។ ហើយខ្ញុំសូមបញ្ជាក់ផងដែរថា ខ្ញុំទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មកើតឡើងនៅមន្ទីរស-២១ ជាពិសេសចំពោះឧក្រិដ្ឋកម្ម ការធ្វើទារុណកម្ម និងការសម្លាប់ដែលបានធ្វើឡើងនៅទីនោះ។ ហើយលោក លោកស្រីចៅក្រមដឹងហើយនៅក្នុងពេលសវនាការ គាត់មិនដែលមានការគេចចេញពីការទទួលខុសត្រូវមន្ទីរម-១៣ទេ។ គាត់បានលើកឡើងថា គាត់គឺជាអតីតប្រធានមន្ទីរម-១៣ ហើយបន្ទាប់មក គាត់ជាប្រធានមន្ទីរស-២១។ ហើយឧក្រិដ្ឋកម្មទាំងអស់វាពាក់ព័ន្ធទៅនឹងការឃុំខ្លួនដែលមិនមានភាពមនុស្សធម៌ ដែលក្នុងនោះមានការឃុំខ្លួនស្ត្រីបុរស និងកូនក្មេង រួមទាំងការកាប់សម្លាប់បុរសស្ត្រី និងកូនក្មេងផងដែរ ។

[១០:០៩:២៩]

ដូច្នេះនេះជាអំពើដែលខ្ញុំទទួលខុសត្រូវ។ គឺវាផ្អែកចម្លើយនេះចុះនៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩ ដែលជាចម្លើយឆ្លើយដោយជនជាប់ចោទ ។

លោកចៅក្រម ឡាវែន៍ ដែលនៅថ្ងៃ១៥ មិថុនា ឆ្នាំ២០០៩ គាត់បានសួរសំណួរទៅជនជាប់ចោទថា "ដូច្នេះនិយាយជាទូទៅ ថាតើជនជាប់ចោទទទួលស្គាល់ថា អ្នកទោសនៅមន្ទីរស-២១ ទទួលរងនៃការរំលោភទៅលើកិត្យានុភាពផ្លូវចិត្ត និងរូបរាងកាយរបស់ពួកគេដែរឬទេ? បានន័យថាគ្មានអំពើប្រព្រឹត្តទៅលើពួកគេជាច្រើន ដូចជាការបង្អត់អាហារ ការដកនូវអនាម័យ ការមិនផ្តល់ការថែទាំសុខភាព និងចំណុចជាច្រើនទៀត។ ថាតើលោកទទួលស្គាល់ទៅលើលក្ខខណ្ឌឃុំខ្លួនបែបនោះដែរឬទេ? ថាអ្នកទោសទាំងអស់ទទួលរងនូវអំពើហិង្សាជាច្រើន ដែលបានកម្រិតចំពោះពួកគេ។ តើលោកជនជាប់ចោទទទួល

ស្គាល់ថា លក្ខខណ្ឌដ៏លំបាកលំបិនទាំងអស់នោះ បានប្រព្រឹត្តឡើងចំពោះអ្នកទោសទាំងអស់គ្នារៀងៗខ្លួន និងជារួមដែរឬទេ? តើលោកទទួលស្គាល់ដែរឬទេទៅលើចំណុចទាំងអស់នេះ? ថាអ្នកទាំងអស់នោះ គឺត្រូវបានគេដកហូតនូវភាពមនុស្សធម៌ ដើម្បីឲ្យពួកគេមានការភ័យខ្លាច" ។

ជនជាប់ចោទ ឆ្លើយថា "លោកចៅក្រមជាទីគោរព, ឧក្រិដ្ឋកម្មដែលលោកចៅក្រមបានលើកឡើងនោះ ខ្ញុំទទួលស្គាល់ទាំងអស់។ ខ្ញុំមិនបដិសេធឧក្រិដ្ឋកម្មមួយណាឡើយ ណាមួយឡើយ"។

នៅពេលដែលយើងចោទសួរអំពីការទទួលខុសត្រូវទៅលើរបស់ជនជាប់ចោទ សហព្រះរាជអាជ្ញាកាលពីម្សិលមិញបានតវ៉ាថា មេធាវីការពារក្តីបានព្យាយាមបង្អាក់នូវលំហូរ ឬក៏ការបញ្ចូលនូវភ័ស្តុតាង ប៉ុន្តែនៅទីនេះ យើងមានឯកសារជាច្រើនដែលវាទាក់ទងទៅនឹងករណីអង្គហេតុ និងអង្គច្បាប់។

ក្មេងទាំងអស់ យើងដឹងហើយថា ត្រូវបានគេសម្លាប់នៅជើងឯក ហើយនិងមានឃើញ លលាដ៍ក្បាលកូនក្មេងដែលត្រូវគេបោកនឹងដើមឈើ។ ជនជាប់ចោទថា "ខ្ញុំទទួលខុសត្រូវចំពោះអំពើទាំងអស់នេះ ដែលវាកើតឡើងក្នុងការគ្រប់គ្រងរបស់ខ្ញុំ"។

[១០:១២:៤៥]

ទឹកភ្នែកក្រពើ ដែលខ្ញុំបានបញ្ជាក់។ ទឹកភ្នែកក្រពើ ឬយើងន័យធៀបថា ទឹកភ្នែកក្លែងក្លាយ គឺវាឃើញនៅក្នុងទីនេះ ដែលគេបញ្ជាក់ ហើយលោកចៅក្រម ខាតវ៉ាយថ៍ បានសួរថា "តើលោកមានវិប្បដិសារីដែរឬទេ លោកជនជាប់ចោទ? ហើយលោកមានការសោកស្តាយចំពោះតួនាទីរបស់គាត់ក្នុងការទាញយកចម្លើយពីអំពើទារុណកម្មដែរឬទេ? តើវាត្រឹមត្រូវដែរឬទេ?" ជនជាប់ចោទឆ្លើយថា "ជាការពិត ខ្ញុំមានការសោកស្តាយ"។ ហើយបន្ទាប់មកទៀតចៅក្រម ខាតវ៉ាយថ៍ បានលើកឡើងនូវសំណួរដូចខាងក្រោមនេះ។

"ថាតើលោកបានជួយទៅលើកុមារបីនាក់នោះយ៉ាងម៉េច? ដែលលោកបានលើកឡើងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។ លោកបានបង្ហាញថា លោកមានការសោកស្តាយដែលលោកមិនបានធ្វើអ្វីលើសពីនោះ ដែលមិនបានព្យាយាមឲ្យច្រើនជាងនោះ ជួយទៅលើក្មេងៗទាំងអស់នោះ"។ ហើយជនជាប់ចោទឆ្លើយថា "ជាការពិត ខ្ញុំមានការសោកស្តាយទៅលើចំណុចនេះ"។ ហើយនៅពេលដែលយើងព្យាយាមនឹកឃើញអំពីសម្តីរបស់ លោក អុប្រ៊េណូវិច វិញ យើងអាចពិចារណាទៅលើចំណុចនេះ ។

លោក លោកស្រីចៅក្រម លោកស្រីចៅក្រម ខាតវ៉ាយថ៍ បានសួរម្តងទៀតទៅលើសំណួរដែល

បានលើកឡើងទៅលើឯកសារមួយ។ លោកស្រីចៅក្រមបាននិយាយអំពីកម្មាភិបាលខ្មែរក្រហម ដែលអនុញ្ញាតឱ្យកូនក្មេងមានការរស់រានមានជីវិត។ ហើយជនជាប់ចោទបានឆ្លើយថា “ភាពអាម៉ាសដែលខ្ញុំមាន គឺវានៅតែអន្ទោលតាមខ្ញុំជានិច្ច ហើយខ្ញុំមានភាពអាម៉ាសណាស់នៅក្នុងរាល់វិនាទីនៃជីវិតរបស់ខ្ញុំ ។

[១០:១៥:00]

ចំពោះភាពកំសាក ទាក់ទងនឹងភាពកំសាក នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ខ្ញុំព្យាយាមមិនជួបជាមួយអ្នកទោសទេ ហើយខ្ញុំអាចធ្វើដូច្នេះបាន ខ្ញុំមិនទៅជួបពួកគេទេ ខ្ញុំមិនដឹងថា ខ្ញុំរៀបរាប់យ៉ាងម៉េចនោះទេ ប៉ុន្តែខ្ញុំអាចជម្រាបថា ខ្ញុំធ្វើការបិទភ្នែក បិទត្រចៀក។ ខ្ញុំមិនចង់ឃើញស្ថានភាពទាំងអស់នេះដែលវាកើតឡើងចំពោះអ្នកទោសនោះឡើយ។ ដោយសារតែស្ថានភាពជាក់ស្តែង វាធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍របស់ខ្ញុំ ហើយវាមិនត្រូវនឹងអារម្មណ៍របស់ខ្ញុំ ដូច្នេះហើយ គឺខ្ញុំធ្វើការបិទត្រចៀក និងបិទភ្នែកកុំឱ្យឮ និងស្តាប់នូវអ្វីបានទាំងអស់ ហើយថាតើនេះជាការកំសាក ឬក៏យ៉ាងម៉េច?

លោកចៅក្រម ឡាវែន៍ បានសួរសំណួរមួយទៅកាន់ជនជាប់ចោទទៅលើចំណុចនេះ ហើយជនជាប់ចោទឆ្លើយថា វាហួសពីភាពកំសាកទៅទៀត ខ្ញុំទទួលស្គាល់ថា វាជាភាពកំសាក ប៉ុន្តែវាហួសលើភាពកំសាកទៅទៀត គឺខ្ញុំបានក្បត់មិត្តភក្តិរបស់ខ្ញុំ ហើយវាបានឆ្លុះបញ្ចាំងថា វាជាភាពកំសាកមួយចំពោះខ្ញុំ។

លោកសហព្រះរាជអាជ្ញា, កាលពីម្សិលមិញលោកបានលើកឡើងអំពីបុគ្គលជនជាប់ចោទ ដែលគាត់អង្វរសុំឱ្យមានការអត់ឱន។ ហើយលោកមិនទទួលយកនូវចំណុចនេះតាមរយៈសេចក្តីថ្លែងបិទរបស់លោក ឬក៏ទឡ្ហីករណ៍របស់លោក ដែលលោកបានលើកឡើង។

ចំពោះអង្គហេតុទាក់ទងទៅនឹងការងារដ៏ល្អិតល្អន់របស់ជនជាប់ចោទ វាជាចំណុចមួយដែលគួរឱ្យចាប់អារម្មណ៍ នៅខែកញ្ញា ឆ្នាំ២០០៩ លោកបាននិយាយថា ការងារហ្មត់ចត់នេះ គឺវាទាក់ទងទៅនឹងអត្តចរិតរបស់ជនជាប់ចោទ ហើយបើសិនយើងលើកឡើងអំពីអភិបាលកិច្ចវិញ វាគឺជាការងារដែលធ្វើបានដោយល្អ ហើយនៅពេលនោះ នៅពេលដែលរដ្ឋាភិបាលនោះកាន់អំណាច វាជាអំពើមួយឧក្រិដ្ឋ ហើយពាក្យទាំងអស់នេះ គឺអាចឱ្យលោកយល់អំពីអត្តចរិតរបស់ជនជាប់ចោទ ។

នាពេលនេះ ខ្ញុំចង់រៀបរាប់នូវអត្ថបទដែលយើងមាននៅក្នុងសំណុំរឿងឯកសាររបស់យើង។ ជាបឋម ខ្ញុំសូមដកស្រង់នូវសម្តីពីប្រតិចារឹកនៅក្នុងសវនាការ ជាពិសេសនៅពេលការសម្តែងឡើងវិញ

នៅស-២១ និងនៅជើងឯក។ ប្រតិចារឹកនោះបានលើកឡើងថា នៅពេលដែលខ្ញុំមកដល់ស-២១ គឺខ្ញុំមានអារម្មណ៍តក់ស្លុតនូវអ្វីដែលបានកើតឡើងកាលពីនៅមន្ទីរស-២១ ហើយខ្ញុំប្រឈមមុខនឹងអ្នករស់រានមានជីវិតបីរូប ដែលឈរចំពោះមុខខ្ញុំ ហើយគាត់ជាអ្នកតំណាងនៅអ្វីដែលកើតឡើងនៅពេលអតីតកាល ។ ខ្ញុំជួបផ្ទាល់ ទៅប្រទះទៅនឹងរូបថតស្ត្រីកូនក្មេង ដែលត្រូវបានជាប់ឃុំ ដែលវាធ្វើឲ្យខ្ញុំរំជើបរំជួលអារម្មណ៍ ហើយឲ្យខ្ញុំមានអារម្មណ៍មិនសុខស្រួល និងមានអារម្មណ៍តក់ស្លុតនៅអ្វីដែលបានកើតឡើងនៅពេលអតីតកាល ហើយខ្ញុំសូមឲ្យមានការអត់ឱនពីព្រលឹងរបស់ជនរងគ្រោះដែលបានកើតឡើង ហើយខ្ញុំមិនអាចបំភ្លេចឡើយ នៅកាលដែលខ្ញុំទៅមើលជើងឯក និងស-២១ នៅពេលដែលសម្តែងឡើងវិញនេះទេ។

[១០:១៩:៥៣]

ជាថ្មីម្តងទៀត ខ្ញុំសូមលើកទៅលើសេចក្តីថ្លែងការណ៍មួយនេះផងដែរ ថាតើបុគ្គលមួយណាអាចត្រូវបានគេចាត់ទុកថា ឌុច អាចយល់ស្របថាត្រឡប់ទៅស-២១ទៀតនោះ ដែលមានអ្នកយាមមន្ត្រីសន្តិសុខ ចៅក្រមស៊ើបអង្កេត បានទៅជាមួយនោះ តើយើងអាចគិតឃើញដែរឬទេ ថាគាត់ប៊ានទៅទីនោះ?

ដូច្នេះនេះ គឺជាដំណើរការមួយដែលគាត់បានដឹកនាំខ្លួនគាត់ សម្រេចចិត្តទៅទីនោះ នៅពេលដែលខ្ញុំលើកឡើងពីមុននេះ ថាគ្មានអ្វីអាចលុបឧក្រិដ្ឋកម្មទាំងអស់នេះឲ្យចេញពីការយល់ឃើញ និងការមើលឃើញរបស់យើងនោះទេ ប៉ុន្តែជននេះបានទទួលស្គាល់នូវពិរុទ្ធភាពរបស់គាត់ ហើយគាត់បានយល់ស្របសហការជាមួយនឹងចៅក្រមនៅក្នុងដំណាក់កាលស៊ើបអង្កេត ហើយគាត់យល់ស្របត្រឡប់ទៅទីកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្ម ហើយគាត់បានយល់ស្របទៅលើការសម្តែងឡើងវិញផងដែរ នៅចំពោះមុខអង្គ-សវនាការនៅចំពោះមុខពលរដ្ឋកម្ពុជា។ ដូច្នេះហើយវាធ្វើឲ្យចំណុចនេះ វាពាក់ព័ន្ធទៅនឹងការបន្ថយនូវភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ដែលយើងត្រូវយកមកពិចារណា។ បើមិនមានការសោកស្តាយ និងវិប្បដិសារីរបស់ជនជាប់ចោទនោះទេ គឺយើងមិនអាចរកឃើញនូវការពិតនោះទេ ប្រសិនបើគាត់សម្រេចចិត្តថានៅស្ងៀមមិនឆ្លើយតបទៅលើចំណុចទាំងអស់ដែលបានចោទសួរមកគាត់នោះ។ ជនជាប់ចោទបានសម្រេចថា វាគ្រប់គ្រាន់សម្រាប់គាត់ហើយ គាត់ត្រូវតែលាតត្រដាងទៅលើចំណុចទាំងអស់នេះ ។

[១០:២២:០៩]

ជាថ្មីម្តងទៀត នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ នៅពេលដែលខ្ញុំទៅជើងឯក ដោយមានចៅក្រមស៊ើបអង្កេតទៅជាមួយនោះ ខ្ញុំគិតអំពីពេលដែលក្មេងៗត្រូវបានគេសម្លាប់ ដោយអំពើទារុណកម្ម ដោយ

ការបោកនឹងដើមឈើ ហើយនៅពេលនោះយើងឃើញថា ជនជាប់ចោទ គាត់សម្រេចទៅទីនោះ ហើយគាត់បានលុតជង្គង់ ដើម្បីធ្វើការគោរពវិញ្ញាណក្ខន្ធទៅលើអ្នកទាំងអស់នោះ។

ការងាររបស់មេធាវីការពារក្តី ដែលមានជនជាប់ចោទទទួលខុសត្រូវទៅលើឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបែបនេះ មិនមានភាពងាយស្រួលនោះទេ។ ប៉ុន្តែ យើងតែងតែផ្តល់ផលប្រយោជន៍ទៅដល់សហព្រះរាជអាជ្ញា ពួកគេមានលទ្ធភាព ពួកគេមានអ្នកជំនាញ ពួកគេមានជំនួយការពីខាងការិយាល័យរបស់ពួកគេ ដែលពួកគេអាចស្នើសុំ ប៉ុន្តែខាងសហព្រះរាជអាជ្ញា គាត់ខ្វះចំណុចមួយ គឺគាត់មិនមានការទាក់ទងជាមួយនឹងជនជាប់ចោទ។

យើងជាមេធាវីការពារក្តី យើងបានជួបជាមួយជនជាប់ចោទដោយផ្ទាល់ជាមួយគាត់នៅមន្ទីរឃុំឃាំង ដែលនៅពេលនោះ គាត់និយាយដោយចំហ ហើយគាត់និយាយដោយបើកចេញពីបេះដូងរបស់គាត់។ យើងបានយល់នូវអ្វីដែលលោកសហព្រះរាជអាជ្ញា លោក លោកស្រីសហព្រះរាជអាជ្ញា មិនបានយល់ទៅលើចំណុចទាំងអស់នេះ។ យើងបានជួបជាមួយនឹងជនជាប់ចោទដែលគាត់មិនបានព្យាយាមលាក់លៀមនឹងយើង ហើយនៅពេលដែលគាត់យំ មិនមាននរណាគេក្រៅតែពីមេធាវីការពារក្តី ដែលគាត់បានឃើញតែប៉ុណ្ណោះ។ ដូច្នេះហើយនេះជាចំណុច ដែលយើងបានឃើញទៅលើព្រឹត្តិការណ៍ទាំងអស់នេះ។ ហើយនេះជាអ្វីហើយ ដែលខ្ញុំបានលើកឡើងនៅក្នុងថ្ងៃនេះ។

ទោះបីជាមានការលើកឡើងទឡ្ហីករណ៍យ៉ាងម៉េចក៏ដោយពីខាងសហព្រះរាជអាជ្ញា នៅពេលនេះ គឺយើងឃើញថាហាក់ដូចជាមិនមានការទទួលស្គាល់នៅក្នុងសេចក្តីសន្និដ្ឋានរបស់គាត់អំពីចំណុច និងការទទួលស្គាល់ពិរុទ្ធភាពរបស់ជនជាប់ចោទ និងការថ្លែងនូវវិប្បដិសារីរបស់ជនជាប់ចោទផងដែរ។ ហើយខ្ញុំមិនឃើញនៅក្នុងសេចក្តីសន្និដ្ឋាន សូម្បីតែពាក់កណ្តាលប្រយោគ លើកឡើងអំពីជនជាប់ចោទដែលគាត់បានលើកឡើងអំពីវិប្បដិសារីរបស់គាត់ ។

[១០:២៥:១៦]

នៅក្នុងសេចក្តីសន្និដ្ឋានសហព្រះរាជអាជ្ញា គាត់មិនបានលើកឡើងទៅលើចំណុចនេះ សូម្បីមួយប្រយោគ មិនបានផ្តល់ជាសញ្ញាណាមួយ លើកឡើងទៅលើវិប្បដិសារីនេះឡើយ ឬក៏ការទទួលស្គាល់នៅកំហុសនេះឡើយ។ ចំណុចនេះ ជាចំណុចមួយត្រូវកែតម្រូវ ហើយគួរតែយើងយល់ថា នៅពេលដែលគាត់ធ្វើសន្និសីទកាសែត គាត់បានលើកឡើងទៅលើចំណុចសារភាព ពិរុទ្ធភាពនេះ។ ប៉ុន្តែ គាត់មិនបានសរសេរនៅក្នុងសេចក្តីសន្និដ្ឋានរបស់គាត់។ សហព្រះរាជអាជ្ញាបានយល់ខុសទៅលើចំណុចហ្នឹង ប៉ុន្តែ

មេធាវីការពារក្តីយល់យ៉ាងច្បាស់ទៅលើចំណុចហ្នឹង។ ទោះបីជាមានទឡ្ហីករណ៍ និងការបដិសេធដែលលើកឡើងដោយសហព្រះរាជអាជ្ញាយ៉ាងណាក៏ដោយ ដូចដែលបានលើកឡើងនៅក្នុងកថាខណ្ឌ១៦៧ យើងឃើញថាឌុច គាត់ទទួលខុសត្រូវ ការទទួលខុសត្រូវរបស់គាត់ជាប្រធាននៅស-២១ ក្នុងនាមជាមេ ហើយគាត់បានពន្យល់ថា មានការពន្យល់ថា គាត់បានព្យាយាមលាតត្រដាងនូវការពិតនៅក្នុងឆ្នាំ១៩៩៩ ដោយសារតែគាត់មិនអាចលាក់បាំងនូវមន្ទីរស-២១ទៀត ហើយសហព្រះរាជអាជ្ញាបានលើកឡើងផងដែរ នៅក្នុងកថាខណ្ឌនេះថា ជនជាប់ចោទលើកឡើង ថាវាជាការប្រឌិតរបស់ជនជាប់ចោទ។

ដូច្នេះហើយនៅក្នុងចំណុចនេះ ជនជាប់ចោទបានសម្តែងនូវវិប្បដិសារីចំពោះជនរងគ្រោះ និងគ្រួសាររបស់ពួកគេ ហើយក៏បានសម្តែងនូវការសោកស្តាយចំពោះបុគ្គលិករបស់ខ្លួនផងដែរ ហើយជនជាប់ចោទបានបន្តជម្រាបទៅចំណុចទាំងអស់នេះទៅកាន់សហចៅក្រមស៊ើបអង្កេត ហើយជនជាប់ចោទបានលើកឡើងថា បុគ្គលិកក្រោមបង្គាប់របស់គាត់ គឺមិនធ្វើឡើងប្រព្រឹត្តអំពើទាំងអស់នោះ ដោយឆន្ទៈពួកគេនោះទេ ពួកគេស្ថិតនៅក្នុងសភាពភ័យខ្លាច ហើយប្រព្រឹត្តអំពើកាប់សម្លាប់ ដោយការភ័យខ្លាច។

កថាខណ្ឌ១៦៨ បានលើកឡើងថា ឌុច បានបដិសេធមិនធ្វើការបន្ទុកទៅកាន់បុគ្គលិករបស់ពួកគាត់ឡើយ ហើយទទួលខុសត្រូវដោយផ្ទាល់ទៅលើឧក្រិដ្ឋកម្មដែលបានកើតឡើងនៅមន្ទីរស-២១។ ហើយចំពោះចំណុចដែលបានលើកឡើងចំពោះជនជាប់ចោទ គឺជនជាប់ចោទបានលើកឡើងថា គាត់ប្រព្រឹត្តអំពើទាំងអស់នេះ ដោយសារភ័យខ្លាច និងដោយមានការអាម៉ាស់ទៅលើអំពើទាំងអស់នេះ ហើយជនជាប់ចោទគាត់មានអារម្មណ៍ឈឺចាប់ចំពោះឧក្រិដ្ឋកម្មទាំងអស់នេះដែលបានកើតឡើង។ ចំណុចទាំងអស់នេះ គឺជាអង្គហេតុដែលសហចៅក្រមស៊ើបអង្កេតបានរកឃើញក្រោយពីមានការស៊ើបអង្កេតជាងមួយឆ្នាំ ប៉ុន្តែសហព្រះរាជអាជ្ញា មិនបានទទួលស្គាល់ទៅលើចំណុចទាំងអស់នេះទេ ។

លោក លោកស្រី ចៅក្រម ខ្ញុំគិតថានៅពេលនេះ យើងគួរតែដល់ពេលឈប់សម្រាកហើយ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី។ ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី អញ្ជើញចូលវិញ ដើម្បីបន្តកិច្ចសវនាការរបស់យើង។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១០:២៩នាទី ដល់ម៉ោង ១១:៥២នាទី]*

[១០:៥២:៤២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ! អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សូមអញ្ជើញមេធាវីការពារក្តីអន្តរជាតិបន្តនូវសេចក្តីសន្និដ្ឋានរបស់ខ្លួន ។

**លោក ហ្រ្វង់ស្វ័រ រ៉ូ៖**

សូមអរគុណលោកប្រធាន។

ដើម្បីសង្ខេបឡើងវិញអ្វីដែលខ្ញុំបានរៀបរាប់ពីដើមទីមក ទាក់ទងទៅនឹងការទទួលសារភាពទៅលើអង្គហេតុដោយ ឌុច។ ដូចដែលសហព្រះរាជអាជ្ញាហាក់មានការមន្ទិលសង្ស័យទាក់ទងទៅនឹងភាពស្មោះត្រង់ សេចក្តីស្មោះត្រង់របស់ជនជាប់ចោទ និងការរៀបរាប់អំពីអត្តចរិតរបស់គាត់។ ហើយមុននឹងខែកញ្ញា ២០០៩ សវនាការចុងក្រោយ ខ្ញុំបានលើកឡើងនូវសំណួរមួយនៅក្នុងសារណាដើម្បីធ្វើសេចក្តីសន្និដ្ឋានទាក់ទងទៅនឹង ឌុច ដែលសួរថា ខ្ញុំសូមលើកសំណួរនេះឡើងវិញ។ សំណួរដែលដកពីសេចក្តីថ្លែងដោយរបស់សហព្រះរាជអាជ្ញា រ៉ូប៊ីត ពេទីត លោកដឹងថា ជាអំណះអំណាងដ៏ល្អដែលដកចេញមកពីភាគីបដិបក្ខ ដែលនៅក្នុងសេចក្តីថ្លែងបើក។ លោកសហព្រះរាជអាជ្ញា រ៉ូប៊ីត ពេទីត ខ្ញុំគិតថាជាសំណួរដែលទាក់ទងទៅនឹងការសារភាពរបស់ជនជាប់ចោទ ដែលសំណួរចោទសួរមកលើជនជាប់ចោទ ។

បើតាមខ្ញុំចាំគាត់បានសួរថាអ៊ីចេះ។ ដូច្នេះនៅចុងបញ្ចប់នៃសវនាការ បើសិនណាយើងត្រូវស្វែងរកឲ្យឃើញនូវការពិតទាក់ទងទៅនឹងអ្វី ដែលបានកើតឡើងនៅមន្ទីរស-២១ បើដូច្នេះខ្ញុំសូមដាក់ជូនជាចុងក្រោយថា គាត់ត្រូវតែសួរតទល់ជាមួយនឹងជនជាប់ចោទទាក់ទងទៅនឹងអង្គហេតុនៅក្នុងរឿងក្តីនេះ និងទាក់ទងទៅនឹងសេចក្តីសន្និដ្ឋានប្រកបទៅដោយហេតុផល ដែលត្រូវទាញសេចក្តីសន្និដ្ឋានប្រកបទៅដោយហេតុផល ប្រសើរជាជាងគ្រាន់តែជាការស្រមើស្រមៃ ដែលថា ឬក៏សន្និដ្ឋានថា គាត់ធ្វើអំពើនេះដោយសារវាប្រឆាំងទៅនឹងឆន្ទៈរបស់គាត់ ។ ហើយនៅក្នុងពេលស៊ើបអង្កេត គាត់បានអះអាងថា គាត់មិនបានដឹងថា មានអំពើហ្នឹងកើតឡើងទេ នៅពេលគាត់រវល់ជាប់ធ្វើការនៅក្នុងការិយាល័យរបស់គាត់ គាត់រវល់ជាប់កត់ត្រា តែតាមការពិតនោះគាត់ជាមនុស្សម្នាក់ដែលត្រូវបានទទួលការទុកចិត្តពីមេរបស់គាត់ ក្នុងការអនុវត្តកិច្ចការរបស់គាត់ ទាក់ទងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅស-២១។

ប្រសិនបើគាត់ទទួលស្គាល់ចំណុចនេះ នោះជនជាប់ចោទអាចអះអាងថា គាត់ពិតជាបានទទួល

សារភាព ហើយគាត់គួរតែទទួលបានប្រយោជន៍ពីការទទួលសារភាពនេះ។ ខ្ញុំសូមដកស្រង់សម្តី។ ខ្ញុំបាននិយាយហើយ ឌុច បានទទួលខុសត្រូវចំពោះសារភាពខុសត្រូវចំពោះឧក្រិដ្ឋកម្មនេះយ៉ាងច្រើន ក៏ប៉ុន្តែដូចដែលសហព្រះរាជអាជ្ញាបានលើកឡើងមកហើយថា បានលើកឡើងនៅក្នុងសារណាមកថា ហើយដោយសារថា សហព្រះរាជអាជ្ញាមានក្របខ័ណ្ឌកម្រិតទាក់ទងទៅនឹងទស្សនៈយល់ឃើញរបស់ខ្លួន នោះវាមានការទទួលខុសត្រូវយ៉ាងច្បាស់ ។

[១០:៥៧:៤៣]

ខ្ញុំសូមចោទជាសំណួរនេះ មួយសំណួរម្តងៗ ទៅលើជនជាប់ចោទនៅមុខអស់លោក លោកស្រីចៅក្រមទាំងអស់គ្នា នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩។ ឌុច យើងបានចូលមកដល់ថ្ងៃបញ្ចប់នៃដំណើរការនីតិវិធីហើយ ខ្ញុំមានសំណួរមួយត្រូវសួរអ្នកឯង ខ្ញុំសួរសំណួរនេះ មួយពាក្យម្តងៗ។

សហព្រះរាជអាជ្ញា រ៉ូប៊ីត ពើទីត, ខ្ញុំបាននិយាយទៅកាន់គាត់ "តើលោកទទួលស្គាល់ទៅលើអង្គហេតុ ដែលថាអ្នកឯង គឺជាមនុស្សម្នាក់ដែលទទួលបានការទុកចិត្តពីថ្នាក់លើ នៅក្នុងការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅស-២១? តើអ្នកឯងទទួលសារភាពទទួលស្គាល់អ៊ីចឹងមែនឬក៏អត់?" ជនជាប់ចោទ ឆ្លើយទៅវិញ "បាទ, ខ្ញុំទទួលស្គាល់ទាំងស្រុង"។ ហើយខ្ញុំដកស្រង់បន្តទៅទៀត "ដូច្នេះថា តើហេតុម៉េចបានជាការសង្ស័យនៅខាងសហព្រះរាជអាជ្ញាតទៅទៀត សហព្រះរាជអាជ្ញាមានរយៈពេលពីរខែ ដើម្បីរៀបចំសេចក្តីព្រាងសារណារបស់ខ្លួន ដែលមានចំនួន១១៦ទំព័រ ដោយមាន*ហ្វូតណូត*យ៉ាងល្អដាក់ជូនតុលាការ។ ហើយខ្ញុំអត់មានឃើញអំណះអំណាងណាមួយដែលការិយាល័យសហព្រះរាជអាជ្ញាលើកឡើងថា មានការពេញចិត្តទៅនឹងចម្លើយដែលបានផ្តល់ជូននេះទេ ដែលជនជាប់ចោទផ្តល់ជូននេះទេ។

សហព្រះរាជអាជ្ញាយល់ឃើញថាវមានការលំបាក។ អស់លោក លោកស្រីជាចៅក្រមទាំងអស់យើងអាចឃើញនៅក្នុងសេចក្តីថ្លែងការណ៍កាលពីម្សិលមិញ គឺថាមានពាក្យពីរម៉ាត់ថ្មី ដែលនិយាយម្តងហើយម្តងទៀត ដែលមានគោលបំណងនិយាយម្តងហើយម្តងទៀត ដើម្បីចោទប្រកាន់ ដើម្បីទាញជនជាប់ចោទឆ្ពោះទៅរកថា ការប្រព្រឹត្តិ ថាគាត់ហ្នឹងប្រព្រឹត្តដោយការពេញចិត្ត រហូតទាល់តែគាត់ទទួលស្គាល់ចំណុចទាំងអស់នេះ ទើបគាត់សារភាពដែលថា ការសារភាព។ ដូច្នេះ ការសារភាពទាំងអស់នេះគឺថាមិនស្មោះត្រង់ទេ នេះមិនមែនជាអ្វីដែលគាត់សារភាពទេ នេះគឺជាពាក្យថ្មីហើយ។ ដូច្នេះ យើងនឹងឃើញសេចក្តីថ្លែងបញ្ចប់របស់ ឌុច ក្រោយមកទៀតនៅក្នុងសេចក្តីថ្លែងរបស់គាត់ថា ខ្ញុំពេញចិត្ត ខ្ញុំមាន

ការអបអរសាទរ មានការពេញចិត្តពេញថ្លើម ដូច្នេះមានពាក្យសំខាន់ៗមិនអ៊ីចឹង? ដែលលោកគិតថាជាពាក្យពីរម៉ាត់សំខាន់សម្រាប់លោកមែនទេ?

ជំនួសឲ្យការទទួលស្គាល់អ្វីដែលគាត់បានទទួលស្គាល់។ ឥឡូវនេះ ខ្ញុំសូមចូលទៅលើអ្វីដែលគាត់បាននិយាយ។ សហព្រះរាជអាជ្ញាបានអានពាក្យសម្ដីរបស់ ឌុច ដែលនិយាយថា "នៅពេលគាត់ឃើញរូបថតរបស់គាត់ថតនៅពេលនោះ គាត់និយាយថា នេះជាសវនាការនៅថ្ងៃទី១៧ ខែមេសា នៅពេលដែលខ្ញុំឃើញរូបថតរបស់ខ្ញុំដែលបានថតនៅពេលនោះ ដែលហាក់ថាខ្ញុំមានមោទនភាពចំពោះការងារដែលខ្ញុំបានធ្វើ ដើម្បីឲ្យខ្ញុំរក្សាបាននូវតំណែងនេះ"។ នេះជាការដកស្រង់សម្ដីដែលលោកបានឮកាលពីម្សិលមិញ ។

[១១:០២:០១]

នេះគឺជាពាក្យសម្ដីដែលជនជាប់ចោទនិយាយបន្តបន្ទាប់មកទៀតទាក់ទងទៅនឹងរូបថតដដែលនេះ។ ប៉ុន្តែបើយើងក្រឡេកមើលទៅក្រោយវិញនៅពេលខ្ញុំអាចនិយាយថា ខ្ញុំមានភាពអាម៉ាស់ណាស់ វាគួរឲ្យរន្ធត់ ហើយមនុស្សម្នាក់អាចមានភាពអាម៉ាស់ លុះណាតែបានឃើញរូបថតអ៊ីចឹងទើបថាវាមានភាពអាម៉ាស់។ នៅពេលដែលមនុស្សនោះត្រូវតែឆ្លើយតបទៅនឹងការទទួលខុសត្រូវ អាយុជីវិតមនុស្សជាងដប់ពីរពាន់នាក់។ ដូច្នេះ សម្រាប់ខ្ញុំវាហាក់បីដូចជាថា អង្គជំនុំជម្រះសាលាដំបូងមានឯកសារទាំងអស់ដែលគាំទ្រទៅដល់ទស្សនៈទាំងអស់ដែរដែលថា ជនជាប់ចោទពិតជាបានទទួលស្គាល់ ការទទួលខុសត្រូវពេញលេញចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខស-២១។ គាត់បានទទួលស្គាល់ថា គាត់បានបញ្ជាពួកគេឲ្យធ្វើដូច្នោះ គាត់បានញុះញង់ពួកគេ ហើយគាត់បានត្រួតត្រាទៅលើបុគ្គលិករបស់គាត់។

ប្រសិនជាអាចធ្វើទៅបាន ខ្ញុំសូមលើកឡើងនូវពាក្យពីរបីម៉ាត់ ដែលហាក់បីដូចយើងមានផលប៉ះពាល់ទៅលើទស្សនៈរបស់ខ្ញុំ ទាក់ទងទៅនឹងការសារភាពនេះ។ ខ្ញុំសូមយោងជាពិសេសទៅលើអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ ដែលខ្ញុំបានចោទសួរទៅគាត់ "តើលោកគិតថា អង្គហេតុដែលជនជាប់ចោទបានទទួលស្គាល់នូវការទទួលខុសត្រូវរបស់គាត់នោះពីការងាររបស់គាត់?"។ ហើយលោក ឆេនដ៍ល័រ បានឆ្លើយថា "បាទ។ វាជាចម្លើយស្រួល។ បាទ, ខ្ញុំជឿ ខ្ញុំជឿថាវាដូច្នេះ ហើយខ្ញុំហាក់មានចំណាប់អារម្មណ៍នៅពេលដែលជនជាប់ចោទទទួលស្គាល់នូវពិរុទ្ធភាពរបស់ខ្លួន"។ នេះជាសម្ដីរបស់លោក ឆេនដ៍ល័រ។ នេះ គឺជាសម្ដីរបស់អ្នកជំនាញដ៏សំខាន់ទាក់ទងទៅនឹងស-២១ ទាក់ទងទៅនឹងអ្នកដែលរស់រានមានជីវិត

ពី ស-២១។

ខ្ញុំមិននិយាយពីអ្នកដែលជនរស់រានមានជីវិតទេ ខ្ញុំនិយាយពីតួអង្គ ដោយរស់ពីរបបខ្មែរក្រហម។ ខ្ញុំឮលោកវេជ្ជបណ្ឌិត ឈឹម សុធារ៉ា ដែលជាវេជ្ជបណ្ឌិតជំនាញចិត្តសាស្ត្របាននិយាយនៅថ្ងៃទី២៥ សវនាការទី២៥ ២០០៩ ទាក់ទងទៅនឹងការសូមអភ័យទោសពីជនជាប់ចោទ។ ទាក់ទងទៅនឹការផ្សះផ្សា ស្នាមដំបៅឡើងវិញ។ នេះជាផ្នែកមួយនៃការផ្សះផ្សាដំបៅៗ ឲ្យជាសះស្បើយឡើងវិញ សម្រាប់ជនរងគ្រោះ ហើយខ្ញុំក៏បានគិតទៅដល់សេចក្តីថ្លែង។ ប្រសិនបើយើងនៅចាំ វាជាសេចក្តីថ្លែងមួយដ៏គួរឲ្យចាប់អារម្មណ៍របស់ រ៉ូបឺត ហាមីលៗ នៅថ្ងៃ១៧ ខែសីហា ឆ្នាំ២០០៩ ដែលខ្ញុំពេញចិត្តណាស់ដែល ឌុច សារភាពពិរុទ្ធភាពរបស់គាត់ ខ្ញុំគឺថាខឹងលើសពីអ្វីៗដែលខ្ញុំអាចនិយាយបានទៅទៀត។ ប៉ុន្តែ ខ្ញុំគោរពនិងទទួលស្គាល់នូវការទទួលយកពិរុទ្ធភាពពីសំណាក់ជនជាប់ចោទ។

ខ្ញុំសង្ឃឹមថា អង្គជំនុំជម្រះសម្រាប់ជាគតិរបស់ខ្លួន និងយកចំណុចទាំងអស់នេះទៅពិចារណា។ ដែលសម្រាប់ខ្ញុំ វាហាក់បីដូចជាថា មានសារសំខាន់ដូចគ្នា ដូចដែលអ្វីដែលបានដាក់ជូនពីដើមដំបូងតាមរយៈការិយាល័យសហព្រះរាជអាជ្ញាកាលពីម្សិលមិញ។

ខ្ញុំមានឯកសារដែលខ្ញុំ នៅពេលខ្ញុំចេញពីតុលាការទៅ ហើយការិយាល័យសហព្រះរាជអាជ្ញាទើបតែប្រឌិតថ្មីៗនូវប្រវត្តិសាស្ត្រនៃកម្ពុជាប្រជាធិបតេយ្យ ហើយបានលើកឡើងមកប្រាប់វាថា ថារបបនេះជារបបផ្តាច់ការ ដោយសារ ប្រសិនបើស-២១ ជាគុកមួយធំជាងគេបំផុតនៅក្នុងប្រទេសកម្ពុជា ប្រសិនបើស-២១ ទាក់ទងទៅនឹងតួនាទីដែលគាត់ទទួលបាននៅស-២១ ដូចដែលលោកបានលើកឡើងអ៊ីចឹងថា បើមេដឹកនាំ ឬប្រធានស-២១ មានអំណាចឯករាជ្យនូវការធ្វើសេចក្តីសម្រេចផ្សេងៗ ដែលមានន័យថា គាត់ខ្លួនឯងត្រូវសម្រេចអ្វីៗទាំងអស់ ដែលគាត់អាចឲ្យយោបល់ទៅមេៗរបស់គាត់។ ហើយដូចដែលលោកស្រី ជា លាង បានលើកឡើងថា គាត់ធ្វើឲ្យមេៗរបស់គាត់មានភាពភ័យខ្លាច អ៊ីចឹងមានន័យថា វាមិនមែនជាភាពផ្តាច់ការទេ វាជាការចូលរួម។ ដូច្នេះស-២១ គឺជាកន្លែងដ៏ពិសេសមួយ។ ដូច្នេះគាត់ជ្រើសរើស មានន័យថា គាត់អត់មានមេទេ និងអ្វីដែលបានលើកឡើង នេះគឺអ្វីដែលបានលើកឡើងមកជូនយើងទាំងអស់គ្នាកាលពីម្សិលមិញ។

ពាក្យសម្តីដែលបានប្រើប្រាស់ ដែលខ្ញុំបានដកស្រង់មក សូមលើកឡើងម្តងមួយពាក្យៗ។

អ្នកជំនាញ វ៉ាអូល ម៉ាកចេនណា ដែលបានមកបំភ្លឺជូនអង្គជំនុំជម្រះ ដើម្បីពន្យល់ជូនអំពីខ្សែសង្វាក់នៃការបញ្ជា ហើយយើងមានការអបអរសាទរយ៉ាងខ្លាំងចំពោះលោក រ៉ូចេនណា ចំពោះការ

ថ្លែងដ៏ច្បាស់ៗរបស់គាត់ ការបញ្ជាក់ដ៏ច្បាស់ៗរបស់គាត់។ ហើយខ្ញុំបានអានរបាយការណ៍របស់សហព្រះរាជអាជ្ញាដែលថា សេចក្តីថ្លែងនេះ គឺថាមិនមានអក្សរយោងទេ អក្សរយោងចុងទំព័រទេ មិនគួរណាទទួលយកជាបានការនោះទេ។ អ៊ីចឹង ថាតើពាក្យថា ផ្តាច់ការ នៅកន្លែងលេខចុងទំព័រហ្នឹង វាមានយ៉ាងម៉េច? យើងមិនអាចទទួលយកបានទេ ដែលថាជនណាម្នាក់អាចនិយាយសម្រាប់តែខ្លួនឯង ដោយមិនទទួលយកពាក្យសម្តីរបស់អ្នកជំនាញ ការយល់ដឹងរបស់អ្នកជំនាញ ។

[១១:០៩:៥៣]

លោកស្រីចៅក្រម ខាតវ៉ាយថ៍ នឹងដឹងហើយនូវអ្វីដែលខ្ញុំលើកឡើងនេះ គឺខ្ញុំលើកឡើងនូវចំណុចជាក់លាក់ ពេលដែលលោក លោកស្រី និយាយតាមទស្សនៈរបស់លោកស្រី រូចេនណា គាត់មកផ្តល់សក្ខីកម្មនៅទីនេះ គឺថាគាត់ប្រកាន់យកពាក្យរបស់គាត់។ ប្រសិនណាចង់ជំទាស់តវ៉ាជាមួយនឹងគាត់ ខ្ញុំសូមអញ្ជើញតវ៉ាជំទាស់ជាមួយនឹងគាត់ចុះ ខ្ញុំជូនពរ ។ គាត់បានពន្យល់មកដល់យើងទាំងអស់ យើងទាំងអស់គ្នា អំពីខ្សែសង្វាក់នៃការបញ្ជានៅក្នុងប្រតិបត្តិការរបស់កម្ពុជាប្រជាធិបតេយ្យ ហើយជាពិសេសគាត់ពន្យល់ទៅលើការវិភាគ ដែលទាក់ទងទៅនឹងការខ្សែសង្វាក់នៃការបញ្ជានេះ ដែលត្រូវគេបានដឹងឮថា ចំណុចនេះក៏មាននៅក្នុងឯកសារ នៅក្នុងសារណាចុងក្រោយរបស់គូបដិបក្ខរបស់ខ្ញុំ គឺថាលោកមិនបានទំនាក់ទំនង-- ឌុច មិនបានទំនាក់ទំនងទៀងទាត់ជាមួយ-- ឌុច មានការទំនាក់ទំនងទៀងទាត់ជាមួយនឹងមេរបស់គាត់ ជាមួយនឹងថ្នាក់លើ។ ខ្ញុំសូមលើកឡើងទៅលើកថាខណ្ឌ១.៤១ នៃសេចក្តីសារណាចុងក្រោយរបស់សហព្រះរាជអាជ្ញា មុននឹងដាក់ជូននូវដីកាសន្និដ្ឋានបញ្ជូនរឿងទៅជម្រះ ។

តាមអ្វីដែលខ្ញុំដឹងគឺថា វាផ្ទុយទៅនឹងអ្វីដែលយើងបានលើកពីម្សិលមិញ។ ការងារទាក់ទងរវាង ឌុច និង សុន សេន ជាពិសេសគឺថាជិតដិតនឹងគ្នាណាស់រវាង ឌុច និង សុន សេន។ អ្នកទាំងពីរនេះ គឺថានិយាយអំពីបញ្ហាសន្តិសុខតាមតេលេហ្វូនរាល់ថ្ងៃ។ ឥឡូវ ខ្ញុំសូមជំទាស់តវ៉ា ឌុច រាយការណ៍ជូន សុន សេន នូវលម្អិតអំពីៗ យុទ្ធសាស្ត្រ ហើយនិងគោលដៅនៃការចាប់ខ្លួន ហើយទទួលបញ្ជាពី សុន សេន។ សុន សេន បានមកមើលស-២១ ជាញឹកញាប់ ដើម្បីផ្តល់ការបណ្តុះបណ្តាល។ ជាពិសេសផ្តល់ការបណ្តុះបណ្តាលទៅលើមន្ត្រីរបស់ស-២១ ដើម្បីទទួលយកព័ត៌មានទាក់ទងទៅនឹងទីភ្នាក់ងារទាំងឡាយដូចជា សេ.អ៊ី.អា និងភ្នាក់ងារយួន។

[១១:១២:៣៤]

សុន សេន ក៏បានទៅផ្ទះរបស់ ឌុច។ ក្រោយពី សុន សេន ចាកចេញពីភ្នំពេញទៅ ដើម្បីទៅធ្វើ

សង្គ្រាមនៅឯព្រំដែន ឌុច បានរាយការណ៍ចូលទៅមេថ្មីរបស់គាត់គឺ នួន ជា។ យ៉ាងហោចណាស់ក៏ពីរបីថ្ងៃម្តងដែរ ដោយផ្ទាល់ ឬក៏ចូនកាលរាយការណ៍តាមរយៈនីរសារ។ ឌុច បានឆ្លើយតបទៅនឹង នួន ជា តាមរយៈ ឆ្លើយទៅ នួន ជា វិញតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ។

ឌុច គឺជាកូនចៅរបស់ សុន សេន យើងមិនចៀសវាង ឬបំភ្លេចឃ្លានេះបានទេថា តើន័យច្បាស់លាស់ហ្នឹង វាមានន័យដូចម្តេចដែរ? ខ្ញុំសូមលើកនូវសំណួរ ឌុច ទៅវិញ តើលោកអាចបញ្ជាក់បានទេថា ឌុច ពិតជាកូនចៅរបស់ សុន សេន ដែលថា សុន សេន-- នេះជាការត្រឹមត្រូវទាំងស្រុងហើយ ហើយខ្ញុំមិនដែលមានន័យថា ឌុច ដែលជាជនជាប់ចោទ សប្បាយរីករាយទៅនឹងអំណាចឯករាជ្យ គាត់ធ្វើតាមបញ្ជារបស់ សុន សេន ហើយឆ្លើយតបសំណួររបស់លោក គឺថាជាការពិតណាស់ នេះមិនមែនជាប្រតិបត្តិការមួយដែលអាចមានប្រតិបត្តិការតែម្នាក់បានទេ វាជាប្រតិបត្តិមួយទាក់ទង-- ត្រូវតែមានការចូលរួមពីថ្នាក់លើ ថ្នាក់កំពូលបំផុត ។

ខ្ញុំសូមលើកឡើងនូវចំណុចនេះនៅក្នុង-- ខ្ញុំបានលើកឡើងចំណុចនេះនៅក្នុងដំណើរការនីតិវិធីនៃប្រតិបត្តិការរបស់ស-២១។ ស-២១ ចាត់ចែងឡើងដោយ សុន សេន។ ស-២១ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈអចិន្ត្រៃយ៍ ប្រសិនបើមានលក្ខណៈពិសេសណាមួយដែលយើងបានដឹងគឺថា កម្មាភិបាលរបស់ខ្មែរក្រហមទាំងអស់ដែលបានបញ្ជូនទៅទូទាំងប្រទេស បញ្ជូនមក ស-២១ ពីទូទាំងប្រទេសហើយ វាជាចំណុចមួយដែលមានលក្ខណៈលំបាកស្មុគស្មាញនៅក្នុងចំណុចនេះ ។

សហព្រះរាជអាជ្ញាបានទទួលស្គាល់ថា តែប្រាំបីភាគរយទេនៅស-២១ អ្នកស្លាប់តែ ប្រាំបីភាគរយទេ នៅស-២១ ដែលជាសមាជិកនៃរបបនោះ មានន័យថាជាកម្មាភិបាលរបស់របបនោះ ដែលភាគច្រើន ដែលធ្លាប់បានសម្លាប់មនុស្សច្រើនជាង ឌុច សម្លាប់ទៅទៀត។ ចំណុចនេះគឺថាយើងបានដឹងហើយ ទាក់ទងទៅនឹងកម្រិតនៃភាពស្មុគស្មាញទៅលើបញ្ហាស-១២ នេះ។ ហើយគ្រប់គ្រួសារទាំងអស់ដែលជាជនរងគ្រោះ ដូចដែល អស់លោក លោកស្រី បានដឹងហើយថា ស-២១ នេះគឺជាអតីត--ជាពិសេសសមាជិកដែលជាអតីតអ្នកឆ្មាំរបស់ស-២១ យើងមិនអាចគេចចេញពីចំណុចទាំងអស់នេះបានទេ ហើយនៅក្នុងពេលនេះ គឺថាយើងមិនអាចមានអីយកមកដោះសាបានទេ ចំពោះលទ្ធផលដែលយើងបានរកឃើញពីអ្នកទាំងអស់ ដែលអ្នកទាំងនេះបានប្រព្រឹត្តឡើង។ អ្នកទាំងអស់នោះ គឺថាជាផ្នែកមួយនៃម៉ាស៊ីនកាប់សម្លាប់នៅស-២១។ ស-២១ ដែលគណៈអចិន្ត្រៃយ៍ជាអ្នកគ្រប់គ្រងដោយផ្ទាល់នេះតែម្តង។

[១១:១៧:១៣]

កាលពីម្សិលមិញ សហព្រះរាជអាជ្ញាហាក់មានចេតនានិយាយថា ឌុច គឺជាមនុស្សមួយដែលមានអំណាចបំផុត។ គំនិតដែលបានលើកឡើងចេញពីសេចក្តីថ្លែងនោះគឺថា ប្រសិនបើមានសាក្សីដែលមិនអាចផ្តល់សក្ខីកម្មទាក់ទងទៅនឹងការអះអាងថា នៅពេល ឌុច ពិធីរៀបអាពាហ៍ពិពាហ៍របស់ ឌុច គឺថាមានអ្នកធំៗច្រើន ហើយសហព្រះរាជអាជ្ញា មិនដែលទទួលស្គាល់ទៅលើចំណុចហ្នឹងទេគឺថា តែងតែនិយាយផ្ទុយទៅលើចំណុចៗដែលមាននៅក្នុងសំណុំរឿង ហើយកាលពីម្សិលមិញនេះ សហព្រះរាជអាជ្ញាបានលើកឡើងថា ឌុច គឺមនុស្សស្នាក់ៀកស្នាជាមួយនឹង សុន សេន ហើយគាត់មានឋានៈនៅក្នុងហ្នឹង ហើយគាត់ព្យាយាមគឺថាធ្វើឲ្យខ្លួនគាត់មានភាពជិតស្និទ្ធជាមួយនឹងអ្នកដែលមានអំណាចបំផុត។

ខ្ញុំសូមចូលទៅដល់ការទទួលយកនូវភ័ស្តុតាងដែលសរសេរនៅក្នុងសៀវភៅដែលយើងមិនអាចមើលរំលងទេ សៀវភៅនេះសរសេរដោយលោក ហ្វីលីព សត ទាក់ទងទៅនឹងគេហៅថា ណាយម៉ែរ គឺ“សុបិនអាក្រក់”។ ដូចដែលយើងបានដឹងហើយនៅពេលស្វែងយល់អំពីតួនាទីរបស់បុគ្គលម្នាល់នៅក្នុងឋានានុក្រមមួយនោះ នៅពេលដែលយើងសម្រេចទៅលើឋានន្តរសក្តិ ដើម្បីឲ្យយល់ថា តើអាជ្ញាធរនោះប្រព្រឹត្តមកលើមនុស្សទាំងអស់នោះនៅក្នុងពេលមានវិបត្តិនោះ ប្រព្រឹត្តដោយរបៀបណា?

យើងនិយាយអំពីវិបត្តិនៅពេលដែលទីក្រុងភ្នំពេញគឺថា មិនមានមនុស្សសោះ។ ជាពិសេសទៅនឹងមនុស្សទាក់ទងទៅនឹងអ្នកដែលមានអំណាច នៅពេលដែលប្រជាពលរដ្ឋត្រូវបានជម្លៀសចេញពីទីក្រុង។ ខ្ញុំសូមដក់ស្រង់នូវសម្តីចេញពីសៀវភៅរបស់លោក ហ្វលីព សត។ គឺនៅថ្ងៃទី៦ មករា សុន សេន បានចាកចេញពីទីក្រុងភ្នំពេញទៅ គាត់បានដើរទៅកាន់ព្រំដែនវៀតណាម ដើម្បីទៅកាន់ខេត្តកំពង់ចាម ហើយដើម្បីចូលទៅជួបជាមួយនឹងកងពលដែលនៅសេសសល់ពីរណសិរ្សបូព៌ា ប៉ុល ពត, នួន ជា , និង ខៀវ សំផន ត្រូវការពារទៅដោយអង្គរក្សដែលជិះរថយន្តហ្ស៊ីបពីរបី បានទៅដល់ពោធិ៍សាត់នៅថ្ងៃទី៧ មករា។ ប៉ុល ពត គាត់ជិះឡាន ឆេវ៉ាឡូត ឡាននោះវាខ្ពស់ វាស្រួលជាងសហការីរបស់គាត់ ដែលជិះម៉ែស្សឺដេស។

អៀង សារី បានចាកចេញទៅកាន់បាត់ដំបងតាមរយៈរថភ្លើងពិសេស ដោយមានដឹកនាំទៅជាមួយនូវបុគ្គលិកសំខាន់ពីក្រសួងការបរទេស និងឯកសារមួយចំនួន គឺថាបានចាកចេញយ៉ាងតក់ក្រហល់នៅពេលល្ងាច។ នៅប្រាំបីព្រឹក យើងបានឃើញ ម៉ុក ជិះឡានហ្ស៊ីប បានបើកឡានមកជិតនឹងក្រសួងការបរទេស ហើយប៉ុន្មានម៉ោងក្រោយមក ដូចដែលយើងបានទទួល គឺថាវត្តមានរបស់គាត់មិនមានន័យ

អីទេ គឺថាមិនមានសារសំខាន់អីទេ។ រហូតដល់ថ្ងៃត្រង់ថ្ងៃច័ន្ទ ដែលមេដឹកនាំទាំងអស់របស់កម្ពុជាប្រជាធិបតេយ្យបានចាកចេញទៅឆ្ងាយ បោះបង់ចោលទីក្រុង ដើម្បីទុកតាមយថាកម្ម។ ប្រជាពលរដ្ឋ ទាហានក៏បានចាកចេញភ្លាមៗដែរ ដើម្បីការពារខ្លួន។ តើ ឌុច នៅឯណាកាលនុំង?

នេះនៅលើទំព័រទី៣៩៨ ទាក់ទងទៅនឹងបញ្ហាសន្តិសុខសម្រាប់ សីហនុ គឺជាគោលការណ៍មួយដែល នួន ជា បានលើកឡើងប៉ុន្មានខែមុននោះថា បើយើងបាត់បង់សមាជិកខ្លះ ប៉ុន្តែយើងនៅតែមានមេដឹកនាំ យើងនៅតែឈ្នះបានឡើងវិញ។ ឌុច នៅឯណាកាលហ្នឹង?

នៅចុងទំព័រ៣៩៩ ប៉ុល ពត, នួន ជា, ម៉ុក, អៀង សារី និង សុន សេន គ្មានអ្នកណាបានទទួលបានព័ត៌មានឲ្យគ្រប់គ្រាន់ ហើយចុងបញ្ចប់សូម្បីតែអង្គភាពសម្ងាត់របស់មន្ទីរទួលស្លែងបន្តធ្វើការងារដ៏សាហាវព្រៃផ្សៃ ស្ទើរតែយឺតពេលទៅហើយ។ គ្មានអ្នកណាអាចកត់សម្គាល់ ឌុច បានទេ។ អ្នកទោសនៅតែទទួលការសួរចម្លើយនៅថ្ងៃទី០៥ ខែមករា តាមបញ្ជារបស់ នួន ជា ដើម្បីឲ្យសម្លាប់នូវអ្នកឃុំខ្លួនដែលនៅសេសសល់ គាត់បានគោរពតាមបញ្ជានោះ។ ប៉ុន្តែ មិនមានពេលគ្រប់គ្រាន់ ដើម្បីកម្ចាត់ចោលនូវឯកសារទាំងអស់ទេ។

លោកប្រធាន លោក លោកស្រីចៅក្រម ជាទីគោរព, ប្រសិនបើអង្គជំនុំជម្រះព្យាយាមស្វែងយល់នូវជំហររបស់ ឌុច នៅក្នុងឋានានុក្រមរបស់កម្ពុជាប្រជាធិបតេយ្យ សូមយោងទៅរកហេតុការណ៍ប្រវត្តិសាស្ត្រ។ លោក លោកស្រីនឹងចងចាំថា ឌុច បានចាកចេញនៅថ្ងៃនោះ គឺចាកចេញដោយថ្មើរជើងមិនមានអ្វីទៅជាមួយទេ គឺខ្លួនទទេ។ នៅក្នុងរបបនេះ ឌុច ត្រូវបានគេប្រគល់ឲ្យនូវតំណែងមួយ និងការងារ ដែលមេគាត់ជាអ្នកផ្តល់ឲ្យ ។

[១១:២៤:០៩]

នៅក្នុងដំណើរការនីតិវិធី លោក លោកស្រីចៅក្រមបានជ្រាបនូវពាក្យពេចន៍ ដែលបានសម្តែងឡើងដោយលោកបណ្ឌិត ក្រេក អេតឆេសាន់ គឺជាពាក្យថ្មីដែលមិនមានការយោងទៅរកសៀវភៅណាមួយពីមុននោះទេ គឺជាស្នាដៃផ្ទាល់របស់គាត់នោះឯង។ បន្ទាប់ពីការដាក់ជូននូវរបាយការណ៍របស់គាត់ លោក ក្រេក អេតឆេសាន់ គឺថា បានពិភាក្សាជាមួយសហព្រះរាជអាជ្ញា ហើយយើងពិនិត្យឃើញថាយើងមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងណាស់ យើងជួបឃើញនូវអត្ថបទថ្មីដែលអង្គជំនុំជម្រះបានស្តាប់ឮម្សិលមិញហើយ ថាគឺពាក្យដែលតាមពាក្យ ឌុច ដែលនិយាយថា ឌុច ជាមនុស្សល្អិតល្អន់ ហ្មត់ចត់ ម៉ឺងម៉ាត់ គឺជាអ្នកបង្កើតនូវស្ថានភាពភ័យខ្លាចដល់របបកម្ពុជាប្រជាធិបតេយ្យ។ បើដូច្នោះមែន គឺជាការពិត

ដែលឬទេ តើគាត់ជាអ្នកថ្នាក់លើដែរឬទេ? តើថ្នាក់លើនោះមានការភ័យខ្លាចដោយការគាត់ដែរឬទេ?

ដូច្នេះ ខ្ញុំសូមយោងទៅសក្ខីកម្មដែលផ្តល់ឡើងដោយលោក ដេវីដ ឆេនដ័ល័រ។ នៅទំព័រ១៣៦ ចម្លើយសារភាព គឺវាមានកម្រិត គឺទំនងជាការពារគណៈអចិន្ត្រៃយ៍ ឬក៏មជ្ឈិមទល់នឹងខ្លាំង ហើយក៏មិនបានព្យាយាមយល់ពីស្ថានភាពទេ មាន ឌុច, ប៊ុន, ចាន់ ហើយនិងអ្នកក្រោមបញ្ជារបស់គាត់មួយចំនួនទៀត។ គឺជាអ្នកអនុវត្តតាមដោយឥតមានការកែប្រែ គឺផ្អែកទៅលើរឿងហេតុការណ៍ ផ្អែកទៅតាមថ្នាក់លើ មេរបស់គេ ដែលទំនងទៀតថា ជាការងារដ៏ល្អរបស់គេផងដែរ ដែលថាជាគំនិតមួយ ដើម្បីធ្វើយ៉ាងដើម្បីបម្រើមេរបស់ខ្លួន ។

យើងបានលើកឡើងវិញនូវចំណុចទាំងនេះ ហើយខ្ញុំជឿថា អង្គជំនុំជម្រះជ្រាបហើយថា ឌុច បាននិយាយថា មេរបស់ខ្ញុំចាត់ទុកខ្ញុំថា ជាមនុស្សស្មោះត្រង់ គឺដូចជាឆ្កែបែកហ្វេ មួយដូច្នោះឯង។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ លោក ក្រេក អេតឆេសាន់ នៅក្នុងរបាយការណ៍របស់គាត់ គឺថាមុនអាចនឹងចំណុចមួយនៅក្នុងរបាយការណ៍របស់គាត់នោះ គណៈអចិន្ត្រៃយ៍ជាអ្នកត្រួតត្រាលើបណ្តាញទំនាក់ទំនងទាំងអស់របស់របបនៃកម្ពុជាប្រជាធិបតេយ្យ ហើយនិងទំនាក់ទំនងទាំងអស់ត្រូវបានត្រួតត្រាដោយ គឺតាមរយៈខ្សែបណ្តោយ គឺគ្មានខ្សែទទឹងនោះទេ។ នៅក្នុងឯកសារវត្ថុតាងដែលនិយាយអំពីបង្ហាញដោយលិខិតសារទូរលេខ ដែលបានបញ្ជូនពីភូមិតំបន់ផ្សេងៗទាក់ទងទៅនឹងកិច្ចការមួយចំនួនទៅគណៈអចិន្ត្រៃយ៍ ។

ឌុច ក៏បានជម្រាបអង្គជំនុំជម្រះផងដែរថា គាត់មិនបានទទួលការទុកចិត្តមួយរយភាគរយ ហើយគាត់-- ចំពោះសារទូរលេខ ដែលបញ្ជូនពីតំបន់ផ្សេងៗ គាត់មិនបានដឹងច្បាស់ទេ មិនឆ្លងគាត់ទេ គឺជាប្រព័ន្ធទាំងស្រុង ដែលដំណើរការទូទាំងប្រទេសនៅកាលនោះ នៅគ្រប់ភូមិភាគ ហើយបញ្ជូនដោយត្រង់ទៅមជ្ឈិមបក្ស គណៈមជ្ឈិម គឺមិនឆ្លងតាមគាត់ទេ គឺគេជាអ្នកត្រួតត្រា ។

សហព្រះរាជអាជ្ញាក៏បានពន្យល់ថា នៅក្នុងប្រព័ន្ធនោះ ឌុច ពេញចិត្តនូវការធ្វើសេចក្តីសម្រេចដែលស្វ័យតមួយទៅវិញ។

[១១:២៩:១៥]

ខ្ញុំសូមអនុញ្ញាតត្រឡប់ទៅរកចំណុចមួយដែលខ្ញុំបានយោងទៅខាងដើម ដែលទាក់ទងទៅនឹងករណី ស៊្វី ម៉េត។ គាត់បានបញ្ជាក់ថា យ៉ាងហោចណាស់នៅក្នុងកងពលមួយនៅក្នុងភូមិភាគ ឌុច អាចនឹងមានទំនាក់ទំនងតាមខ្សែទទឹង ដែលលោក ក្រេក អេតឆេសាន់ នៅក្នុងរបាយការណ៍និយាយថា

ទំនាក់ទំនងខ្សែទទឹងត្រូវចាត់ទុកជា អំពើ ឬក៏ការធ្វើដោយក្បត់មេ។ គឺបើ ឌុច គាត់ធ្វើបែបនេះដោយខ្លួនឯង តើគាត់មានលទ្ធភាពដើម្បីអនុវត្តនូវការទាក់ទងខ្សែទទឹងជាមួយ ស៊ូ ម៉េត បានដោយរបៀបណា?

សហមេធាវីរបស់ខ្ញុំបានជម្រាបជូនអង្គជំនុំជម្រះពីម្សិលមិញ អំពីហេតុការណ៍ដែលកើតឡើងក្នុងឆ្នាំ១៩៨៦ ខ្ញុំមិនលើកឡើងវិញនោះទេ។ ឥឡូវនេះខ្ញុំសូមជម្រាបថា តាមបរិបទនេះ គឺថាការសម្រេច ឬក៏អនុវត្តអ្វីនៅកាលនោះ គឺជាការសម្ងាត់។ តាមការសម្រេចបែបនោះ នៅរបបបដិវត្តន៍ គឺមិនខុសគ្នាទេនៅកម្ពុជា និងករណីផ្សេងទៀតនោះ។

លោកសាក្សី ចេនណា បាននិយាយអំពីករណីសហភាពសូវៀត ហើយនិងបដិវត្តន៍នៅទីនោះ។ បដិវត្តន៍បានបម្រើ គឺបម្រើសេចក្តីប្រាថ្នា ដែលថាបដិវត្តន៍ទាំងអស់ គឺត្រូវជំរុញឡើងដោយឧត្តមគតិមួយចំនួនដែលថាគេត្រូវធ្វើយ៉ាងកម្ចាត់នូវខ្មាំង ឬក៏អ្នកប្រឆាំងបដិវត្តន៍។ ហើយនៅទីនេះក៏ដូចកន្លែងផ្សេងទៀតដែរ ជានយោបាយមួយនៃការបំបាត់ជាប្រព័ន្ធនូវខ្មាំង ហើយនិងនយោបាយកម្ទេចខ្មាំងត្រូវបានអនុវត្ត ហើយក៏គេបានកំណត់សញ្ញាខ្មាំងដែរ។ ក្រោយមកក៏បានបញ្ជូនអ្នកដែលគេយល់ថា ជាខ្មាំងទៅស-២១ ហើយកន្លែងគេបានបញ្ជូនទៅមន្ទីរសន្តិសុខផ្សេងៗទៀត ហើយគេសួរចម្លើយ ដើម្បីធ្វើយ៉ាងណាឲ្យមានយុត្តិកម្មសម្រាប់ការចាប់ខ្លួន បន្ទាប់មកគេក៏កម្ទេចអ្នកទាំងនោះចោល។ នេះ គឺជាការងារមួយដ៏ធ្ងន់ធ្ងររបស់ ឌុច ដូចដែលលោក ដេវីដ ឆេនដ៍ល័រ បានជម្រាបដូច្នោះដែរ។

ខ្ញុំជឿជាក់ថា ជនជាប់ចោទបានធ្វើការនៅស-២១ ជាអ្នកគ្រប់គ្រងដំណើរការដើម្បីធានាថា អ្នកដែលបញ្ជូនមកដល់ស-២១ ហើយនឹងត្រូវសម្លាប់។ នេះគឺជាបេសកម្មមួយដែលគេផ្តល់ឲ្យគាត់។ មេរបស់គាត់មិនដែលបានប្រកាសដក ឬក៏លុប បេសកម្មរបស់គាត់នោះទេ។ គាត់មិនដែលបានស្វែងរកការឯកភាពពីមេដើម្បីអនុវត្តបញ្ជានៅក្នុងប្រព័ន្ធមួយដែលគាត់មិនមានការជម្រើសខុសពីអ្វីពីការបញ្ជា។ គាត់មិនអាចនឹងសម្រេចថា អ្នកណាត្រូវសម្លាប់ ឬក៏អ្នកណាត្រូវទុកនោះទេ។

[១១:៣៣:១៧]

កាលណាចូលដល់ស-២១ ហើយនោះ អ្នកគ្រប់គ្នាដែលត្រូវបានគេបញ្ជូនមកស-២១ ត្រូវតែបានសម្លាប់ដោយមិនគិតអំពីស្ថានភាពអ្វីទេ។ នេះជាអំពើមួយ ការងារមួយដ៏អាក្រក់បំផុតដែលគេប្រគល់ឲ្យ ឌុច ធ្វើ។ ការងារដ៏អាក្រក់នេះ គឺជាផ្នែកមួយនៃគោលនយោបាយ ដែល ឌុច ត្រូវតែទទួលពីអ្នក ដែលខ្ពស់ជាងគាត់។ ដូចដែលយើងបានចងក្រងនូវប្រវត្តិសាស្ត្រ ដោយមិនត្រូវប្រើពាក្យណាដែលឆ្ងាយហ្នឹង ដែល

បញ្ជាក់ថា ឌុច នៅក្នុងខ្សែសង្វាក់នៃការបញ្ជានោះ គឺថាវាមានលទ្ធភាពណាមួយ ដើម្បីនឹងជ្រើសរើស សម្រេចដោយឯករាជ្យ ថាអ្នកណាត្រូវសម្លាប់ ឬក៏បញ្ជាឱ្យមានការចាប់ខ្លួន។ ប៉ុន្តែ យើងខ្ញុំនឹងជម្រាប ជូនចំណុចនេះឡើងវិញនូវពេលមួយ ដែលយើងនិយាយទៅដល់ការមិនពិតនោះ ដែលយើងមិនទាន់បាន ឮនៅឡើយ ទាក់ទងពីការងាររបស់ ឌុច ។

ខ្ញុំនឹងដកស្រង់សេចក្តីរបស់លោក ក្រេក អេតធេសាន់ គឺថាការបោសសម្អាតនៅក្នុងជួរបក្ស គឺ ទូទាំងប្រទេស ហើយមានគ្រប់ទីកន្លែង។ នៅក្នុងទំព័រ២១ ការបោសសម្អាតកើតឡើងម្តងហើយម្តង ទៀតនៅក្នុងមន្ទីរសន្តិសុខនានានៅក្នុងជួរបក្សកម្មាភិបាលដូចគ្នានោះ ហើយមានមរណភាព ១២.៣៨៣ នាក់។ ប៉ុន្តែ បើសរុបនៃរបបនោះ គឺថា១.៧លាននាក់ឯណោះ ដែលត្រូវតែមានអ្នកទទួលខុសត្រូវអំពី បញ្ហានេះ ដែលថាមេដឹកនាំជាន់ខ្ពស់ជាអ្នកទទួលខុសត្រូវចំពោះការបាត់បង់ជីវិតទាំងនោះ។

[១១:៣៥:២៩]

ឥឡូវនេះ ខ្ញុំសូមដកស្រង់អត្ថបទទង់បដិវត្តន៍ខែឧសភា ឆ្នាំ១៩៧៦ ដែលគេបានកំណត់អំពីគោល នយោបាយមួយ នេះជាពាក្យរបស់ ក្រេក អេចធេសាន់ ដែលគាត់បានបញ្ជាក់។ ជាពិសេសយើងសង្កត់ ធ្ងន់ ជាពិសេសដើម្បីរកខ្មាំង ហើយដើម្បីកំណត់អត្តសញ្ញាណ។ យើងអាចនឹងកម្ទេចខ្មាំងបាន ឲ្យបាន ច្រើនជាង៨៩ភាគរយ ដែលបានបង្កប់នៅខាងក្នុង ត្រូវតែពិនិត្យឲ្យបានជាដាច់ខាតទូទាំងប្រទេស។ តំបន់ នីមួយៗ ត្រូវតែពិនិត្យឲ្យបានហ្មត់ចត់ ស្រុកឃុំនីមួយៗត្រូវតែពិនិត្យពិច័យ សហករណ៍នីមួយៗត្រូវតែ ពិនិត្យផ្ទៀងផ្ទាត់ឲ្យបានហ្មត់ចត់។ យោធា មន្ទីរផ្សេងៗត្រូវតែពិនិត្យនៅក្នុងន័យនេះ។ ចំណុចទាំងអស់ នេះ គឺនៅក្នុងសេចក្តីដកស្រង់ ជាសេចក្តីដកស្រង់ផ្ទាល់អំពីទស្សនាវដ្តីទង់បដិវត្តន៍ គឺជាការងារស្នាដៃ របស់ប៉ុល ពត។ បន្ទាប់មកយើងមានចំណុចនេះ ដោយយើងចាត់ទុកថា ជាការសំខាន់ គឺជាការប្រយុទ្ធ នឹងខ្មាំងផ្ទៃក្នុង ដែលជាការងារសំខាន់ទាំងអស់របស់យើង។

ដូច្នេះ គ្រប់ជាន់ថ្នាក់នៃបក្សត្រូវតែដើរតួដោយសំខាន់ ដើម្បីជួយកំណត់ខ្មាំង ហើយនិងអ្នកណា ដែលអាចនឹងរាយការណ៍ពីខ្មាំង ហើយនិងកម្ទេចៗម្តងហើយម្តងទៀត ដោយមិនបង្អង់ដៃ។ ដូច្នេះកម្លាំង បក្សរបស់យើងនឹងបរិសុទ្ធ ហើយនិងការដឹកនាំរបស់យើងគ្រប់ជាន់ថ្នាក់បក្សនោះ គឺមិនមានការភ័យ ខ្លាចអ្វីទេ នឹងក្លាយទៅជាបក្សដ៏បរិសុទ្ធ។

ផ្អែកទៅលើខ្លឹមសារនេះ ថាតើអ្វីជាការងារជាក់ស្តែងរបស់ ឌុច នៅស-២១ ដើម្បីនឹងអនុវត្ត ការងាររបស់គាត់នោះ។ លោក លោកស្រីចៅក្រម គឺថាអាចនឹងពិនិត្យឃើញករណីមួយចំនួនហើយ

គឺថាជាករណីពិសេសមួយដែលប្រព័ន្ធដែលរៀបរាប់ដោយខ្លួនឯង ដូចជាឯកសារដែលមាននៅសំណុំរឿងនោះឯង។ ឯកសារទាំងអស់នោះ គឺបាននិយាយយ៉ាងច្បាស់ដោយខ្លួនឯងថា អង្គជំនុំជម្រះពិនិត្យមើលហើយ គឺថាសាក្សី ហើយនិងភ័ស្តុតាងក៏បានបង្ហាញនៅទីនោះស្រាប់ ដូចជាសៀវភៅកំណត់ដៃអ្នកសួរចម្លើយ បញ្ជីស្ថិតិនៃការងារនៅក្នុងស-២១ មនោគមវិជ្ជានយោបាយ ហើយនិងអង្គការចាត់តាំង។ ខ្ញុំនឹងជូន ERN លេខ000070445, 744500200751 គឺថាសហព្រះរាជអាជ្ញាបានយោងទៅរកឯកសារសំខាន់នេះ គឺជាសៀវភៅណែនាំពីការធ្វើទារុណកម្ម។

[១១:៣៩:២៨]

សូមចងចាំចំណុចមួយដែលខ្ញុំបានសួរទៅសាក្សីឈ្មោះ ប្រាក់ ខន ដែលអង្គជំនុំជម្រះជ្រាបហើយ គឺថាដែលយើងមានការទុកចិត្តលើចម្លើយរបស់គាត់ សក្ខីកម្មរបស់គាត់។ ខ្ញុំបានសួរទៅគាត់អំពីអ្វីៗដែលបានកត់ត្រាទុកនៅក្នុងឯកសារ។ ខ្ញុំបានសួរសំណួរទៅគាត់ដូចតទៅនេះ ៖ លោកសាក្សី ខ្ញុំចង់សួរលោកនៅសំណួរមួយចំនួនផ្អែកទៅលើឯកសារនានា ដែលមាន ដែលនៅក្នុងកំណត់ត្រាឯកសាររឿងក្តីដែលចាត់ទុកថា ជាសៀវភៅកំណត់ដៃអ្នកសួរចម្លើយ ហើយខ្ញុំបានជម្រាបអង្គជំនុំជម្រះថា គេអះអាងថា សៀវភៅហ្នឹងត្រូវបានចងក្រងឡើងនៅក្នុងការបណ្តុះបណ្តាល ដែល ឌុច ជាអ្នកផ្តល់ការបណ្តុះបណ្តាលនោះ។ នេះគឺជាការងារដែលមជ្ឈិមគេស្វែងរកខ្លាំងដែលគផ្ទេរអំណាចហ្នឹង មកឲ្យ ឌុច ធ្វើ ហើយឌុច ជាអ្នកធ្វើការងារ ហើយសៀវភៅនេះ យើងអាចរកឃើញថា តើគាត់បាននិយាយអ្វីខ្លះទៅអ្នកសួរចម្លើយ។ នេះមិនមែនជាភ័ស្តុតាងទេ នេះគឺជាឯកសារមួយ ជាសៀវភៅ ជាឯកសារ។ ខ្ញុំក៏បានសួរសំណួរទៅ ប្រាក់ ខន ទៀត។ មានជំពូកមួយដែលមានចំណងជើងថា ការបង្រៀនរបស់ ឌុច នៅក្នុងវគ្គសិក្សាអប់រំមួយ។ លោក រ៉ូ បាននិយាយថា (សូមអភ័យទោស) នេះគឺជាចំណងជើងដែលយើងដាក់ឲ្យទេនៅក្នុងអត្ថបទបារាំង នៅក្នុងទំព័រទី៩ នៃឯកសារនោះ។

និយាយបញ្ជីសតិ ខ្ញុំបានសួរទៅសាក្សីប្រាក់ ខន នេះខ្ញុំអានទៅ ខ្ញុំឃើញថាបែបនេះ លោកសាក្សីសូមលោកស្តាប់ដោយប្រុងប្រយ័ត្ន។ អង្គការបានណែនាំឲ្យយើង ឲ្យសួរចម្លើយឲ្យបានល្អ ឲ្យបានដាច់ខាត ហើយត្រូវតែគោរពការណែនាំ ហើយបើសិនយើងដាក់ទម្ងន់ពេកទៅលើការធ្វើទារុណកម្ម ឬក៏ត្រូវគោរពតាមនយោបាយ ។ បើការធ្វើហួសហេតុពេក គឺផ្ទុយអំពីការណែនាំ បើសិនជាក្នុងករណីខ្លះ យើងមិនប្រែរបៀបនយោបាយទេ។

ហួសពីនោះ នៅក្នុងឯកសារដដែលនេះដែរ ចំណងជើងនិយាយថា គោលបំណងនៃការកែលម្អ

ការងារ មានបីចំណុចនៅកន្លែងនោះ។ ទីមួយ ប្រើនយោបាយជាមូលដ្ឋាន។ ទីពីរ គោរពតាមការប្រៀបធៀបនូវចម្លើយឲ្យបានលម្អិតមុននឹងអនុវត្តការធ្វើទារុណកម្ម។ ទីបី គោរពជាដាច់ខាតនូវវិន័យអង្គការក្នុងពេលសួរចម្លើយ។ ហើយខ្ញុំបានបន្ថែមតទៅទៀតថា ខ្ញុំនឹងសួរទៅទៀត គឺឥឡូវនេះ ខ្ញុំចូលទៅដល់ទំព័រដប់បីនៃបារាំង កថាខណ្ឌទីបី គឺថាបញ្ហាទាក់ទងអំពីការសួរចម្លើយ ឯកសារនោះ គឺបញ្ជាក់ថា វិធានការសម្រាប់យើងសួរចម្លើយនោះគឺវាមានពីរ៖

ក) សួររឿងនយោបាយ។ យើងត្រូវតែអនុវត្តការងារនេះឲ្យបានគ្រប់ពេលវេលា។

ខ) ទណ្ឌកម្ម គឺជាបញ្ហាបន្ទាប់បន្សំ។ ចំណុចនេះ គឺបានបង្ហាញដូចខាងក្រោមនេះ បទពិសោធន៍បានពីអតីតកាលអំពីអ្នកសួរចម្លើយរបស់យើងនោះ ជាទូទៅ ច្រើនតែសង្កត់ទៅលើការធ្វើទារុណកម្ម នេះមានន័យថា វាមានសារសំខាន់ក្នុងការធ្វើទារុណកម្ម ជាជាងការឃោសនា នេះគឺជាវិធីសាស្ត្រដែលខុសទេ ហើយយើងត្រូវតែច្បាស់នៅក្នុងការប្តេជ្ញា ឬក៏ការសម្រេចចិត្តរបស់យើង ដើម្បីចៀសវាង។ ហើយខ្ញុំសួរទៅ ប្រាក់ ខន ថាលោកសាក្សី តើលោកនៅចាំទេ តើលោកនៅចាំទេ តើលោកនឹកឃើញទេ នៅពេលវគ្គបណ្តុះបណ្តាលនោះ គាត់បានឮអ្វីខ្លះ? លោក ប្រាក់ ខន បានឆ្លើយថា “បាទ, ខ្ញុំបានឮអ្វីដែលឌុច បាននិយាយនៅក្នុងវគ្គបណ្តុះបណ្តាល វគ្គរៀនសូត្រនោះ បាទ, ខ្ញុំពិតជាបានឮទ្រឹស្តីនេះមែន”។

[១១:៤៥:២៩]

តើគាត់ជាមនុស្សឃោរឃៅដែលបានរៀបរាប់អំពីពីអ្វីៗប្រាប់លោកម្សិលមិញទេ? តើគាត់ជាមនុស្សដែលបាននិយាយ ហើយគាត់បានប្រើពាក្យថា ត្រូវតែសង្កត់ធ្ងន់លើរឿងនយោបាយ ហើយប្រើទារុណកម្មជាដំណោះស្រាយចុងក្រោយតែប៉ុណ្ណោះ។ តើមែនទេ? ហើយខ្ញុំបានសួរសំណួររបស់ខ្ញុំទៅសាក្សី ប្រាក់ ខន ដដែលនៅក្នុងឯកសារដដែល ហើយលោកមានភារកិច្ចមួយចំនួនទាក់ទងទៅនឹងការសួរចម្លើយខ្លាំង នៅក្នុងការសរសេរកត់ត្រានោះ អនុញ្ញាតឲ្យគេនិយាយ ឬក៏សរសេរអ្នកមិនត្រូវរំខានគេទេ យើងមិនត្រូវកែអ្វីដែលបានឃើញ បានឮភ្លាមទេ តាមគោលបំណងរបស់យើង។ លើកលែងតែចំណុចដែលបក្សឯកភាព យើងត្រូវតែសួរ ពីព្រោះបក្សបានយល់ពីស្ថានភាពហ្នឹងច្បាស់ហើយ ថាប្រសិនបើយើងសង្កត់ធ្ងន់ឈ្មោះហើយនិងសកម្មភាព គេនឹងប្រឌិតអ្វីដែលយើងប៉ុនប៉ងឲ្យគេធ្វើ ចង់ធ្វើ។ បើយើងធ្វើបែបនោះ យើងនឹងប្រើកម្លាំងបក្សបដិវត្តន៍ គេនឹងធ្វើឲ្យស្ថានភាពបដិវត្តន៍ហ្នឹងភាន់ច្រឡំ ហើយឲ្យធ្វើឲ្យខ្លឹមសារចម្លើយសារភាពហ្នឹងមិនច្បាស់លាស់ ហើយគ្មានតម្លៃ។ ហើយតទៅខាងក្រោមទៀតនៅក្នុងឯកសារដដែលនោះ ចំណុចសំខាន់គឺថា យើងមិនត្រូវចុចឈ្មោះ ឆ្លើយដាក់ឈ្មោះទេ យើងមិនត្រូវ

បង្ខំឲ្យគេនិយាយទៅតាមគោលបំណងដែលយើងចង់បានទេ ហើយខ្ញុំសួរ ប្រាក់ ខន ត្រង់ចំណុចនេះ។

តើលោកនឹកឃើញអ្វីទេ តាមចំណុចនេះ គាត់បានឆ្លើយថា “បាទ, គឺជាការបង្រៀនរបស់យើង ពីព្រោះថាមានអ្នកខ្លះបង្ខំឲ្យអ្នកទោស សរសេរ ឬក៏និយាយច្រើនពេក ហើយចម្លើយសារភាព គឺគ្មានន័យ ហើយគេបានពន្យល់របៀបសរសេរធ្វើម៉េចឲ្យចម្លើយសារភាពហ្នឹងងាយយល់ ហើយស្រួលយល់បាន។ នេះគឺជាការបង្រៀនដែល ឌុច បានបង្រៀនជាបន្តបន្ទាប់ក្នុងប្រព័ន្ធអប់រំនោះ។

ដូច្នេះ អង្គជំនុំជម្រះជ្រាបហើយថា គាត់បានជម្រាបចំពោះអង្គជំនុំជម្រះដែលជាតុលាការអន្តរ-ជាតិ គឺថាឯកសារហ្នឹង គឺវាមានជាភ័ស្តុតាង ជាឯកសារ ហើយគាត់បានមើលឯកសារហ្នឹង ហើយផ្អែកលើឯកសារទាំងនេះ យើងបានព្យាយាមបង្ហាញនូវការពិតនោះ។ បានន័យថា យើងមិនចង់បាននូវអ្វីដែលយើងជឿជាក់ដោយខ្លួនឯង ក្នុងការឈានទៅដល់ការចង់បាននូវការពិតនោះឡើយ។ ការពិតវាទាមទារឲ្យយើងនិយាយអំពីរបបនៃភាពភ័យខ្លាចនេះផងដែរ។ ថាតើយើងអាចដាក់បន្ទុក ឌុច ចំពោះមន្ទីរស-២១ ដោយប្រព័ន្ធការភ័យខ្លាចនេះយ៉ាងម៉េច? ខ្ញុំចង់លើកឡើងចំណុចមួយចំនួន ដែលខ្ញុំនិយាយអំពី វ៉ាអ៊ូល ចេនណា ដែលគាត់បាននិយាយទៅលើរបបនោះ។

ចំពោះបុគ្គលដែលតតាំងថា ខ្លួនមិនមែនជាខ្មាំង។ ថាតើយើងត្រូវការពន្យល់ចំណុចនេះឲ្យបានច្រើនជាងនេះ ឬក៏យ៉ាងម៉េច? ដោយសារតែនៅសម័យនោះ គេមានប្រើពាក្យគេយ៉ាងជាក់លាក់។ នៅពេលនេះ ខ្ញុំលើកឡើងអំពីលោក ក្រេក អេតឆេសាន់ ដែលបានផ្តល់នៅថ្ងៃទី២៨ ខែឧសភា។ ខ្ញុំជឿថា របបកម្ពុជាប្រជាធិបតេយ្យ គឺប្រើប្រព័ន្ធការភិតភ័យនេះ ជាប្រព័ន្ធនៃការគ្រប់គ្រងរបបរបស់គេ។

នៅពេលនេះ ខ្ញុំសូមលើលអំពីបណ្ឌិត ដេវីដ ឆេនដ័ល័រ ដែលគាត់សរសេរនៅក្នុងសៀវភៅរបស់គាត់ ទំព័រ៦៦ ជាភាសាបារាំង។ គាត់បានលើកឡើងថា របបនោះ គឺជារបបនៃការភិតភ័យ ដែលប្រើប្រព័ន្ធភិតភ័យនេះ រហូតដល់ចុងបញ្ចប់នៃរបបនេះ។ ដូច្នេះលោក លោកស្រីនៅចាំ នៅពេលដែលខ្ញុំសួរលោក ដេវីដ ឆេនដ័ល័រ នៅពេលដែលគាត់មកផ្តល់សក្ខីកម្មនៅទីនេះ ទាក់ទងទៅនឹងការភ័យខ្លាច យើងហៅថា ផារ៉ាណូយ៉ា។ គាត់បានលើកឡើង ផារ៉ាណូយ៉ា ឬក៏ការភ័យខ្លាចនេះ គឺកើតឡើងមិនត្រឹមចាប់ពីស-២១នោះទេ គឺវាមិនកើតឡើងតែក្នុងមន្ទីរនេះទេ គឺវាកើតឡើងទូទាំងជួរបក្ស ហើយប្រព័ន្ធនៃការភ័យខ្លាចនេះ គឺវាបន្តនៅមានរហូត ហើយប្រសិនបើមានខ្មាំងនោះ គឺថាវានៅតែមានការភិតភ័យរហូត។ ខ្ញុំសូមលើកឡើងអំពីសម្តីរបស់លោកស្រី ស៊ីរ៉ូនី ហ្កៀលបូ ដែលនិយាយនៅថ្ងៃទីខែកញ្ញា ឆ្នាំ២០០៩។ ប្រព័ន្ធនៃការភ័យបែកសត្វត្រដេរវិច គឺវាកើតឡើងទៅលើបុគ្គលដែលនៅក្នុងរបបនោះ ។

លោកស្រីបានរៀបរាប់ថា "ការពីម្សិលមិញយើងនិយាយអំពីការវិភាគចិត្តសាស្ត្ររបស់ជនជាប់ចោទ ហើយយើងក៏អាចនិយាយថា វាបន្តិចម្តងៗនៅក្នុងប្រទេសទាំងអស់គឺដើរចូលផ្លូងតែមួយ។ ពួកគេធ្វើការងារក្នុងលក្ខណៈជាបុគ្គលតែមួយតែប៉ុណ្ណោះ។ ដូច្នេះ ការផ្លាស់ប្តូរផ្នែកចិត្តសាស្ត្រគឺវាអាស្រ័យទៅលើចិត្តសាស្ត្ររបស់បុគ្គលទៅតាមការផ្លាស់ប្តូរនៃរបប។ បានន័យថា នៅពេលដែលវាមានរបបនោះវាដើរទៅជាផ្លូងមួយ។ ដូច្នេះ បុគ្គលទាំងឡាយគឺជា បង្កើតទៅជាមហាជន ហើយការណាមានប្រព័ន្ធការភ័យខ្លាចនោះ គឺពួកគេនឹងទទួលរង។ ដូច្នេះ ហើយត្រូវតែមានប្រព័ន្ធចិត្តសាស្ត្រមួយដើម្បីបង្កើតឲ្យដើរទៅជាផ្លូងមួយ ហើយវាធ្វើឲ្យមានបញ្ហាចិត្តសាស្ត្រទាក់ទងទៅនឹងការមិនទទួលយកការពិតចំពោះអង្គហេតុ និងការភ្លៀវភ្លាហួសហេតុទៅលើចំណុចទាំងអស់នេះ។ ហើយការដែលយើងចង់បំបាត់ទៅលើប្រព័ន្ធនៃការភិតភ័យនេះ ទាល់តែមានចំណុចដែលខ្ញុំបានលើកឡើងនេះ។

ដូច្នេះបរិយាកាសនៃការភិតភ័យ វាកើតមាន ហើយសាក្សីជាច្រើនគឺបានមកផ្តល់សក្ខីកម្មនៅក្នុងតុលាការនេះ ហើយបាននិយាយរៀបរាប់អំពីមន្ទីរស-២១។

ហើយខ្ញុំសូមលើកឡើងនូវសម្តីដកស្រង់ជាច្រើន គឺនៅនេះគឺនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩។ ជាការពិតជនជាប់ចោទបាននិយាយ គាត់មានការភ័យខ្លាចនៅគ្រប់ករណីទាំងអស់។ នរកគឺជាទីបញ្ចប់នៅជីវិតរបស់ខ្ញុំ។ ហើយយើងចងចាំហើយនៅសម្តីរបស់លោកបណ្ឌិត កាស៊ុន បូណាត ដែលគាត់បានលើកឡើងនូវសម្តីរបស់គាត់នៅពេលនោះថា "នៅក្នុងករណី វន វ៉េត ដែលត្រូវបានគេសម្លាប់។ ជនជាប់ចោទ គាត់គ្មានជម្រើសអ្វីឡើយ ប៉ុន្តែត្រូវតែសម្លាប់ ដើម្បីធ្វើយ៉ាងណាឲ្យជនជាប់ចោទមានជីវិតរស់។ ដូច្នេះហើយទើបគាត់សម្រេចសម្លាប់ចោល។ ហើយបណ្ឌិត គាត់បានលើកឡើងបន្តទៀតថា ជនជាប់ចោទ គឺជាសមាជិកបក្សមួយរូប ហើយប្រសិនបើបុគ្គលម្នាក់ជាសមាជិកមជ្ឈិមបក្សនោះ គឺគាត់ជាគំរូរបស់បក្ស។ ប៉ុន្តែជនជាប់ចោទ គាត់គ្រាន់ជាឧបករណ៍មួយរបស់បក្សតែប៉ុណ្ណោះ ហើយគាត់ត្រូវដំណើរការងាររបស់គាត់ដូចម៉ាស៊ីន គឺម៉ាស៊ីនមួយដោយគោរពតាមបញ្ជារបស់មេ និងការណែនាំរបស់មេ។ គាត់ទទួលបញ្ជារបស់មេ ដោយគ្មានការតវ៉ាបានឡើយ។

[១១:៥៤:១៤]

ដូច្នេះហើយជនរូបនេះ គាត់ស្ថិតនៅក្នុងស្ថានភាពមួយដែលគាត់ត្រូវតែសម្លាប់គេ បើមិនដូច្នេះគេនឹងសម្លាប់គាត់។

ខ្ញុំសូមលើកឡើងសម្តីរបស់លោក ដេវីដ ឆេនដ៍ល័រ សម្តីនេះគឺនៅថ្ងៃទី៦ សីហា ឆ្នាំ២០០៩ លើក

ឡើងអំពី ឌុច។ គាត់បានលើកឡើងថា ជនរូបនេះមានការភិតភ័យតាមពិតទៅ ដោយសារតែរបបនោះគឺវាមានលក្ខណៈទំនើងទៅៗ។ ដូច្នេះហើយ ប្រសិនបើវៀតណាមមិនចូលលុកលុយនៅក្នុងប្រទេសកម្ពុជាទេ សុន សេន នឹងជួបនូវវាសនារបស់គាត់ចុងក្រោយ។ ដូចដែលយើងបានឃើញហើយ នៅក្នុងខ្សែជីវិតរបស់គាត់ របស់ សុន សេន នៅតំណាក់កាលចុងក្រោយ"។ ហើយលោក ឆេនដ៍ល័រ បានបន្ថែមថា នៅក្នុងរបបប្រាំមួយខែចុងក្រោយនៃរបបនោះ គឺវាបង្ហាញយ៉ាងច្បាប់ថា ឯកសារបានបង្ហាញថាជនជាប់ចោទមានការសោកស្តាយនឹងការងាររបស់គាត់ ហើយជាការពិតគឺជនរូបនេះមានការភ័យខ្លាច។ ដូច្នេះវាស៊ីសង្វាក់គ្នានូវអ្វីដែលបានកើតឡើងនៅក្នុងរបបនោះ ។

មុនពេលយើងឈប់សម្រាក ខ្ញុំសូមលើកឡើងអំពីគោលការណ៍រក្សាសម្ងាត់ ដែលវាដើរត្រសងគ្នាជាមួយនឹងប្រព័ន្ធនៃការភ័យខ្លាច។ លោក ដេវីដ ឆេនដ៍ល័រ លើកឡើងថា គោលការណ៍នៃការសម្ងាត់គឺជាមនោគមវិជ្ជា និងជាកិច្ចការនៃរបបនេះ។ ហើយ នួន ជា បាននិយាយបញ្ជាក់យ៉ាងច្បាស់នៅពេលដែលគាត់មានមន្ត្រីប្រតិភូមកពីដាណឺម៉ាក មកទស្សនកិច្ចនៅឆ្នាំ១៩៧៨។ នួន ជា បានលើកឡើងថាខ្ញុំមិនចងចាំពាក្យសម្តីរបស់គាត់នោះទេ។ នួន ជា បានលើកឡើងថា គោលការណ៍នៃការរក្សាសម្ងាត់ គឺជាចំណុចដ៏សំខាន់ គឺជាបេះដូងដ៏សំខាន់របស់កម្ពុជាប្រជាធិបតេយ្យ។ ហើយនាពេលនេះ យើងឮថាមានការលើកឡើងថា គណៈកម្មាធិការអចិន្ត្រៃយ៍គឺមិនអនុវត្តការងាររបស់ខ្លួនដោយរក្សា និងធ្វើឲ្យស្របទៅលើគោលការណ៍នៃរក្សាសម្ងាត់។ ដូច្នេះហើយវាហាក់ដូចជាមិនត្រូវទៅលើចំណុចនេះ ។

លោក លោកស្រីចៅក្រមនឹងអាចមើលនៅក្នុងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា មាត្រា២ ដែលនិយាយអំពីបក្ខជន ហើយប្រសិនបើយើងអាចចោទប្រកាន់ ឌុច នោះ យើងមិនអាចចោទប្រកាន់គាត់ចំពោះការដែលគាត់អនុវត្តទៅតាមកាតព្វកិច្ចដែលមានចំពោះបក្ខជនគ្រប់ៗគ្នានោះឡើយ។ ដូច្នេះចំណុចនេះ យើងឃើញថា គេត្រូវរក្សានិងគោលការណ៍រក្សាការសម្ងាត់ដាច់ខាតនៅក្នុងបក្ស។ តើអស់លោកលោកស្រី ជឿទេថា ឌុច ប្រសិនបើ ឌុច គាត់មិនគោរពនោះ តើមានអ្វីកើតឡើង? ហើយប្រសិនបើ សុន សេន គាត់មិនគោរពនោះ តើមានអ្វីកើតឡើងនៅក្នុងរបបនោះ?

[១១:៥៨:១៧]

ខ្ញុំសូមនិយាយឡើងវិញអំពីបណ្ឌិត វ៉ាអ៊ូល ចេនណា ដែលគាត់និយាយថា បក្សកុម្មុយនីស្តកម្ពុជាចាប់ពីឆ្នាំ១៩៦៣ គឺធ្វើការនៅក្នុងភាពលាក់កំបាំង។ ហើយវាគឺជាការសម្ងាត់មួយដែលគេធ្វើការងារដោយកំបាំង ហើយវាជារបៀបនៃការគ្រប់គ្រងរបស់បក្ស។ ហើយបន្ទាប់ពីឆ្នាំ១៩៧៥ វិធីនៃគោល-

ការណ៍រក្សាការសម្ងាត់នេះក៏ត្រូវបានគេប្រើប្រាប់នៅក្នុងប្រទេសផងដែរ។ ដូច្នេះ វប្បធម៌នៃការរក្សាការសម្ងាត់នេះវាកើតមាននៅក្នុងមន្ទីរស-២១។ ប្រព័ន្ធសម្ងាត់ គឺធ្វើយ៉ាងណាកុំឲ្យគេដឹងពីអត្ថិភាពនៃមន្ទីរស-២១ លើកលែងតែសមាជិកគណៈអចិន្ត្រៃយ៍ និងមេរបស់ខ្លួនតែប៉ុណ្ណោះ។ ដូច្នេះទោះបីជាបុគ្គលណាក៏ដោយដែលបញ្ជូនទៅស-២១ ដោយកំហុសនោះ ពួកគេត្រូវតែសម្លាប់ចោល ហើយអ្វីដែលគាត់ធ្វើ គឺធ្វើឡើងតាមតែបញ្ជា ដែល ឌុច គាត់ទទួលបញ្ជាតាមថ្នាក់លើរបស់គាត់។ ដូច្នេះ ឌុច ត្រូវបានគេបង្គាប់ឲ្យធ្វើ ហើយអនុវត្តដាច់ខាត ហើយនិងរក្សាទៅតាមគោលការណ៍សម្ងាត់ និងឲ្យស្របទៅតាមមាត្រា២នៃលក្ខន្តិកៈ និងរដ្ឋធម្មនុញ្ញនៃរបបនោះផងដែរ។ ដែលគាត់ត្រូវអនុវត្តគ្រប់ពេលទាំងអស់ ។

លោក លោកស្រីចៅក្រមជាទីគោរព, ខ្ញុំគិតថានៅពេលនេះ យើងប្រហែលជាដល់ពេលឈប់សម្រាកនីតិវិធីយើងសិន ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ពេលត្រូវពិសារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះសាលាដំបូងប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយនិងសាមសិបនាទីរសៀលនេះ។ សូមអញ្ជើញភាគី និងសាធារណជនចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទៅកាន់កន្លែងសម្រាក ឬក៏ទៅមន្ទីរឃុំឃាំង និងឲ្យនាំគាត់មកកាន់សាលសវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយ និងសាមសិបនាទីជាកំណត់។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោយឈរ!

*[សវនាការសម្រាកពីម៉ោង១២:០១នាទី ដល់ម៉ោង ១៣:៣០នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ កិច្ចបន្តសូមអញ្ជើញមេធាវីការពារក្តីបន្តធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។

សូមអញ្ជើញ!

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណច្រើនលោកប្រធាន។ ខ្ញុំនឹងបន្តនូវសេចក្តីថ្លែងសន្និដ្ឋានបញ្ចប់របស់ខ្ញុំ ដែលខ្ញុំបានឈប់មុនពេលអាហារថ្ងៃត្រង់ ដែលខ្ញុំរៀបរាប់អំពីបរិបទទូទៅនៃបក្សកុម្មុយនីស្តកម្ពុជារបស់កម្ពុជាប្រជាធិបតេយ្យ ការភ័យខ្លាច ហើយនិងគោលនយោបាយរបស់របបនោះ។ យើងខ្ញុំនឹងនិយាយនៅចំណុចបន្តទៀត ហើយយើងក៏មិនត្រូវភ័យអំពីការគោរពបញ្ជារបស់ថ្នាក់លើ និងការគោរពវិន័យផងដែរ ដូចដែលមានចែងនៅក្នុងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា។ មាត្រា២នៃបក្សនេះ ចែងថាសមាជិកទាំងឡាយ ត្រូវគោរពទៅលើគោលការណ៍វិន័យរបស់អង្គការ ដោយគ្មានលក្ខខណ្ឌ ហើយដោយមនសិការច្បាស់លាស់របស់ខ្លួន។ ដូចដែលលោក លោកស្រីបានចងចាំហើយ យើងនិយាយអំពីចំណុចហ្នឹងយ៉ាងច្រើន ដែលអ្នកជំនាញក៏បានលើកឡើងផងដែរ។

លោក លោកស្រីក៏ចាំផងដែរនៅសម្តីរបស់លោក ដេវីដ ឆេនដ៍ល័រ ដែលបានថ្លែងផ្តល់សក្ខីកម្មនៅចំពោះមុខសវនាការ ហើយក៏គាត់បានសរសេរបោះពុម្ពផ្សាយនៅក្នុងសៀវភៅរបស់គាត់ ទំព័រ១៧១ផងដែរ ដែលចាប់ផ្តើមពីកថាខណ្ឌទី២ នៅទំព័រ១៧។ វាមិនងាយស្រួលក្នុងការវិនិច្ឆ័យទៅលើអ្នកទទួលធ្វើទារុណកម្ម និងអ្នកដែលធ្វើការកាប់សម្លាប់នោះទេ។ វាពិបាក ដោយសារតែគាត់គោរពទៅលើគោលវិន័យរបស់គេ ហើយវាជាពាក្យសម្តីដែលលើកឡើងដោយ ដេវីដ ឆេនដ៍ល័រ។

លោក ដេវីដ ឆេនដ៍ល័រ បានបន្តលើកឡើងទៀតថា បើសិនយើងមិនឆ្លងកាត់នូវរបបនេះទេ គ្មាននរណាម្នាក់ក្នុងចំណោមយើងទាំងអស់គ្នា អាចនិយាយថាតើអ្នកទាំងអស់នោះ គាត់សម្តែងនិងប្រព្រឹត្តយ៉ាងដូចម្តេច? ប្រសិនបើអ្នកទាំងអស់នោះ ឬក៏យើងជាអ្នកធ្វើទារុណកម្ម ឬសួរចម្លើយ ។

យើងក៏បាននិយាយទៅលើចំណុចទាំងអស់នេះ ខ្ញុំសូមដកស្រង់សម្តីរបស់លោកបណ្ឌិត ក្រេក អេចឆេសាន់ ផងដែរ ដែលខ្ញុំបានដេញដោលសួរទៅលើចំណុចហ្នឹង ។ សំណួររបស់ខ្ញុំសួរដូចតទៅៈ ដោយសារតែយើងនិយាយអំពីចំណុចហ្នឹង យើងនិយាយអំពីជម្រើស និងការគោរពបញ្ជាថ្នាក់លើ ថាតើខ្ញុំយល់ខុសដែរឬទេនៅពេលដែលខ្ញុំនិយាយថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើបុគ្គលណាម្នាក់មិនគោរពបញ្ជានោះ បុគ្គលនោះនឹងប្រឈមប្រថាននឹងការកាប់សម្លាប់ ឬក៏នឹងការសម្លាប់ចោល។ ចម្លើយគាត់បានឆ្លើយថា ជាការពិត គឺដូច្នេះមែន។

ការគោរពបញ្ជារបស់ថ្នាក់លើ គឺជាចំណុចមួយដែលយើងត្រូវពិចារណា ហើយចំណុចមួយទៀតថា ហេតុអ្វីបានជា ឌុច គាត់មិនរត់គេចចេញពីរបបហ្នឹង? ជាការពិតសហចៅក្រមស៊ើបអង្កេត បានសួរ

សំណួរហ្នឹងទៅកាន់ជនរូបនេះ។ ជាការពិត គេសួរសំណួរទៅកាន់ ឌុច ហេតុអ្វីបានជាគាត់មិនរត់គេចខ្លួនពីរបបហ្នឹង? ហើយគាត់ឆ្លើយដោយផ្អែកទៅលើមនសិការរបស់គាត់ ហើយបានលើកឡើងថា កុយ ធួន មានអំណាចជាងខ្ញុំទៅទៀត ហើយគាត់នោះមិនអាចរត់គេចចេញពីរបបនេះផង។ វន វ៉េត មានអំណាចជាងខ្ញុំ ហើយគាត់ក៏មិនអាចរត់ចេញពីរបបនផងដែរ។ យើងបានបន្តលើកឡើងបន្តសម្តីរបស់មេដឹកនាំជាន់ខ្ពស់ៗផ្សេងៗទៀត ដែលបានលើកឡើងនូវចំណុចនេះ ដែលត្រូវបានគេឆ្លើយដាក់ជាអ្នកទោសនៅស-២១។ ពួកគេទាំងអស់គ្នាមិនមានលទ្ធភាពរត់គេចចេញពីរបបនេះឡើយ។

យើងទាំងអស់គ្នា បានដឹងហើយទៅលើចំណុចទាំងអស់នេះថា កូនគាត់អាចនឹងមិនគោរពបញ្ជារបស់ឪពុកម្តាយបាន ប៉ុន្តែនៅពេលដែលយើងគិតទៅលើករណីនេះ ទោះបីជានៅជិតព្រំដែនវៀតណាមក៏ដោយ ក៏វាពិបាកក្នុងការរត់គេចខ្លួន ហើយនិងការមិនគោរពតាមបញ្ជា។ ឌុច មិនស្ថិតនៅជិតព្រំដែននោះទេ ហើយឌុច នៅតែនិយាយថា គាត់ត្រូវតែមានលិខិតដើរផ្លូវដើម្បីធ្វើដំណើរ ហើយយើងនិយាយអំពីមេដឹកនាំ ឬក៏មេមន្ទីរមួយនេះ។ ហេតុអ្វីចាំបាច់គាត់ត្រូវការលិខិតដើរផ្លូវ ដើម្បីចាកចេញពីភ្នំពេញ? នេះជាចំណុចដែលយើងត្រូវពិចារណា។

យើងត្រូវចាំនូវសម្តីរបស់លោក ហ្វីលីព សត ក្នុងទំព័រ៤៣០នៃសៀវភៅរបស់គាត់ មានតែមន្ត្រីរដ្ឋាភិបាលតែប៉ុណ្ណោះ ដែលអាចទទួលការអនុញ្ញាត ឬលិខិតដើរផ្លូវឲ្យចូលនៅនាយកដ្ឋាន ក្រសួងផ្សេងៗ។ លិខិតដើរផ្លូវ ទាមទារឲ្យមាន ដើម្បីធ្វើដំណើរពីស្រុកមួយទៅស្រុកមួយ រួមទាំងធ្វើដំណើរពីភ្នំពេញផងដែរ។ សូម្បី ប៉ុល ពត ក៏ត្រូវទទួលការត្រួតពិនិត្យផងដែរ នៅពេលដែលគាត់ដើរនៅតាមតំបន់ផ្សេងៗ។ ដូច្នេះហើយវាជាប្រព័ន្ធនៃការភ័យខ្លាច។ អ្នកជាមន្ត្រីកម្មាភិបាលរបស់របបនេះ ទាមទារឲ្យមានលិខិតដើរផ្លូវ។ ដូច្នេះចុះចំណែក ឌុច វិញ តើយ៉ាងម៉េចដែរ? នេះយើងឃើញហើយ ថាមានការលើកឡើងអំពីនៅក្នុងចម្លើយរបស់សហចៅក្រមស៊ើបអង្កេតផងដែរ ដែលគាត់បានធ្វើការស៊ើបអង្កេត។

នៅពេលដែលសួរសំណួរទៅកាន់អ្នកយាម នៅមន្ទីរស-២១ គាត់បានឆ្លើយអំពីឋានានុក្រមនៃរបបនោះ។ យើងមិនមានសេរីភាពដើរហើរដោយសេរីនោះទេ យើងត្រូវតែមានការប្រុងប្រយ័ត្នដោយសារការបំពារបំពានទៅលើវិន័យទាំងឡាយ វាអាចនាំឲ្យមានការដាក់ទោស។ ដូច្នេះហើយយើងជាអ្នកយាមធ្វើការងារឲ្យមានភាពរឹងមាំ និងហ្មត់ចត់ និងខំប្រឹងការងារនៅក្នុងបរិយាកាសនៃការភ័យខ្លាច ហើយយើងភ័យខ្លាចថា នៅថ្ងៃណាមួយ យើងនឹងស្លាប់ដូចអ្នកដទៃ។ ទាំងអស់នេះ គឺជាការងារដែលដាក់ជូនដោយមេផ្ទាល់របស់យើង ដូច្នេះហើយយើងខ្ញុំជាអ្នកយាមត្រូវតែអនុវត្តតាម ហើយគោរពតាមទៅ

តាមបញ្ជាទាំងអស់នោះ ។

[១៣:៤០:២១]

ដូច្នេះ យើងអាចប៊ានិយាយយ៉ាងម៉េច ដោយសារតែយើងឃើញហើយថា មេថ្នាក់លើគាត់ជាអ្នកចេញបញ្ជាទាំងអស់។ ទោះបីដែលខ្ញុំរត់ចេញគេចពីស-២១ ក៏ដោយ ក៏គេចាប់ខ្ញុំដែរ ដូចដែលឌុចបាននិយាយនោះ។ ដូច្នេះថាខ្ញុំគួររត់ទៅណា? រត់ទៅជំរំខ្មាំង? បើសិនជាខ្ញុំធ្វើដូច្នេះ គេក៏ចាប់ខ្ញុំដែរ ហើយប្រសិនបើគេចាប់ខ្ញុំ ឬក៏ខ្ញុំរត់គេចខ្លួន តើមានអ្វីកើតឡើងចំពោះគ្រួសារនិងកូនចៅរបស់ខ្ញុំ? លោក លោកស្រីចៅក្រម ក៏ពិតឃើញនៅក្នុងសេចក្ដីឆ្លើយតប និងចម្លើយឆ្លើយតបដែលយើងឃើញមាននៅក្នុងប្រតិចារឹក ដែលក្នុងនោះគូសបញ្ជាក់អំពីការដែលជនជាប់ចោទលើកឡើងថា ប្រសិនបើគាត់រត់គេចខ្លួន តើគាត់ធ្វើយ៉ាងម៉េច? ហើយវាមានអ្វីកើតឡើងចំពោះគ្រួសាររបស់គាត់? ហើយឲ្យខ្ញុំធ្វើយ៉ាងម៉េច? លោក លោកស្រីចៅក្រម ក៏ជ្រាបផងដែរនៅស-២១ គេបានកំណត់ថា ជាជនក្បត់ចំពោះអ្នកទោស ហើយបើសិនជាដូច្នេះមែន អ្នកជាគ្រួសាររបស់គាត់ក៏ត្រូវគេចាប់ខ្លួនដែរ ហើយ ឌុច គាត់បានដឹងទៅលើករណីទាំងអស់នេះ។

ចំណុចមួយទៀត ដែលខ្ញុំសូមលើកឡើងផងដែរ ដោយផ្ទាល់តែម្ដង ជាពិសេសគឺការពេញចិត្តពេញថ្លើមរបស់គាត់ក្នុងការងារ និងភាពក្លៀវក្លាទៅលើការងាររបស់ ឌុច។ ខ្ញុំសូមលើកឡើងសាជាថ្មីអំពីលក្ខន្តិកៈដែល ឌុច គាត់លើកឡើងថា គាត់ត្រូវគេបង្ខំឲ្យអានលក្ខន្តិកៈជារៀងរាល់ថ្ងៃ ហើយខ្ញុំក៏នៅចាំផងដែរនៅក្នុងវគ្គស្វ័យទិតៀន ដែលគេបានលើកឡើងអំពីលក្ខន្តិកៈទាំងអស់នេះ។ អនុលោមតាមមាត្រា៥ នៃលក្ខន្តិកៈ សមាជិកក៏ត្រូវតែមានការបង្កើតការកែច្នៃនិងមានភាពស្វយ័ត ហើយធ្វើការដោយហ្មត់ចត់ និងប្រឹងប្រែងធ្វើការងារ ហើយធ្វើឲ្យមានលក្ខណៈហ្មត់ចត់និងពិស្ដារ។ ដូច្នេះបានន័យថា បក្សបានកំណត់ឲ្យបុគ្គលម្នាក់ៗបង្ហាញអំពីភាពពេញចិត្ត ពេញថ្លើម និងការចូលចិត្តរបស់ខ្លួន ដូចដែលសហព្រះរាជអាជ្ញា បានចោទប្រកាន់ ឌុច ទៅលើចំណុចនៃភាពក្លៀវក្លា និងភាពពេញចិត្តនេះ។

លោក លោកស្រីចៅក្រម, ខ្ញុំបានឃើញទៅលើការការឃោសនាទាំងឡាយ ដែលយើងបានដឹងទាំងអស់គ្នា ដែលបុគ្គលទាំងឡាយត្រូវបានគេឃោសនាឲ្យធ្វើការតាមស្រែ តាមភូមិ ដោយគ្មានឈប់បង្ខំឲ្យធ្វើការងារទាំងឡាយ ហើយលោក លោកស្រីក៏បានដឹងដែរថា ឌុច គឺត្រូវបានគេឲ្យធ្វើការងារដែលជាការទាមទាររបស់មេថ្នាក់លើ។

នៅពេលដែល ដេវីដ ឆេនដ័ល័រ បានលើកឡើង យើងបានឃើញថា ជនជាប់ចោទគឺត្រូវបានគេ

ឲ្យធ្វើការងារទាំងឡាយឲ្យមានភាពពេញចិត្ត ពេញថ្លើម ដូចដែលគាត់បានលើកឡើងនៅថ្ងៃទី២៧ ខែឧសភា។ វាមានការលើកឡើងទៅលើចំណុចនេះថា បក្សកុម្មុយនីស្តកម្ពុជា បានដាក់អាទិភាពទីមួយ គឺការគោរពបទបញ្ជា និងការមានវិន័យត្រឹមត្រូវ ហើយត្រូវការអនុវត្តទៅតាមមាគ៌ាបក្សឲ្យបានរឹងមាំ ដូចដែលបានចែងនៅក្នុងគោលការណ៍វិន័យរបស់បក្ស។

ដូច្នេះ នៅតំបន់ទាំងឡាយ កម្មាភិបាលទាំងអស់ត្រូវតែប្រឹងប្រែងធ្វើការដោយគោរពទៅតាមមាគ៌ាបក្ស។ ដូច្នេះ គ្មានអ្វីលើកលែងចំពោះ ឌុច នោះទេ។ គាត់ជាកម្មាភិបាលមួយរូបដែលត្រូវអនុវត្តមាគ៌ាបក្សផងដែរ ហើយមិនមានអ្វីដែលជំរុញឲ្យ ឬក៏បង្ខំឲ្យសហព្រះរាជអាជ្ញាគាត់សន្និដ្ឋានថា ជនជាប់ចោទគួរតែធ្វើអំពើទាំងអស់នេះក្នុងរបៀបផ្សេង ហើយគាត់គួរតែអនុវត្តខុសពីមាគ៌ាបក្សទៅវិញ។ ប៉ុន្តែនេះជាចំណុចមួយ ជាចំណុចវិវាទដែលបានលើកឡើងពីខាងសហព្រះរាជអាជ្ញា ដែលគាត់លើកឡើងថាជនរូបនេះគឺជាអ្នកដែលគោរពទៅតាមមាគ៌ាបក្ស។ ដោយយើងឃើញហើយ វាជាគោលការណ៍មានចែងយ៉ាងច្បាស់នៅក្នុងលក្ខន្តិកៈបក្ស។

លោក លោកស្រីចៅក្រម ជាទីគោរព, ខ្ញុំសូមលើកឡើងអំពីចម្លើយដែលឆ្លើយទាក់ទងទៅនឹងមន្ទីរម-១៣ ដែលបានឆ្លើយនៅក្នុងថ្ងៃខែ-- នៅក្នុងឆ្នាំ២០០៩ នៅក្នុងសវនាការយើងនេះ។

យើងឃើញហើយថា យើងនិយាយអំពីជនបដិវត្តន៍ក្មេងៗដែលគាត់ជឿទៅលើមនោគមវិជ្ជា ហើយគាត់ត្រូវបំពេញការងាររបស់គាត់។ នេះគឺជាភារកិច្ចដែលពួកគេត្រូវទៅបំពេញការងារចាប់ខ្លួន ហើយទទួលខុសត្រូវ ហើយជនជាប់ចោទគឺគាត់ គេឲ្យគាត់បំពេញការងារទាំងអស់នេះ។ គាត់ថាគាត់មិនចង់សម្លាប់អ្នកទាំងអស់នោះទេ ដោយសារតែកូនក្មេងកសិករគឺជាវណ្ណៈកូនក្មេងដែលល្អ។ ប៉ុន្តែ គេប្រាប់ខ្ញុំថាឲ្យមនុស្សទាំងឡាយគោរពទៅតាមបញ្ជា។ ដូច្នេះហើយពួកគេត្រូវតែគោរពទៅលើបដិវត្តន៍ ហើយវាជាចំណុចដែលយើងត្រូវពិចារណា ថាតើបដិវត្តន៍យ៉ាងម៉េច? គេត្រូវតែកម្ទេចខ្មាំង។

លោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ បានផ្តល់ចម្លើយនៅក្នុងសវនាការរបស់យើង ហើយនិយាយអំពីការឈឺចាប់ក្នុងផ្លូវចិត្តរបស់ ឌុច នៅពេលដែលគាត់បានយល់ឃើញថា អ្វីដែលគេឲ្យជនរូបនេះធ្វើយើងអាចនឹកឃើញហើយ នូវអ្វីកើតឡើងនៅម-១៣។ នៅម-១៣ គាត់មិនមានការទំនាក់ទំនងជាមួយនឹងមជ្ឈិមបក្សនោះទេ។ នៅម-១៣ គាត់អាចដោះលែងអ្នកទោសប្រាំពីររូប ហើយវាជាចំនួនមួយតិចជាការពិតទៅ។ ប៉ុន្តែ នៅពេលដែលយើងសួរ ប៊ីហ្សូ ថាតើគាត់មិនអាចទទួលស្គាល់ថាយ៉ាងម៉េចទៅលើចំណុចនេះ?

ជាថ្មីម្តងទៀត ខ្ញុំសូមឲ្យលោក លោកស្រីចាប់អារម្មណ៍ថា តើគេចង់បានអ្វីខ្លះពីកម្មាភិបាលខ្មែរក្រហម? អ្នកជំនាញទាំងឡាយបានផ្តល់ចម្លើយជូនអង្គសវនាការអំពីការកម្ទេចនៃសតិអារម្មណ៍សួនតួ។ ខ្ញុំសូមឲ្យលោក លោកស្រីពិចារណាទៅលើពាក្យរបស់លោក ហ្វីលីព សត គឺគោលបំណងត្រូវតែកម្ទេចចោលនូវគំនិតសួនតួនិយម។ ខ្ញុំសូមដកស្រង់សម្តី "ភាពរឹងមាំ គឺធ្វើយ៉ាងណាយើងត្រូវរៀបចំការវាយលុកទៅលើបុគ្គល កម្ទេចទៅលើបុគ្គល ដែលគាត់ចាត់ទុកពួកគេថាជាអ្នកតំណាងនូវអ្វីៗដែលល្អ ប៉ុន្តែតាមពិតអ្នកទាំងអស់នោះ គឺជាអ្នកតំណាងនៃការស្រមើស្រមៃ ឬក៏ភាវអាក្រក់។ គំនិតសួនតួ គឺជាកម្មសិទ្ធិរបស់គហបតី ដែលគហបតីនេះបានកម្ទេចមហាប្រជាជន"។ ចំណុចនេះហើយដែលអាចឲ្យពួកគេពើងទ្រូង ងាកងើយក្បាល ហើយវាជាលទ្ធផលដែលកើតចេញពីចក្រពត្តិ និងពួកអាណានិគមន។

គោលបំណងចុងក្រោយរបស់ខ្មែរក្រហមគឺមិនចង់ឲ្យមានគំនិតសួនតួនេះឡើយ ហើយ ឌុច គាត់បានដើរតាមគំរូនេះ។ ដូច្នេះ នៅទីនេះ ខ្ញុំឃើញនូវចម្លើយថ្ងៃ២៨ ខែមេសា គឺជាការបង្ហាញឲ្យអំពីបុគ្គលរូបភាពម្នាក់ ដោយសារតែខ្ញុំយល់អំពីជនជាប់ចោទដែលបានជួបគាត់រយៈពេលមួយឆ្នាំជាងមកហើយ។ គាត់បានជម្រាបខ្ញុំថា យើងជាបុគ្គលមួយរូប យើងជាសមាជិកនៅក្នុងវណ្ណៈអធន យើងមិនត្រូវគិតអំពីគំនិតសួនតួនោះទេ យើងមិនត្រូវពាក់ព័ន្ធខ្លួនឯងចំពោះគំនិតសួនតួ ដោយយើងធ្វើការបំភ្លេចចោលនូវភាពលំបាកលំបិនរបស់មហាជន។ មិនថាអ្នកជាវណ្ណៈណាឡើយ អ្នកត្រូវតែរៀនឲ្យក្លាយខ្លួនជាវណ្ណៈអធន។ នេះហើយជាអ្វីដែលយើងរៀនសូត្រ។ នេះហើយជាអ្វីដែលគាត់អនុវត្តតាម។ ដូច្នេះហើយ ខ្ញុំមិនអាចទទួលស្គាល់ថា គាត់គឺជាបុគ្គលដែលគិតអំពីតែខ្លួនឯងនោះទេ គាត់បម្រើទៅតាមគោលការណ៍នេះ។ ខ្ញុំជឿគាត់ថា នៅពេលដែលគាត់និយាយថា គាត់មិនចង់ធ្វើប្រធាន ស-២១ ឡើយ។ ថាតើលោកសហព្រះរាជអាជ្ញាអាចសួរខ្លួនឯង-- ធ្លាប់សួរខ្លួនឯងដែរឬទេ? ប្រសិនបើលោក លោកស្រីជាបុគ្គលដូចជនជាប់ចោទរយៈពេលបីឆ្នាំជាង ដោយមិនមានការតម្លើងឋានៈ មិនតម្លើងជាប្រធានស-២១ តើលោកពន្យល់យ៉ាងម៉េច? ដោយសារតែចំណុចទាំងអស់នេះ មេរបស់គេយល់យ៉ាងច្បាស់ មេរបស់ជនរូបនេះយល់យ៉ាងច្បាស់ថា ជននេះគឺជាជនដែលបម្រើគេ ហើយជនជាប់ចោទ គាត់ដឹងហើយថាប្រសិនបើនរណាម្នាក់គាត់មិនគោរពទៅតាមបញ្ជារបស់ថ្នាក់លើ ហើយមិនធ្វើការងារទៅតាមថ្នាក់ នឹងបញ្ចប់ជីវិតរបស់គាត់ប្រហែលជាដូចនៅស-២១។ ដូច្នេះហើយគឺ ឌុច គាត់ព្យាយាមមិនចង់ធ្វើជាមេដែលមានអំណាចធំធេងនៅក្នុងរបបនេះទេ។ គាត់គ្រាន់តែចង់ធ្វើយ៉ាងណា ឲ្យគាត់រក្សាជីវិតគាត់តែប៉ុណ្ណោះ។

[១៣:៥៣:១៤]

នៅថ្ងៃណាមួយ បើបុគ្គលណាម្នាក់ គាត់ចោទជាសំណួរទៅកាន់ប្រជាជនរបស់ខ្ញុំ នៅថ្ងៃទី១៧ ឆ្នាំ១៩៧៩ តើលោកបានធ្វើអ្វីក្នុងរយៈពេលជាងដប់ឆ្នាំនេះ? គាត់បានឆ្លើយថា ខ្ញុំនៅសល់ជីវិតពីរបប នេះ។ ខ្ញុំជឿថា ប្រសិនបើយើងចង់ស្វែងយល់អំពីជនជាប់ចោទ ឌុច ថ្ងៃនេះ ហើយប្រសិនបើយើងចង់ ធ្វើការវិនិច្ឆ័យទៅលើរូបគាត់ យើងត្រូវស្វែងយល់អំពីគាត់។ យើងត្រូវយល់អំពីធាតុផ្សំ ឬក៏ព័ត៌មានទាំង ឡាយដែលពាក់ព័ន្ធទៅនឹងគាត់។ ចិត្តវិទូបានជម្រាបអំពីភាពគ្មានអារម្មណ៍អាណិតអាសូរ អលទ្ធភាព គិតថាបុគ្គលផ្សេងមានអារម្មណ៍ផ្សេងពីយើង។ នេះជាចម្លើយដែលលើកឡើងដោយ ស៊ីរ៉ូនី។ នេះវាកើត ឡើងទាក់ទងទៅនឹងបុគ្គល ដោយសារតែគាត់មិនស្គាល់ មិនដឹងច្បាស់អំពីអត្តសញ្ញាណរបស់គាត់។ ដោយសារតែ មនោគមវិជ្ជាដែលវាមានឥទ្ធិពលនៅក្នុងរបបខ្មែរក្រហម ដូច្នេះការដែលមិនមានភាព អាណិតអាសូរនេះ គឺមាននៅក្នុងអារម្មណ៍ ឌុច។ ដូច្នេះ គាត់កម្ទេចចោលរាល់អត្តសញ្ញាណបុគ្គលទាំង ឡាយដើម្បីជាប្រយោជន៍នៃការកំណត់ដើរតាមទៅលើអត្តសញ្ញាណសមូហភាព។ កាលពីម្សិលមិញជា ជនកុម្មុយនីស្ត ថ្ងៃនេះ ក្លាយជាអ្នកគោរពសាសនាគ្រីស្ត។ ប៉ុន្តែ នៅពេលជាមួយគ្នា គឺលោកស្រី ស៊ីរ៉ូនី បានចោទសួរសំណួរដូច្នេះថា យើងគួរកត់សម្គាល់ ភាពគ្មានអារម្មណ៍អាណិតគេនេះ គឺវាជាដាច់ វានឹង ក្លាយជាអារម្មណ៍ដាច់នៅចុងក្រោយ ដែលវាជាការវិវត្តន៍មួយ វាកើតមាននៅក្នុងគល់ ហើយយើងឃើញ វាជាការលើកឡើងនូវចំណុចចាប់ផ្តើមរបស់អ្នកជំនាញដែលគាត់បាននិយាយទៅលើចំណុចទាំងអស់នេះ។ នៅពេលដែលគាត់បានបញ្ចប់ទៅលើការពិចារណាទាំងអស់នោះ គឺគាត់បានបញ្ជាក់ទៅលើចំណុចទាំង ឡាយ។ ហើយនាពេលនេះ ខ្ញុំសូមពន្យល់នឹងលើកឡើងផ្តល់ជាព័ត៌មាន ជាការគំនិតគិតគួរសម្រាប់អស់ លោក លោកស្រី ភាគីទាំងឡាយ និងលោក លោកស្រីចៅក្រម។

[១៣:៥៦:០៩]

ខ្ញុំជាមនុស្សមួយរូបដែលរស់រាន ឬក៏មានភាពពេញវ័យដោយមានលក្ខណៈលំបាកដែលយើងត្រូវ គិតពិចារណាផង។ ហើយយើងត្រូវពិចារណាអំពី ឌុច ដែលគាត់ជាបុគ្គលមួយពិបាក ដែលគាត់ក៏ទទួល រងនូវការលុបចេញ បំបាត់ចេញពីសង្គមផងដែរ។ យើងដឹងហើយថា កាលណាអះអាងទាមទារឲ្យដាក់ សែសិបឆ្នាំ យើងមិនអាចនិយាយថា វាជាទោសស្រាលនោះទេ។ ទោសសែសិបឆ្នាំ ហើយគាត់អាយុ ហុកសិបជាងឆ្នាំហើយនោះ គឺវាហាក់ដូចជាគុកដាក់ពន្ធនាគារអស់មួយជីវិតដូច្នេះដែរ។ ដូច្នេះហើយ វាពិបាកដែលទៅលើចំណុចទាំងអស់នេះ។ ខ្ញុំបានលើកចំណុចទាំងអស់នេះព្រឹកមិញផងដែរ ហើយនៅ ចំពោះមុខអង្គសវនាការនាពេលនេះ។ ខ្ញុំនឹងមិនធ្វើការទាមទារនិងអះអាងថាគាត់បដិសេធថាគាត់មិន

ប្រព្រឹត្តឧក្រិដ្ឋកម្មទេ គាត់ប្រាកដជាត្រូវបានកាត់ទោសទៅលើចំណុចទាំងអស់នេះ។ ប៉ុន្តែសាធារណជនត្រូវយល់អំពីចំណុចនេះ ហើយមិនចង់ឲ្យរបបនេះកើតឡើងសាជាថ្មី។

របបនេះនឹងកើតឡើងសាជាថ្មី ប្រសិនបើយើងមិនដោះស្រាយឲ្យត្រឹមត្រូវ ហើយវាធ្វើឲ្យបុគ្គលដែលសាមញ្ញមួយរូបនឹងក្លាយទៅជាជនពេជ្ឈឃាដសាជាថ្មី។ ដូច្នេះ យើងត្រូវគិតអំពីបាតុភាពទាំងអស់នេះ។ ចំណុចនេះ ដេវីដ ឆេនដ៍ល័រ គាត់បានលើកឡើងយ៉ាងច្បាស់អំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយសារតែការទទួលបញ្ជាពីថ្នាក់លើ។ ទស្សនវិទូក្នុងទសវត្សរ៍ទី១៦ *អ៊ិចទី ឌឺ ឡា ប៊ូទី* ឈ្មោះរបស់គាត់ គាត់បានសរសេរថា គាត់សរសេរស្នាដៃមួយតូច ដែលហៅថា “ដំណើរការនៃការអនុវត្តរបស់បម្រើ” ទោះបីជានៅក្នុងសតវត្សទី១៦ ក៏ដោយ គាត់បានប្រាប់យើងជាស្រេចហើយថា ដំណោះស្រាយគឺត្រូវតែគោរពចំពោះអ្នកណាដែលជាមេរបស់យើង យើងនឹងបានរួចខ្លួន។

ខ្ញុំសូមអនុញ្ញាត ខ្ញុំសង្ឃឹមនៅក្នុងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ លោក លោកស្រីចៅក្រមនឹងលើកគំនិតនេះមកពិចារណា។ លោក លោកស្រីចៅក្រម ត្រូវតែយល់ជ្រាបច្បាស់ថា ខ្ញុំត្រូវតែបង្ហាញបំភ្លឺគំនិតនេះជូនលោក លោកស្រី គឺថារយៈកាល៣៥ឆ្នាំមកហើយ។ មុននោះ ខ្ញុំបានការពារសិទ្ធិជនស៊ីវិលជាច្រើនណាស់នៅក្នុងសាលាក្ដីផ្សេងៗ ហើយខ្ញុំក៏បានការពារពលរដ្ឋដែលមិនបានគោរពច្បាប់ ហើយនៅក្នុងលក្ខខណ្ឌដែលមិនមានអំពើហិង្សា ដើម្បីជាកាតព្វកិច្ចកែប្រែច្បាប់ គឺជាការអនុវត្តដែលយើងដឹងច្បាស់ណាស់នូវកម្ពុជា ដោយសារថា យើងមិនខុសឆ្ងាយពីឥណ្ឌានោះទេ។ គឺជាការអនុវត្តវិជ្ជាជីវៈ គឺជាយុត្តិសាស្ត្រដែលបានចងក្រងដោយ មហាត្មៈ ហ្គាន់ឌី គឺជាការអនុវត្តបែបអហិង្សាដែលបានរៀបរាប់យ៉ាងច្បាស់ដោយ ហាណា អារិន។ ហាណា អារិន នោះគាត់បានសរសេរសៀវភៅ *អេចម៉ាន់* *(Eichmann)* ហើយគាត់បានសួរសំណួរដ៏ត្រឹមត្រូវដោយបញ្ជាក់ថា នៅពេលដែលស្ថានភាពត្រូវបានរាំងស្ទះពលរដ្ឋគ្រប់រូបនឹងងើបឡើង ហើយនិងប្រឆាំងក្នុងខណៈអមនុស្សធម៌ ដើម្បីគោរពទៅតាមច្បាប់ពេលនោះយើងត្រូវយល់ឲ្យច្បាស់ថាតើការមិនគោរពនោះវាមានន័យដូចម្ដេច? គឺមិនមែនជាការងាយស្រួលនោះទេ តើខ្ញុំអាចអះអាងនៅក្នុងតុលាការមួយថា យើងអាចងាកចេញពីការមិនគោរពបានដែរឬទេនៅក្នុងស្ថានភាពមួយនៅពេលនោះ ពីព្រោះកាលនោះវា៣៥ឆ្នាំកន្លងមកហើយ។

ខ្ញុំសូមបញ្ជាក់ថា ខ្ញុំផ្អែកទៅលើអ្នកប្រកាន់សាសនានៅក្នុងគោលការណ៍សហរដ្ឋអាមេរិក ដែលគេនិយាយថា៣០ឆ្នាំនៃការពិនិត្យការពិសោធន៍៣០ឆ្នាំជាងមកហើយនោះ ហើយយើងបានយើងមើលពលរដ្ឋអាមេរិក គឺថាយើងត្រូវមើលឲ្យច្បាស់ ហើយយើងត្រូវដាក់នៅក្នុងចំណុចមួយថាតើ ហើយ

យើងអាចកាត់ទោសផ្អែកទៅលើជនម្នាក់ដែលបង្ហាញពីចំណុចដែលមិនច្បាស់នោះទេ។ ដូច្នេះ យើងបើយើងចង់សួរសំណួរនោះគេ ថាតើគេសួរគេកុហកដែរឬអត់? ពេលនោះយើងនឹងអាចនឹងបញ្ជូនចរន្តអគ្គីសនីទៅឲ្យគេ ពេលនោះគឺយើងមានអ្នកពន្យល់ម្នាក់គឺថា ថាតើយើងអនុវត្តហុកសិបភាគរយនៃអ្នកចូលរួម ដូចដែលខ្ញុំឬលោកចៅក្រមអ៊ីចឹងគឺថា ពីព្រោះគេគោរពបញ្ជារបស់មនុស្សដែលគេបញ្ជា នៅក្នុងការពិសោធន៍នោះដែលចុចគន្លឹះរហូតទៅដល់ចំណុចដែលថាដើម្បីឲ្យអគ្គីសនីឆក់អ្នកនោះឲ្យស្លាប់នោះ។ ប៉ុន្តែនៅទីបំផុត ប៉ុន្តែតាមការពិត គឺថាគេអ្នកដើរតួដើម្បីបង្កការភ័យខ្លាចទៅឲ្យជនរងគ្រោះតែប៉ុណ្ណោះ។

គឺថានៅក្នុងពេលនេះ គឺយើងត្រូវតែពិនិត្យមើលស្ថានភាពថាតើយើងត្រូវគោរព ឬមិនគោរពនៅក្នុងកាលនោះ។ នៅខ្ញុំពេលដែលខ្ញុំនិយាយពីករណីរបស់ប្រទេសបារាំងនោះ ខ្ញុំនិយាយអំពីអតីតប្រធានាធិបតីឧត្តមសេនីយ៍ ឌឺហ្គោល ដែលមិនគោរពទៅតាម ហើយគាត់បានទៅនៅប្រទេសបារាំង ហើយទៅរស់តស៊ូនៅប្រទេសអង់គ្លេស ហើយត្រលប់មកវិញគឺថា គេកាត់ទោសប្រហារជីវិតនៅក្នុងប្រទេសបារាំង ប៉ុន្តែគាត់ជាមនុស្សគាត់ជាអ្នកមិនគោរព គឺចាំបាច់គាត់មិនគោរពទៅតាមរបបឧក្រិដ្ឋរបស់ខ្មែរក្រហម ថាតើត្រូវគោរព ឬមិនគោរពបើគាត់នៅក្នុងស្ថានភាពបែបនោះ។ ប៉ុន្តែ តើពេលប៉ុនណាដែលហៅថាចាំបាច់ ដើម្បីឲ្យភាពចាំបាច់នៃការមិនគោរពនេះឲ្យយើងទាំងអស់គ្នាយល់បាននៅក្នុងការសម្ប-ជញ្ញៈរបស់យើង។ ខ្ញុំបានឮសម្តីរបស់លោក អូបាម៉ា ថ្មីៗនេះគឺថា ត្រូវបញ្ចប់នូវការឈឺចាប់ទុក្ខសោក។ ចំណុចមួយគាត់និយាយអំពីទាហានរបស់អាមេរិកាំងដែលបានគោរពបញ្ជានៅអ៊ីរ៉ាក់ ហើយក៏បានប្រើអំណាចនោះដើម្បីនឹងធ្វើទារុណកម្ម អូបាម៉ា និយាយថា អ្នកដែលបំពេញភារកិច្ចរបស់ខ្លួនដោយស្មោះត្រង់គោរពតាមការណែនាំច្បាប់នៃក្រសួងយុត្តិធម៌នោះ នឹងមិនត្រូវជាកម្មវត្ថុនៃការស៊ើបអង្កេតចោទប្រកាន់នោះទេ។ ផ្លូវនោះវានៅឆ្ងាយណាស់ តើអ៊ីចឹងដែរឬទេ?

[១៤:០៤:២២]

លោក លោកស្រីចៅក្រមជាទីគោរព, ផ្លូវនៅវែងឆ្ងាយណាស់តាមពិតឲ្យដើម្បីឲ្យចំណុចមួយដែលយើងនឹងឈានទៅដល់។ ខ្ញុំមិនជឿជាក់ទេថា ដីកា ឬក៏សេចក្តីសម្រេចរបស់អង្គជំនុំជម្រះនោះវារឹងមាំដែលអនុញ្ញាតឲ្យជីវិតរបស់មនុស្សលោកម្នាក់ ឲ្យឃ្លាតឆ្ងាយពីច្បាប់កំនត់ ហើយនិងឃ្លាតឆ្ងាយពីច្បាប់របស់អាទិទេពនោះ គឺសម្តីរបស់ អាល់ប៊ឺត អាំងស្តែន នោះបាននិយាយថា មិនធ្វើអ្វីប្រឆាំងនឹងសម្បជញ្ញៈរបស់អ្នកទោះបីជារដ្ឋតម្រូវឲ្យអ្នកធ្វើដូច្នោះក៏ដោយ។ ដូច្នេះ ខ្ញុំនិយាយម្តងទៀត តើលោក វ៉ាន់ ណាត និយាយដូចម្តេចនៅក្នុងខ្សែភាយន្តដ៏ល្អបំផុតរបស់ ឫទ្ធី ប៉ាន់ នៅស-២១ និយាយអំពីគ្រឿង

ម៉ាស៊ីនឃាតកម្មរបស់ខ្មែរក្រហម ហើយគាត់សួរថា តើអ្នកបានទុកសម្បជញ្ញៈនៅទីណា?

តាមពិតប្រសិនបើយើងមិនរៀន មិនគោរពប្រព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យនោះទេ តើយើងធ្វើដូចម្ដេចនៅក្នុងរបបផ្ដាច់ការបែបនេះ? ក៏ប៉ុន្តែការនិយាយអំពីការមិនគោរព ដែលការនោះវាមានន័យសំខាន់ណាស់សម្រាប់យើងនៅពេលដែលយើងរស់រានរាល់ថ្ងៃនេះ។ តើយើងអាចធ្វើដូចម្ដេចបាននៅក្នុងរដ្ឋប្រជាធិបតេយ្យទាំងឡាយ? តើយោធាទាំងអស់អនុវត្តការងារដូចម្ដេច? តើរដ្ឋបាលបច្ចុប្បន្នគេធ្វើការដូចម្ដេច? គឺថាសង្គមយើងទាំងអស់គ្នា គ្រប់លំដាប់ថ្នាក់ទាំងអស់គឺយើងត្រូវតែមានមេនៅថ្នាក់លើជាអ្នកឱ្យបញ្ជាហើយមានមេនៅថ្នាក់កណ្ដាលមួយដែលបញ្ជូនបញ្ជាបន្តទៅ គឺយើងដឹងច្បាស់ហើយខ្ញុំក៏បានដឹងច្បាស់ដែរនៅក្នុងសាលសវនាការនេះថា មនុស្សជាច្រើននិយាយថា ខ្ញុំមិនអាចឆ្លើយទៅលោកចៅក្រមទេ ខ្ញុំត្រូវតែសុំការអនុញ្ញាតពីមេខ្ញុំសិន គឺថាយើងតែងតែធ្វើការងារតាមបែបបទបែបនេះឯង។ ខ្ញុំសង្ឃឹមថា អង្គជំនុំជម្រះនឹងលើកឡើងនូវបញ្ហាទាំងអស់នេះក្នុងការធ្វើការពិចារណា អំពីបទឧក្រិដ្ឋនៃការគោរពបញ្ជាមេ គឺជាបទឧក្រិដ្ឋមួយដែល ឌុច បានប្រព្រឹត្ត ហើយជាពិសេសជាបទឧក្រិដ្ឋនៃការគោរពបញ្ជាមេក្រៅពីហ្នឹងមិនមានអ្វីទៀតទេ ប៉ុន្តែអាចនឹងនិយាយថា បទឧក្រិដ្ឋនៃការចំណុះគេ ប៉ុន្តែយើងគួរតែកត់សម្គាល់ថា ការគោរពវាដូចម្ដេច? បើការមិនគោរពវាមានលទ្ធផលដូចម្ដេច? ពាក្យថា មិនគោរពនេះមានន័យថា ពាក្យរបស់ឡាតាំងថា ត្រូវស្ដាប់ បន្ទាប់មកធ្វើតាម។ ពេលនេះហើយដែលការគោរពតាមហ្នឹងគឺសម្ដែងន័យខ្លួនឯងអំពីលទ្ធភាពដែលថា មិនអាចឱ្យមានលទ្ធភាពដែលចៀសបាននោះទេ។

[១៤:០៧:៥៣]

អ៊ីចឹងហើយដោយសារថា បទឧក្រិដ្ឋហ្នឹងគឺជាបទឧក្រិដ្ឋនៃការចំណុះតាម រណបតាម បន្ទាប់ពីការធ្វើការងារ៣៥ឆ្នាំមកហើយជាមេធាវី គឺថាបើសិនជាអ្នកណាម្នាក់ដែលមិនគោរពច្បាប់នោះ គឺថាខ្ញុំពិបាកនឹងការពារ អ្នកណាដែលបំពេញការងារមិនគោរពវិន័យ និងច្បាប់នោះណាស់។ ដូច្នេះ គឺថាយើងត្រូវប្រឈមនឹងបញ្ហាមួយទៀត ដែលអាចនឹងកើតឡើង គឺជាបញ្ហាដែលលើកឡើងដោយលោក ដេវីឌ ឆេនដ៍ល័រ។ ខ្ញុំមិនដែលបានស្ថិតក្នុងសភាពបែបនោះក្នុងម្ដងណាសោះ។ ក៏ប៉ុន្តែ ថាតើខ្ញុំនឹងត្រូវធ្វើអ្វី? ហើយខ្ញុំដឹងច្បាស់ថា លោកខ្លួនឯងត្រូវតែសួរខ្លួនឯងពីសំណួរនេះ។

ទោះបីជាលោក ក្រេក អេតឆេសាន់ បានព្យាយាមគេចវាងមិនឆ្លើយនឹងសំណួរនោះដែរ ប៉ុន្តែគាត់គួរតែទទួលស្គាល់ថា ជាសំណួរដូចច្បាស់ដែលថាគាត់ត្រូវផ្ដល់ការពិត ដែលថាម្នាក់ៗត្រូវតែមានជម្រើសថាត្រូវស្ដាប់ ឬត្រូវរស់នោះ។ យើងចងចាំពាក្យមួយដែល ដេវីឌ ឆេនដ៍ល័រ បាននិយាយដែលថា

នាំឲ្យយើងយល់បានពេលដែលយើងស្តាប់នោះហើយគាត់ដកស្រង់ គឺជាព័ត៌មានដែលគួរឲ្យភ័យរន្ធត់មួយនោះ ដែលដកស្រង់ចេញមកពីសម័យហាយនភាពដែលថា ចារីទាំងឡាយបានប្រព្រឹត្តអំពើនោះមិនមែនជាភ័ស្តុតាងបង្ហាញថា វាអាចធ្វើទៅបាន យើងអាចមានលទ្ធភាពនឹងប្រព្រឹត្តនូវបទឧក្រិដ្ឋនោះទេ។ នេះគឺជាចំណុចមួយ គឺជាចំណុចមួយដែលថា បញ្ជាក់ដោយ លោក ប៊ីហ្ស ដែលគាត់ថា គាត់នៅចំពោះមុខមនុស្សម្នាក់ដែលធ្លាប់ជាអ្នកធ្វើទារុណកម្មមិនមែនត្រឹមតែអ្វីដែលសរសេរនៅក្នុងសៀវភៅ ឆេនដ៏ល័រទេគឺជាចំណុចសំខាន់យ៉ាងច្បាស់លាស់ ជាគំនិតមួយហើយជាទស្សនទានដែលខ្ញុំត្រូវធ្វើការជាមួយសហព្រះរាជអាជ្ញាក្នុងនាមប្រទេសនេះ ហើយដើម្បីសុខមាលភាពមនុស្សលោកនៃប្រទេសនេះ។ ដើម្បីរកប្រភពឲ្យឃើញថា និយាយថា ជាអំពើធ្វើនៅស-២១ រៀងរាល់ថ្ងៃជាអំពើដូចបិសាចនោះ តើគាត់ស្រង់ពីកន្លែងណា? យើងត្រូវពិនិត្យមើលចំណុចហ្នឹងដោយខ្លួនឯងឲ្យបានច្បាស់។ តើការបំភ័យបែបនេះ ឬក៏អះអាងបែបនេះ គឺវាឆ្ងាយចេញអំពីការពន្យល់ធម្មតាក្នុងការកំណត់ថាជនម្នាក់ក្លាយទៅជាអ្នកទទួលថ្នូបាក់។

បន្ទាប់ពីគិតបែបនេះ គឺថាយើងអាចនឹងគោរពទៅតាមទស្សនវិស័យមួយចំនួន ខ្ញុំសូមអនុញ្ញាតដើម្បីចែករំលែកនូវឧត្តមគតិ ឬក៏គំនិតមួយចំនួនដែលនិយាយអំពីច្បាប់។ ដោយបានពិនិត្យឃើញបញ្ហាមួយចំនួនដែលលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់នេះដែលថាយើងមានតែ១៦ទំព័រទេ គឺនិយាយអំពីសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោលរបស់យើង គឺថាយើងគិតថាវាជាកត្តាចាំបាច់ដើម្បីនឹងលើកឡើងកំណត់ជូននីតិវិធី គឺយើងមិនបញ្ជាក់ឡើងវិញនូវអ្វីពីមុនទេ ប៉ុន្តែយើងនឹងពិនិត្យមើលសេចក្តីសន្និដ្ឋានដែលទាក់ទងទៅនឹងទ្រឹស្តីនៃបទសហកម្មឧក្រិដ្ឋកម្មរួមដែលខ្ញុំនឹងនិយាយឡើងវិញ ហើយខ្ញុំមិនគិតថានៅពេលណាមួយ អង្គជំនុំជម្រះនេះអាចនឹងកំណត់ថា ឌុច បានប្រព្រឹត្តនូវបទល្មើសដែលលើកឡើងថ្មីនេះទេ។

[១៤:១២:៣៣]

នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ចំពោះមនុស្សមួយចំនួនដែលបានផ្តល់សក្ខីកម្មរួចហើយចំពោះតុលាការនេះ ហើយមិនបានផ្តល់សិទ្ធិឲ្យពួកអ្នកទាំងនោះការពារខ្លួនគេទាល់តែសោះ។ ខ្ញុំជឿថា អង្គជំនុំជម្រះជឿថាហើយថា ខ្ញុំបានដឹងថាយើងមិនមានការអាណិតអាសូរចំពោះអ្នកទាំងឡាយ អ្នកដែលបានបដិសេធដែលគាត់ប្រព្រឹត្ត ដូចជា លោក ម៉ម ណៃ ខ្ញុំមិនអាចទទួលដែលថា មនុស្សម្នាក់ដែលថា បានឃើញឈ្មោះរបស់ខ្លួននៅក្នុងសាលក្រមដែលត្រូវបានកាត់ទោស ដោយសារថាខ្លួនជាផ្នែកមួយនៃបទ

សហកម្មឧក្រិដ្ឋកម្មរួម ហើយខ្លួនមិនបានការពារខ្លួនបន្តិចទាល់តែសោះនៅក្នុងដំណើរការនីតិវិធីនោះ។ ដូច្នេះសូមអង្គជំនុំជម្រះរំឭកថា ប្រសិនបើនេះជាករណីពិតប្រាកដមែននោះ គឺជាការទទួលខុសត្រូវរបស់សហព្រះរាជអាជ្ញាក្នុងការរៀបចំឲ្យមានសវនាការអសាធារណៈ ដើម្បីឲ្យពួកគេការពារខ្លួនបានឲ្យគេអាចនិយាយចំពោះការចោទប្រកាន់ដែលធ្វើឡើងប្រឆាំងគេ ប៉ុន្តែការងារនេះមិនបានធ្វើទេ។ ដូច្នេះហើយខ្ញុំសង្ឃឹមថា អង្គជំនុំជម្រះនឹងច្រានចោលការចោទប្រកាន់អំពីសហកម្មឧក្រិដ្ឋកម្មរួមនេះ។

លោកប្រធានអង្គជំនុំជម្រះតុលាការ ឡេបាណុន ខ្ញុំសូមទាញចំណាប់អារម្មណ៍អង្គជំនុំជម្រះទៅសម្រេចសម្រេចដែលចេញដោយអង្គបុរេនៅថ្ងៃទី៥ ធ្នូ និយាយថា ឌុច មិនអាចត្រូវបានចោទប្រកាន់អំពីការដែលបានប្រព្រឹត្តទារុណកម្មដោយខ្លួន ប៉ុន្តែខ្ញុំមានការភ្ញាក់ផ្អើលណាស់ពីម្សិលមិញនេះ ពីល្ងាចម្សិលមិញសហព្រះរាជអាជ្ញាបានលើកឡើង ហើយបានស្នើសុំឲ្យ ឌុច ទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលមិនបានចោទ ដូចជា ការញុះញង់ ការបញ្ជា និងការធ្វើទារុណកម្ម។ ប៉ុន្តែ បុរេជំនុំជម្រះបានសម្រេចថាមិនអាចទទួលទោសពីបទបញ្ជា ឬញុះញង់នោះទេ។ ប៉ុន្តែ ទឡ្ហីករណ៍ដែលខ្ញុំនឹងលើកឡើងបន្ទាប់មកទៀតនោះ គឺមានការសំខាន់ណាស់ចំពោះខ្ញុំ គឺជាបញ្ហានៃការបកប្រែ ប៉ុន្តែគឺជាបញ្ហាដែលបង្ហាញឃើញច្បាស់ទាក់ទងទៅនឹងវិធាន៨៧ នៃវិធានផ្ទៃក្នុង ។

[១៤:១៥:៣៥]

ចំណុចទីមួយ កថាខណ្ឌទី១ នៃវិធាន៨៧ បានចែងថា។ ខ្ញុំសូមឲ្យអ្នកបកប្រែបើកទៅដល់វិធាននោះដើម្បីអាន។ “អង្គជំនុំជម្រះត្រូវតែកាត់ទោសផ្អែកលើអំពើរបស់ជនជាប់ចោទ ឲ្យហួសពីវិមតិសង្ស័យដើម្បីកាត់ទោសជនជាប់ចោទនោះបាន ទិវុឍភាពរបស់គាត់ត្រូវតែបង្ហាញឲ្យបានច្បាស់ ឲ្យហួសពីវិមតិសង្ស័យ” បានន័យថា ឲ្យគ្មានការសង្ស័យ។ នេះជាអត្ថបកប្រែមួយមិនល្អសោះ យើងនិយាយអំពីប្រព័ន្ធច្បាប់ពីរ។ ឥឡូវនេះ គឺជាប្រព័ន្ធដែលមានន័យពីរខុសគ្នាស្រឡះ។ ទោះបីជានៅក្នុងកាលវិភាគចុងក្រោយក៏ដោយ ខ្ញុំគិតថា ចៅក្រមនៅក្នុងប្រពៃណីច្បាប់ខំមិនឡនោះ អាចនឹងទទួលស្គាល់ថា ហួសវិមតិសង្ស័យនោះ មានន័យថា ការកាត់ទោសចុងក្រោយ។ ក៏ប៉ុន្តែប្រព័ន្ធរបស់យើងខ្ញុំវិញ សញ្ញាណនៃការបង្ហាញភស្តុតាង គឺវាមិនដូចគ្នា ហើយសហព្រះរាជអាជ្ញានិយាយដដែលៗ ថាត្រូវបង្ហាញឲ្យហួសពីវិមតិសង្ស័យ។ ក៏ប៉ុន្តែ ខ្ញុំនិយាយថា អត់ទេ នេះគឺជាការបកប្រែមិនល្អទេនៅក្នុងវិធានផ្ទៃនេះ។ នៅក្នុងភាសាបារាំង និងអង់គ្លេស ហើយខ្ញុំសូមរំឭកថា នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា មាត្រា៣០១ កថាខណ្ឌទី២ ចែងដូចខាងក្រោមនេះ៖

"តុលាការមានបុព្វសិទ្ធិក្នុងការពិចារណាលើភ័ស្តុតាង ដែលបង្ហាញឲ្យខ្លួនអនុលោមទៅតាមការសម្រេចជាចុងក្រោយ នៅទីនេះហើយ"។

អត្ថបទអង់គ្លេសត្រូវបានរៀបចំឡើងសរសេរយ៉ាងត្រឹមត្រូវ ពីព្រោះនិយាយអំពីឥស្សរចិត្តរបស់ចៅក្រមក្នុងការសម្រេចយកនោះ។ នេះហើយ គឺជាគំនិតដ៏ត្រឹមត្រូវនៃក្រមនីតិវិធីព្រហ្មទណ្ឌនោះ។ ចំណុចនេះនឹងមានផលប៉ះពាល់ទៅលើការពិចារណា នៅពេលដែលអង្គជំនុំជម្រះនឹងសម្រេចចេញសាលក្រមនោះ ។

ជាថ្មីម្តងទៀត តាមមាត្រា៨៨ ចែងថា "ចម្លើយសារភាពបង្កើតបានជាភ័ស្តុតាង ធាតុផ្សំនៃភ័ស្តុតាង"។ ខ្ញុំសង្ឃឹមថា លោក លោកស្រីចៅក្រម-- ខ្ញុំគិតថា បញ្ញាញាណរបស់អង្គជំនុំជម្រះនឹងផ្អែកទៅលើការពិចារណាតាមឥស្សរចិត្ត។ ចៅក្រម ឡាវែន៍ អាចនឹងជួយជាជំនួយដល់ខ្ញុំបានមួយចំនួនក្នុងការពិចារណានេះទាក់ទងទៅនឹងក្រមព្រហ្មទណ្ឌរបស់ប្រទេសបារាំង ។

[១៤:១៩:១៣]

នេះ គឺជាគំនិតមួយដោយចម្លែក ជាអត្ថបទមួយដ៏ចម្លែក ដែលមើលឃើញនៅក្នុងសេចក្តីយោងនៃអត្ថបទច្បាប់នេះ។ ហើយទោះបីជាស្ថិតនៅលើមូលហេតុនៃស្មារតីក៏ដោយ មាត្រា៣៥៣ នៃក្រមព្រហ្មទណ្ឌបារាំង ដែលយើងកំពុងតែអនុវត្តនោះ។ "ប្រធានជាអ្នកអាននូវការណែនាំដូចខាងក្រោមនេះ ដែលចង្អុលបង្ហាញយ៉ាងច្បាស់ថា នៅក្នុងការប្រជុំសម្រេចរបស់អង្គជំនុំជម្រះ៖ ច្បាប់មិនតម្រូវឲ្យចៅក្រមទទួលខុសត្រូវចំពោះអត្ថន័យដែលកំណត់ចែងដោយច្បាប់ ហើយមិនបានចែងពីវិធានណា ដែលតាមវិធាននោះដែលខ្លួនត្រូវតែពឹងផ្អែក ដើម្បីនឹងធ្វើការវាយតម្លៃឲ្យបានគ្រប់គ្រាន់ទៅលើភ័ស្តុតាងមួយណា គឺចៅក្រមនោះឯង។ ទៅតាមការពិចារណាដោយឯករាជ្យរបស់ខ្លួន ដើម្បីស្វែងរក-- ផ្អែកតាមសម្បជញ្ញៈដ៏ស្មោះត្រង់ ដ៏ត្រឹមត្រូវរបស់ខ្លួន ហើយនិងទៅតាមលក្ខណៈដ៏ត្រឹមត្រូវនៃភ័ស្តុតាងដែលបានដាក់បង្ហាញចំពោះមុខតុលាការ ហើយនិងប្រើភស្តុតាង។ បញ្ហានេះ គឺជាភារកិច្ចរបស់ចៅក្រមនៅក្នុងពេលដែលធ្វើសេចក្តីសម្រេចចុងក្រោយលើបញ្ហានេះ"។

ខ្ញុំមានចំណុចពីរទៀត ដើម្បីលើកឡើង។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតបន្ថែមពេលឲ្យខ្ញុំបន្តិចទៀត ខ្ញុំមានចំណុចតែពីរ ដើម្បីជម្រាបជូនទៅលោកប្រធាន ។

ប្រសិនបើយើងនិយាយអំពីបុគ្គលិកលក្ខណៈ ឬក៏អត្តចរិតរបស់ ឌុច នោះ--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន។ ពាក់ព័ន្ធទៅអត្តចរិតរបស់លោក ឌុច យើងបាននិយាយជាច្រើនមកហើយ។ ខ្ញុំសូមអនុញ្ញាតដើម្បីជម្រាបជូនអង្គជំនុំជម្រះនិយាយអំពីសៀវភៅរបស់លោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ ដែលខ្ញុំសូមអនុញ្ញាតជម្រាបជូនអង្គជំនុំជម្រះ ដើម្បីពិនិត្យសេចក្តីដកស្រង់ ដែលខ្ញុំមិនបានយោងទៅរក ហើយសហព្រះរាជអាជ្ញាក៏មិនបានយោងទៅរកដែរ។

ការដកស្រង់នោះ គឺថា គឺជាចិត្តដែលពោរពេញទៅសេចក្តីសង្ឃឹម ដែលគាត់បានធ្លាក់ចូលទៅក្នុងបរិវេណពិភពលោកមួយ ដែលពោរពេញទៅដោយអំពើគួរឲ្យរន្ធត់។ គាត់ដូចជាកុមារម្នាក់ដែលរស់នៅក្នុងចំណោមចចក ដែលត្រូវចិញ្ចឹមដោយទឹកដោះកញ្ជ្រោង ហើយត្រូវរស់នៅក្នុង ហើយត្រូវទទួលរងការភ័យខ្លាច។ នោះហើយក្រោយមកក៏បានក្លាយទៅជាអ្នកអំណាច គឺជាកត្តាអូសទាញគាត់ ដែលថាឲ្យគាត់ក្លាយទៅជាអ្នកប្រាសចាកគោលការណ៍សីលធម៌ បែរជាគោរពតាមបញ្ញាហួសហេតុពេក ។

[១៤:២៣:៣៣]

យើងចង់ជម្រាបជូនអង្គជំនុំជម្រះអំពីសក្ខីកម្មមួយចំនួន ដែលសាក្សីមួយចំនួនបានផ្តល់ ដែលបាននិយាយថាមុនពេលកម្ពុជាប្រជាធិបតេយ្យនោះ ឌុច គឺជាមនុស្សដាក់ខ្លួន មនុស្សសាមញ្ញ មនុស្សដែលមានសប្បុរស ហើយមនុស្សគួរឲ្យគោរព ហើយគាត់ជាមនុស្សស្ងៀមស្ងាត់ គាត់ជាមនុស្សល្អ។ ពាក្យទាំងឡាយនោះយើងអាចរកឃើញនៅក្នុងសក្ខីកម្មរបស់សាក្សីទាំងអស់នោះ។

ក្នុងទសវត្សន៍ឆ្នាំ៩០ យើងក៏បានឮពាក្យសម្តីទាំងអម្បាលម៉ាននោះដែរ ហើយខ្ញុំនឹងជម្រាបជូនសម្តីដែលនិយាយនៅក្នុងសៀវភៅរបស់ នីក ដងឡុប។ នៅក្នុងទំព័រ២៥៦ ទាក់ទងទៅនឹងសមាជិកនៃកងទ័ពបដិវត្តន៍កម្ពុជា ដែលនិយាយថា ឌុច បានដើរតួជាមនុស្សដ៏សំខាន់ដោយបានធ្វើការងារយ៉ាងសកម្មដើម្បីបំបាត់អំពើគ្រុនពោះវៀន ឬជំងឺផ្សេងៗនៅក្នុងការងាររបស់គាត់ ដែលគាត់ធ្វើការនៅតាមព្រំដែន ហើយជីវិតដ៏ច្រើនដែលត្រូវបានគាត់ជួយសង្គ្រោះ។ ហើយតើយើងអាចស្រមៃបានដែរឬទេ ថាអំពើទារុណកម្មនៅស-២១ តើគាត់ជាមនុស្សដែលគ្មានប្រយោជន៍ក្នុងជីវិត ឬដែរឬយ៉ាង? ប៉ុន្តែ គាត់បែរជាមកធ្វើការនៅក្នុងមនុស្សធម៌បានដូចគ្នា ។

ខ្ញុំសូមអនុញ្ញាតលើកជូនអង្គជំនុំជម្រះដោយសង្កត់យ៉ាងធ្ងន់ៗដូចតទៅនេះ អំពីដំណើរដែលជន

ជាប់ចោទ គាត់មើលខ្លួនឯងឃើញ ថាតើគាត់បានដើរផ្លូវណា? មានការទទួលស្គាល់ជាច្រើន ហើយក៏ជាអង្គហេតុដែលថាជាការពិត។ សំណួរមួយចំនួន ដែលសួរថា តើគាត់អាចធ្វើដូចម្តេចបាន ដើម្បីផ្តល់នូវសំណាង ហើយនិងការជួសជុលដូចដែលសហព្រះរាជអាជ្ញាលើកឡើង ហើយនិងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនោះបានឡើង។ នេះមិនមែនជាបញ្ហាត្រឹមត្រូវ មិនមែនជាបញ្ហានៃយុត្តិសាស្ត្រនោះទេ នេះជាសំណួរដ៏ជាក់លាក់ ។

ដូចដែលលោកជ្រាបហើយ ខ្ញុំបានសួរទៅលោកស្រី ស៊ីរ៉ូនី ដែលជាអ្នកជំនាញនោះ ហើយគាត់បាននិយាយថា គឺថាមិនអាចមានការបដិសេធបានទេ ហើយក៏មិនត្រូវមានការមិនទទួលស្គាល់នូវការពិតនោះដែរ។ យន្តការចិត្តសាស្ត្រផ្លូវចិត្តមួយនេះ គឺថាទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំចង់ជម្រាបថា វាអាចនឹងងាយនឹងធ្វើការចោទប្រកាន់ខ្លួនឯង ក្នុងឋានៈជាឧក្រិដ្ឋជន គាត់ទទួលអារម្មណ៍ថាមានពិរុទ្ធ តើខ្ញុំត្រូវធ្វើម៉េច?

ហើយខ្ញុំបានសួរសំណួរមួយចំនួនទៅលោកស្រី ស៊ីរ៉ូនី ប៉ុន្តែវាមិនមានការលំបាកអ្វីនឹងឆ្លើយនោះទេ និងទទួលស្គាល់ថា អ្វីៗដែលថាគាត់បដិសេធមិនទទួលស្គាល់ ហើយគាត់បានឆ្លើយថា បាទ គឺអ៊ីចឹងមែន។ ដំណើរការនេះឯងជាផ្លូវអារម្មណ៍ ដែលគាត់គិតគូរពីផ្លូវចិត្តសាស្ត្ររបស់គាត់នៅក្នុងខ្លួនគាត់នោះ។

ហើយខ្ញុំសូមបញ្ជាក់ច្បាស់ជូនអង្គជំនុំជម្រះថា ហើយក៏ចំពោះជនរងគ្រោះដែរនូវអ្វីមួយចំនួនដែលមានការទទួលស្គាល់ក្នុងស្ថានចិត្តសាស្ត្រ ដែលថាអ្នកជួបប្រទះនូវជំងឺបាក់ស្បាតបន្ទាប់ពីមានរងការភ័យខ្លាចជាដើមនោះ។ នេះគឺជាបញ្ហាតែងតែកើតឡើងនៅក្នុងចំណោមពួកកងទ័ព ដែលបានឆ្លងកាត់ការងារនៅក្នុងចម្បាំង ឬក៏សង្គ្រាមមួយចំនួននោះ។ បើនិយាយតាមការពិត វាជារោគសញ្ញាមួយដែលថាបុគ្គលម្នាក់ដែលមានរោគសញ្ញានេះ គឺថាអាចនឹងគេចខ្លួនដើម្បីបំភ្លេចនូវស្ថានភាពដែលខ្លួនប្រទះនឹងការភ័យខ្លាច និងហើយអាចនឹងចៀសវាងមិននិយាយ ហើយក៏ព្យាយាមចៀស ដើម្បីកុំឲ្យប្រឈមមុខនឹងពាក្យពេចន៍ទាំងអស់នោះ។ អ្នកដែលធ្វើឲ្យជននោះ គឺមានការមិនទទួលស្គាល់មួយផ្នែកនូវការពិត ឬក៏ទទួលស្គាល់ពិត។ ប៉ុន្តែទិដ្ឋភាពមួយនៃការចៀសវាង គឺថាជាផ្លូវអារម្មណ៍ដែលអាចឈានទៅដល់ឆ្ងាយទៅពីអារម្មណ៍ ដែលថាវាអាចនឹងរំញោចខ្លាំង អាចប៉ះពាល់ខ្លាំង ។

[១៤:២៨:៥៣]

ខ្ញុំសូមអនុញ្ញាត ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីប្រហែលជាមិនជឿខ្ញុំទេ ប៉ុនខ្ញុំសូមនិយាយថាខ្ញុំជឿជាក់ថា ប្រសិនបើ ឌុច បាននិយាយថា ចំណុចសំខាន់នោះ គឺមានបញ្ហាមួយចំនួនដែលថាគាត់នៅ

លាក់លៀមមិនបានប្រាប់យើងនោះ ហើយថាចំពោះអស់លោក លោកស្រីខ្លះអាចនឹងជាការសំខាន់ អាចនឹងយល់ចំណុចនេះ គាត់បាន-- ឌុច បាននិយាយថា ខ្លឹមសារទាក់ទង ឬចំណុចសំខាន់នៃបទឧក្រិដ្ឋនោះក៏ប៉ុន្តែវាមានបញ្ហាមួយចំនួនដែលនៅសេសសល់។ មេធាវី ស្លូតហ្សិនស្គី បានព្យាយាមចង់ដឹងច្រើន ប៉ុន្តែមិនអាចដឹងបាន។ ប៉ុន្តែនៅក្នុងដំណើរការថា តើគាត់បានគេចកែ គាត់ចៀសវាងឬ? ខ្ញុំមិនគិតដូច្នោះទេ យើបានឃើញពីអារម្មណ៍នៅក្នុងពេល ម៉ម ណៃ មកបង្ហាញ ហើយក៏នៅក្នុងអារម្មណ៍របស់ ឌុច ដែលពេលដែលយើងនិយាយដេញដោលអំពីសាស្ត្រាចារ្យ ភឹង តុន នោះ ។

[១៤:៣០:០០]

ដូច្នេះការពិតណាស់ មានការមន្ទិលសង្ស័យនៅក្នុងភាពខុសខ្មៅងងឹត ដូចដែលខ្ញុំបាននិយាយហើយ ចំណុចសំខាន់នៃចំណុចទាំងអស់នេះ ខ្ញុំនិយាយថាឧក្រិដ្ឋនេះ គឺថាគាត់បានទទួលស្គាល់ហើយ ប៉ុន្តែវានៅមានចំណុចមួយចំនួនដែលវានូវមានភាពច្របូកច្របល់គ្នា។ ហើយចំណុចនេះគឺជាមធ្យោបាយមួយ ហើយដូចដែលអ្នកជំនាញបង្ហាញទាក់ទងទៅនឹងផ្នែកដែលផ្នែករបស់ ឌុច មិនអាចឆ្លើយបាន។ នៅក្នុងពេលនេះ គឺថាយើងមានការចាប់អារម្មណ៍ ទោះបីជាគាត់បានគេចបំផ្លើសគេចវេសក៏ដោយ។ ឥឡូវនេះ ដល់ពេលខ្ញុំនិយាយអំពីការផ្តន្ទាទោស។

ការផ្តន្ទាទោសនឹងត្រូវដាក់ចេញដោយយោងទៅលើមូលដ្ឋានដែលយើងបានស្តាប់ឮទាំងអស់គ្នា ហើយដែលនឹងត្រូវសម្រេចដោយយោងទៅលើស្ថានសម្រាលទោស។ យើងដឹងហើយថា បញ្ជារបស់ថ្នាក់លើគឺថាមិនគេចផុតអំពីពិរុទ្ធភាពបានទេប៉ុន្តែតុលាការនូរ៉ឹមប៊ឺក អ្វីដែលបានសរសេរនៅក្នុងអត្ថបទនៃតុលាការព្រហ្មទណ្ឌអន្តរជាតិដែលបទបញ្ជារបស់ថ្នាក់លើ គឺអាចយកមកធ្វើជាកត្តាស្ថានសម្រាលទោសបាន។ ដែលអ្នកអាចបដិសេធបញ្ជារបស់ថ្នាក់លើក្នុងសម័យកម្ពុជាប្រជាធិបតេយ្យបាន ដែលនៅក្នុងលក្ខណៈ ឌុច គឺថាស្ថិតនៅក្នុងសភាពមួយនៃគេហៅថាសង្វាក់នៃការបញ្ជា គាត់គឺជាខ្ញុំបម្រើ និងជាចំណាប់ថ្នូរនៅក្នុងរបបនេះ។ ហើយខ្ញុំអាច-- ខ្ញុំទទួលខុសត្រូវចំពោះការទទួលខុសត្រូវរបស់នេះ។ នេះគឺជាចំណុចទាក់ទងទៅនឹងស្ថានសម្រាលទោស។

ស្ថានទោសនិងចំណុចមួយទៀតដែលយើងអាចនឹងទទួលយកបាននោះ គឺការអ្វីគាត់បានលើកឡើង។ យើងបានឮសួរចំណុចនេះ ខ្ញុំសូមរំឭកឡើងវិញនូវចំណុចនេះ ចំណុចមួយទៀតគឺកិច្ចសហការ។

លោកប្រធានអង្គបុរេជាទីគោរព, តើ ឌុច បន្តការសហការរបស់គាត់ជាមួយនឹងសហព្រះរាជអាជ្ញានៅក្នុងរឿងក្តីទីពីរទេ? ដឹងថាគាត់នៅតែបន្តទេ? សូម្បីតែពីរសប្តាហ៍មុននេះ យើងបានអង្គុយ

ជាមួយគ្នា ជាមួយនឹងសហចៅក្រមស៊ើបអង្កេតដែរថាគាត់នឹងបន្តសហការ ហើយគាត់នឹងឆ្លើយទៅនឹងសំណួរទាំងអស់ដែលសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតបានសួរគាត់ ហើយសប្តាហ៍ក្រោយនេះគាត់នឹងត្រូវឆ្លើយទៀតហើយ។ ជាការគួរឲ្យសោកស្តាយ ខ្ញុំសោកស្តាយណាស់ ដែលយើងមិនបានសង្កត់ធ្ងន់ ឬក៏មិនបានប្រើប្រាស់ការសហការនេះ ដែលសហព្រះរាជអាជ្ញាមិនបានលើកឡើងចំណុចនេះឡើងមកនិយាយទេ សម្រាប់ការស្វែងយល់យុត្តិធម៌។ យើងសូមឲ្យអ្នកជំនាញ ថាតើគាត់អាចស្តារនីតសម្បទានឡើងវិញបានទេ? ហើយយើងចាំបានថា ឌុច អាចស្តារនីតិសម្បទានឡើងវិញបាន។ ដូច្នេះ អ្វីដែលជាគោលបំណងនៃការផ្តន្ទាទោស តើការផ្តន្ទនាទោសមានគោលបំណងដើម្បីធ្វើអី? ដាក់ទណ្ឌកម្ម? ដាក់ទណ្ឌកម្មទៅលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង។ បាទ, ជាការពិតហើយ ត្រូវហើយ ប៉ុន្តែបើខ្ញុំមិនច្រឡំទេ តុលាការនៅទូទាំងពិភពលោកនេះ កំពុងតែពិចារណាថា ការស្តារនីតិសម្បទាក៏ត្រូវយកមកពិចារណានៅក្នុងការផ្តន្ទាទោសនេះផងដែរ។

ដូច្នេះ នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលទាក់ទងទៅនឹងការស្តារនីតិសម្បទានឡើងវិញ ខ្ញុំចាំបានថា លោក លើហ្វ៊រ ដែលបានលើកឡើងអំពីការឈឺរបស់គាត់ ហើយអ្នកស្រីបានលើកជាសំណូមពរមក-- បានលើកសំណូមពរដ៏គួរចាប់អារម្មណ៍ថា ខ្ញុំអាច-- នៅក្នុងប្រតិចារឹកនៃសំណុំរឿង០០១ ខ្ញុំអាចនឹកឃើញថា ឌុច គាត់ធ្វើការដូចជានៅជើងឯកដើម្បីឲ្យកន្លែងនេះក្លាយទៅជាកន្លែងកប់មនុស្ស។ ខ្ញុំឃើញកម្ទេចសំរាមនោះ ហើយខ្ញុំឃើញកន្លែងនោះស្អាតមែនទែន ដើម្បីឲ្យក្មេងៗជំនាន់ក្រោយហ្នឹងយល់ឃើញ ដឹងថាខ្មែរសម្លាប់ខ្មែរ ហើយដើម្បីបញ្ជាក់ថាហ្នឹងមិនមានកន្លែងត្រូវអាចចរចាគ្នាទេ។ នេះគឺជាយោបល់មួយដ៏ល្អ ហើយកាលដែលឲ្យ ឌុច ក្លាយទៅជាអ្នកកាត់ស្មួនអ្នកថែស្មួនមួយដ៏សាមញ្ញ។ គឺថាខ្ញុំឃើញគាត់នៅជើងឯក គាត់បានពន្យល់ទៅកាន់ក្មេងៗជំនាន់ក្រោយថា នូវអ្វីដែលមិនគួរធ្វើ ពន្យល់ទៅក្មេងៗថាជាការពិតណាស់ យើងនឹងអាចធ្វើសេចក្តីសម្រេចនូវថ្ងៃណាមួយ ហើយខ្ញុំនឹងអាចមានសោកស្តាយចំពោះសេចក្តីសម្រេចនេះអស់មួយជីវិតរបស់ខ្ញុំ។

[១៤:៣៦:៤២]

ហើយព្រឹកមិញនេះ ខ្ញុំបានលើកឡើងផងដែរ នៅក្នុងការទទួលយកសារភាពទទួលយកពិរុទ្ធភាពដែលលើកឡើងពីម្សិលមិញ ពាក់ព័ន្ធទៅនឹង អាល់ប៊ឺត ស្ពៀរ យុត្តាធិការរបស់ អាល់ប៊ឺតស្ពៀរ ដែលជាអតីតរដ្ឋមន្ត្រីក្រសួងការពារជាតិដែលមានឋានៈខ្ពស់ជាង ឌុច ជាអតីតក្រសួងការពារជាតិនៃរបបអ៊ីត្លែរដែលមិនបានសារភាព ទទួលសារភាពនៅតុលាការនូរឹមប៊ឺកទេ ប៉ុន្តែគាត់ទទួលស្គាល់ការទទួលខុសត្រូវ-

- គាត់មិនទទួលកំហុសទេ ប៉ុន្តែគាត់និយាយថា បាទ, ខ្ញុំទទួលខុសត្រូវ។ នេះហើយដែលជាហេតុផលដែលយើងត្រូវសួរទៅអតីតព្រះរាជអាជ្ញា ហេនរី យើង ដែលបានជួបនៅក្នុងប៉ារ៉ូរបស់ខ្ញុំ ការិយាល័យរបស់ខ្ញុំ ខ្ញុំសួរគាត់ឲ្យផ្តល់សក្ខីកម្មនៅទីនេះ ឲ្យគាត់អញ្ជើញមកផ្តល់សក្ខីកម្មនៅទីនេះ ។

[១៤:៣៧:៤០]

អំពី អាល់ប៊ឺត ស្ពៀរ យុទ្ធសាស្ត្ររបស់ អាល់ប៊ឺត ស្ពៀរ ប៉ុន្តែជាអកុសលគាត់ស្លាប់ គាត់មិនអាចមកបាន។ គាត់បានឆ្លើយតបមកយើង "ខ្ញុំជឿថា ការទទួលស្គាល់កំហុសរបស់ អាល់ប៊ឺត ស្ពៀរ បានដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការសម្រេចទៅលើការផ្តន្ទាទោសដែលជាការផ្តន្ទាទោសដាក់ពន្ធនាគារ។ ខ្ញុំមិនអាចដាក់ឯកសារណាដើម្បីគាំទ្រទៅលើគំនិតយោបល់នោះទេ។ ប៉ុន្តែ មានពាក្យចចាមអារ៉ាមនិយាយថាប្រធានរបស់តុលាការនៅ *ហេក* នេះ បានផ្តល់នូវតំលៃទៅដល់អាល់ប៊ឺត ស្ពៀរ នៃការទទួលកំហុសនេះ។ ហើយខ្ញុំខ្លួនឯងក៏បានឮថា គាត់ជឿថា អាល់ប៊ឺត ស្ពៀរ គឺជាមនុស្សម្នាក់ដ៏ល្អនៅក្នុងពិភពលោកយើងនេះ"។ គាត់ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារ២០ឆ្នាំ។ អុប្រ៊ែណ្សវិច ត្រូវបានផ្តន្ទាទោសឲ្យជាប់គុក១៧ឆ្នាំ។ ហើយនៅទីនេះ នេះមិនពាកព័ន្ធទៅនឹងឧក្រិដ្ឋកម្មសាមញ្ញៗ បទល្មើសសាមញ្ញៗ យើងនិយាយតែឧក្រិដ្ឋកម្មដែលជនជាប់ចោទបង្កើតនូវឧក្រិដ្ឋកម្មធ្ងន់ធ្ងរដើម្បីផលប្រយោជន៍ខ្លួនឯង។ យើងនឹងមិនដោះស្រាយ-- មិនពាក់ព័ន្ធទៅនឹងចូលរួមពាកព័ន្ធនឹងបញ្ហានេះទេ។ ដូច្នេះ ថាតើ ឌុច អាចមានសារសំខាន់សម្រាប់មនុស្សជាតិទេ? នេះគឺជាសំខាន់ ដែលអង្គបុរេនឹងត្រូវសួរខ្លួនឯង។

យើងក្នុងនាមជាមេធាវីការពារក្តី មិនមែនតែ ឌុច ទេដែលត្រូវ-- ឌុច ចំណាយជាប់ការឃុំឃាំងដប់ឆ្នាំមកហើយ ដូចដែរលោកសហព្រះរាជអាជ្ញាបានរំឭកកាលពីម្សិលមិញ គឺថាគាត់ក៏ជាអ្នករត់គេចខ្លួនលាក់ពួនខ្លួនម្ភៃឆ្នាំ ពី៧៩ ទៅដល់៩៩។ គាត់បាន-- អ៊ីចឹង ទាំងអស់ហ្នឹងសាមសិបឆ្នាំមកហើយ ដែលគាត់ជាអ្នករត់គេចខ្លួនម្តងហើយម្តងទៀត។ ហើយវាអាចលើសពីនេះទៅទៀតប្រសិនបើយើងអាចបន្ថែមទាក់ទងតាំងពីពេលប្រព្រឹត្តបទល្មើសនិងផ្ទាល់មកទៀត វាកាន់តែច្រើនឆ្នាំទៅហើយ។ រយៈពេល៣០ឆ្នាំដែលមនុស្សនេះមិនមានសេរីភាព។ ចៅក្រមនឹងពិចារណា-- អង្គបុរេជាទីគោរព,ខ្ញុំនៅសល់ពេលតែដប់នាទីទៀត មុននឹងត្រូវឈប់សម្រាក។

[១៤:៤០:៥៨]

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គជំនុំជម្រះអនុញ្ញាតតាមការស្នើសុំ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអគុណលោកប្រធាន។ ខ្ញុំសូមអានចុងបញ្ចប់នៃកំណត់ពន្យល់របស់ខ្ញុំ។ ខ្ញុំបានពិភាក្សាជាមួយប្រជាជនយើងដែលបានប្រាប់ខ្ញុំថា នៅទីនេះ ព្រះពុទ្ធសាសនានិយាយថាបិសាចដែលអ្នកទទួលគឺថានឹងទទួលមកវិញ គឺថា ឌុច បានទទួលនូវអ្វីដែលគាត់បានប្រព្រឹត្តហើយ គឺថាអ្នកប្រព្រឹត្តនូវអំពើអ្វីនឹងទទួលនូវកម្មផលនោះ។ គាត់មានការឈឺចាប់ចំពោះអំពើបាបដែលគាត់បានប្រព្រឹត្ត។ ហើយឥឡូវនេះយើងចូលមកដល់ចុងបញ្ចប់នៃការធ្វើសេចក្តីសកន្និដ្ឋាន នេះគឺជាពេលមួយពិបាកណាស់សម្រាប់មេធាវី វាជាពេលវេលាមួយដ៏ពិបាកសម្រាប់មេធាវីការពារ ដូចដែរគាត់ដឹងហើយថាគាត់ត្រូវតែនៅឲ្យស្ងៀមស្ងាត់មិននិយាយស្តី ដោយសារគាត់ដឹងថា តើខ្ញុំបាននិយាយអ្វីៗអស់ចប់សព្វគ្រប់ហើយឬនៅ? តើខ្ញុំបានបំពេញចប់សព្វគ្រប់ហើយឬនៅ? ពាក្យពេចន៍របស់ខ្ញុំបានចូលមកដល់ទ្វាររបស់អង្គបុរេសម្រាប់ធ្វើការពិចារណា ខ្ញុំចង់ដឹងថាតើរឿងក្តីរបស់យើងមានចំណាប់អារម្មណ៍អីខ្លះសម្រាប់មេធាវីការពារឲ្យចៅក្រមមានចំណាប់អារម្មណ៍នោះ?

ដូច្នេះហើយ សូមអនុញ្ញាតឲ្យខ្ញុំនិយាយពីរបីមាត់ទៀត ដែលជាសារចុងក្រោយសម្រាប់អង្គ-បុរេ។ សុំទោសៗ នៅក្នុងកំណាព្យមួយរបស់ សរ សុវណ្ណរស់ (?) ខ្ញុំបានឮអ៊ីចេះ ដែលគាត់បានផ្ញើសារមួយថា ជាប្រលោមលោកមួយ ខ្ញុំសូមអានដូចខាងក្រោមនេះ៖

"សូមអគុណ ដែលជាផ្នែកមួយនៃ បុប្ផាណា ដែលបន្តរស់នៅក្នុងរបស់អ្នក-- នៅក្នុងខ្លួនរបស់យើងទាំងអស់គ្នា និងរហូតដល់តែយើងដកដង្ហើមចុងក្រោយ។ នោះវានឹងនៅតែមាន-- យើងនៅតែមានការចង់ចាំដ៏ល្អប្រពៃបំផុត បើគ្មានអំពើឃោរឃៅណាអាចបំផ្លិចបំផ្លាញបានទេ"។

ហើយមានសៀវភៅមួយច្បាប់ទៀត ដែលខ្ញុំចង់អានជូនអង្គជំនុំជម្រះ ខ្ញុំសូមអាននូវសេចក្តីផ្តើមដែលសៀវភៅនេះហៅថា កូនសោចូលទៅកាន់ព្រះរាជាណាចក្រ។

"តាមរយៈអង្គជំនុំជម្រះវិសាមញ្ញនេះ យើងឃើញថានេះជាប្រទេសមួយដែលបានរងរបួសដោយរបបខ្មៅងងឹត ឬក៏ហៅថា បាតដៃប្រឡាក់ឈាម ដែលនៅក្នុងប្រទេសកម្ពុជា យើងមិនអាចពិព៌ណ៌នាកម្ពុជានៅក្នុងនេះទេ។ ឧទាហរណ៍ ដែលគាត់អាចនឹងទទួលបាននូវអច្ឆរិយភាពរបស់ខ្លួនបានឡើងវិញដែរ ។ ជាប្រទេសមួយដែលយើងនឹងត្រូវនិយាយពាក្យនៅចុងក្រោយនេះ"។

[១៤:៤៥:០៥]

ខ្ញុំសូមអាននូវសេចក្តីសន្និដ្ឋាន ដែលទាក់ទងទៅនឹងការកាត់សេចក្តីនេះ។ នៅក្នុងសៀវភៅនេះ

គឺថាកម្ពុជាមិនត្រូវបញ្ចប់នៅក្នុងរបបដ៏ខ្មៅងងឹតទេ គ្មាននរណាអាចបំភ្លេចបានទេ ការចងចាំនឹងនៅតែមាននៅក្នុងជីវិតយើងគ្រប់ៗគ្នា។ ប៉ុន្តែ ដូចដែលអនុប្រធានាធិបតីនៅតុលាការនៃប្រទេសលីបង់ ដែលឈ្មោះ ខាលីល ជីរ៉ង់។ “កូនរបស់លោកអ្នក មិនមែនជាកូនរបស់លោកអ្នកទេ គេគឺជាកូនប្រុស កូនស្រីដែលមានការរស់នៅអាយុវែងឆ្ងាយដោយខ្លួនឯង គេមានកំណើតតាមរយៈលោកអ្នក ប៉ុន្តែលោកអ្នកមិនអាចបត់ផ្នត់គំនិតគេបានទេ។ លោក លោកស្រី អាចផ្តល់សេចក្តីស្រលាញ់ ប៉ុន្តែ មិនអាចផ្តល់គំនិតទៅឲ្យគេបានទេ ចិញ្ចឹមគំនិតគេបានទេ។ លោកអាចចង់ឲ្យគេធ្វើខ្លួនឲ្យលោក ប៉ុន្តែ មិនអាចឲ្យគេមានគំនិតដូចលោកបានទេ។ ដោយសារថា ដួងព្រលឹងរបស់ វានឹងចូលទៅក្នុងផ្ទះមួយសម្រាប់ថ្ងៃស្អែក ដែលយើងមិននឹងអាចចូលទៅសួរសុខទុក្ខ ពិនិត្យបាន ហើយក៏មិនអាចស្រមៃបានផង។ លោក លោកស្រីអាចចង់ឲ្យគេធ្វើដូចលោក លោកស្រី បានប៉ុន្តែមិនអាចឲ្យគេមានចិត្តគំនិតដូចបានទេ”។

ពាក្យពេចន៍ពីរបីម៉ាត់ទៀត មុនយើងនិយាយពីជោគវាសនារបស់ ឌុច ដែលត្រូវស្ថិតនៅក្នុងដៃរបស់អង្គជំនុំជម្រះ នេះគឺជារឿងមួយដែល គឺជារឿងជាសកលមួយ វាជារឿងរបស់មនុស្សដ៏ឆ្លាតម្នាក់ជាមនុស្សរបស់ស្បែកសម្នាក់ ដែលគាត់ជាអ្នកចិត្តសាស្ត្រ គាត់ជាអ្នកកាន់សាសនា ឬក៏ជាសង្ឃ គាត់បានបង្រៀនយើងទៅដល់សាវករបស់គាត់ដូចខាងក្រោមនេះ៖

“ថាតើយើងធ្វើម៉េចបានដឹងពីយប់មួយទៅដល់ថ្ងៃមួយ ដើម្បីឲ្យចេញផុតពីភាពងងឹតទៅ ដល់ភាពមានពន្លឺ?” សាវកក៏បានឆ្លើយមកវិញថា “នៅពេលដែលយើងចាប់ផ្តើមរកឲ្យឃើញពណ៌របស់ស្លឹកស្វាយ”។ សាវកម្នាក់ទៀតនិយាយថា “នៅពេលណាដែលយើងអាចមើលទៅដល់ឃើញជួរភ្នំក្រវាញ” ហើយសាវកម្នាក់ទៀតឆ្លើយថា “នៅពេលដែលយើងអាចមើលស្គាល់បងប្អូនប្រុសរបស់យើងនៅក្នុងកែវភ្នែករបស់អ្នកដទៃម្នាក់ទៀត” ។

ឌុច, ជនរងគ្រោះរបស់អ្នកឯងទាំងអស់ គឺជាបងប្អូនប្រុសស្រីក្នុងនាមជាមនុស្សជាតិ អ្នកឯងបាននិយាយថា អ្នកឯងគឺជាមនុស្សកំសាកដែលអ្នកឯង-- គេនឹងទៅមើលអ្នកឯងនៅក្នុងកន្លែងឃុំឃាំងខ្លួនទេ។ នៅក្នុងកែវភ្នែករបស់មនុស្ស អ្នកនឹងមិនអាចត្រូវបានដោះស្រាយចំពោះឧក្រិដ្ឋកម្មទាំងអស់នេះ ហើយកែវភ្នែករបស់អ្នកទាំងឡាយណាដែលអ្នកមិនចង់ជួប និងនៅតែក្រឡេកមើលទៅលើអ្នកឯងជារៀងរហូត ។

[១៤:៤៨:៤២]

ចុះចំពោះយើងទាំងអស់គ្នាទៅវិញ? តើយើងបានរៀបចំខ្លួន ត្រៀមខ្លួនរួចជាស្រេច ដើម្បីក្រឡេក

មើលទៅលើភ្នែក ឌុច និងមើលគាត់ថាក្នុងនាមជាមនុស្សជាតិម្នាក់។ ហើយសំណួរចុងក្រោយនោះតាមការរយៈការកាត់សេចក្តី ដែលយើងអាចនឹងឲ្យ ឌុច ត្រលប់ចូលមកភាពជាមនុស្សជាតិឡើងវិញបានទេ? ពាក្យពេចន៍ចុងក្រោយបំផុត គឺ ឌុច ស្លាប់បាត់ទៅហើយ។ ថ្ងៃនេះគាត់ឈ្មោះ កាំង ហ្គេកអ៊ាវ តែប៉ុណ្ណោះ។ គាត់លែងមានឈ្មោះ ឌុច ដែលជាជនបដិវត្តន៍ទៀតហើយ។

សូមអរគុណ អង្គជំនុំជម្រះជាទីគោរព ។

[១៤:៤៩:៥៦]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ម៉ោងត្រូវសម្រាកល្ហម ដូច្នេះ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងបីនិងដប់នាទី ក៏សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង១៤:៥០ នាទី ដល់ម៉ោង១៥:១១នាទី]*

[១៥:១១:២២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជាកិច្ចបន្តនេះ គឺជាដំណាក់កាលនៃការធ្វើសេចក្តីសន្និដ្ឋានតបរបស់ភាគីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង/ឬ សហព្រះរាជអាជ្ញា ប្រសិនមាន។ ប៉ុន្តែដើម្បីឲ្យបានច្បាស់លាស់ និងសម្របសម្រួលកិច្ចដំណើរការនេះប្រព្រឹត្តទៅបានល្អ អង្គជំនុំជម្រះសូមធ្វើការរំឭកដល់ភាគីទាំងអស់ថា នៅពេលធ្វើសេចក្តីសន្និដ្ឋានតបត្រូវផ្តោតទៅលើបញ្ហាដែលជាកម្មវត្ថុនៃការវិនិច្ឆ័យរបស់អង្គជំនុំជម្រះតែប៉ុណ្ណោះ។

ភាគីទាំងអស់ត្រូវគោរពសិទ្ធិរបស់ភាគីដទៃ នៅពេលដែលខ្លួននិយាយរួមទាំងសិទ្ធិរបស់ជនជាប់ចោទផងដែរ។ ភាគីទាំងអស់ត្រូវតែមានការប្រុងប្រយ័ត្ននូវការបញ្ចេញពាក្យសម្តី អាកប្បកិរិយារបស់ខ្លួន។ ភាគីទាំងអស់ត្រូវគោរពនូវក្រមសីលធម៌វិជ្ជាជីវរបស់ខ្លួន។ អង្គជំនុំជម្រះសង្ឃឹមថា ភាគីទាំងអស់នឹងនិយាយតែសម្អាងហេតុទាំងឡាយណា ដែលទាក់ទិនទៅនឹងអង្គហេតុ ភ័ស្តុតាង និងអង្គច្បាប់ និងមិននិយាយច្រំដែលទៅលើសេចក្តីសន្និដ្ឋានដើមរបស់ខ្លួនឡើយ។ លើសពីនេះទៅទៀត ភាគីទាំងអស់

នឹងគោរពពេលវេលាដែលអង្គជំនុំជម្រះបានសម្រេចរួចហើយ។

ជាការអនុវត្ត ដើម្បីឲ្យមានប្រសិទ្ធិភាពនូវសេចក្ដីណែនាំនេះ អង្គជំនុំជម្រះសូមជម្រាបថា នឹងកាត់ផ្ដាច់នូវសេចក្ដីសន្និដ្ឋានតបណាដែលមិនស្របនឹងការណែនាំនេះ។ ដោយដំបូងអង្គជំនុំជម្រះនឹងរំឭកដល់ភាគីណាដែលមានបញ្ហា និងបន្ទាប់មកនឹងកាត់ផ្ដាច់នូវសេចក្ដីសន្និដ្ឋានតបនោះ បញ្ឈប់លែងឲ្យធ្វើសេចក្ដីសន្និដ្ឋានតបតែម្ដង ។

ជាកិច្ចបន្តនេះ គឺតើខាងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មានត្រូវធ្វើសេចក្ដីសន្និដ្ឋានតបទៅនឹងសេចក្ដីសន្និដ្ឋានរបស់ជនជាប់ចោទ និងមេធាវីការពារក្ដីដែរឬទេ?

ហើយអង្គជំនុំជម្រះសូមជម្រាបថា មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងបួនក្រុម មានពេលវេលាសរុបចំនួនមួយម៉ោង នៅក្នុងការធ្វើសេចក្ដីសន្និដ្ឋានតបនេះ ។

**លោក ការីម ខាន៖**

ខ្ញុំសូមថ្លែងអំណរគុណលោកប្រធាន។ ក្រុមទាំងបួន ក្រុមមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាំងបួនគឺសូមដាក់សេចក្ដីសន្និដ្ឋានតបក្នុងរយៈមួយម៉ោង ដែលបានផ្ដល់ជូន។

សូមការអនុញ្ញាតពីលោកប្រធាន ខ្ញុំនឹងចាប់ផ្ដើមមុន។ ខ្ញុំទទួលបានរយៈពេលម្ភៃនាទី គឺក្រុមទីបួនបន្ថែមឲ្យខ្ញុំបួនប្រាំនាទី។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធានសូមការអនុញ្ញាតតែម្ដង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ! មេធាវីអញ្ជើញ។

**លោក ការីម ខាន៖**

ខ្ញុំសូមអរគុណ។ លោកប្រធាន លោក លោកស្រីចៅក្រម មេធាវីការពារក្ដី សហព្រះរាជអាជ្ញា មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីជាទីគោរព រួមទាំងសាធារណជននៅទីនេះ និងពលរដ្ឋកម្ពុជាទាំងមូល ដែលបានមកចូលក្នុងរយៈពេលនេះ ដែលគ្រោងទុក ហើយមកចូលរួមស្ដាប់នូវសេចក្ដីថ្លែងបិទការបញ្ចប់ការដេញដោល។

វាគឺជាផ្លូវដ៏វែងឆ្ងាយ ដែលយើងបានធ្វើដំណើរមករួមគ្នាទាំងអស់។ ចាប់តាំងពីអ្នកដែលរស់រានមានជីវិតចាកចេញពីមន្ទីរស-២១ ហើយនៅចុងបញ្ចប់នៃវិថីនេះ ដែលយើងសង្ឃឹមថា យុត្តិធម៌នឹងទទួលបាន។ ប៉ុន្តែ លោកប្រធាន លោក លោកស្រីចៅក្រម មុនពេលដែលខ្ញុំចូលទៅដល់សេចក្ដីសន្និដ្ឋានតប គឺវាមានភាពយុត្តិធម៌ ដែលខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដែលគាត់បានលើកឡើងទៅលើភាព

សមរម្យរបស់គាត់ និងសេចក្ដីសន្និដ្ឋានរបស់គាត់នៅក្នុងដំណើរការនេះ។ ហើយខ្ញុំជឿថា ខាងភាគីទាំងអស់ក៏យល់ស្របដូចគ្នា យើងខ្ញុំថ្លែងអំណរគុណចំពោះបទពិសោធន៍របស់គាត់ និងលទ្ធភាពរបស់គាត់នៅក្នុងការបំពេញការដ៏មានភាពលំបាកលំបិននេះ។

លោក លោកស្រីចៅក្រម, ខ្ញុំនឹងមិនលើកឡើងគោលការណ៍ទស្សនវិជ្ជានោះទេ ហើយសេចក្ដីសន្និដ្ឋានរបស់ខ្ញុំក៏មិនចាកឆ្ងាយពីសេចក្ដីសន្និដ្ឋានដែលលើកឡើងដោយលោកមេធាវី រ៉ូ ផងដែរ។ ហើយខ្ញុំ គឺនឹងផ្ដោតផ្អែកសំខាន់ទៅលើភ័ស្តុតាង ដែលនឹងផ្ដល់ជាជំនួយទៅដល់លោកចៅក្រមក្នុងការស្វែងរកការពិត ដើម្បីឲ្យបណ្ដឹងទាមទារសំណងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅដំណាក់កាលចុងក្រោយសម្រេចសងសំណងទៅដល់ពួកគាត់ក្នុងលក្ខណៈសមស្របនិងពេញលេញ។ ហើយយើងខ្ញុំយល់អំពីជនជាប់ចោទ ដែលគាត់មានមេធាវីតំណាងចំពោះឧក្រិដ្ឋកម្មរបស់គាត់ គាត់ទទួលបានសិទ្ធិនេះ។ ប៉ុន្តែ នីតិវិធីរបស់យើង គឺវាទាក់ទងទៅនឹងអត្តចរិតនិងភស្តុតាង ឬក៏ទាក់ទងទៅនឹងពិរុទ្ធភាពរបស់បុរសរូបនេះដែលកំពុងអង្គុយនៅក្នុងឈើរាងវង់ក្រចកសេះនេះ។

ខ្ញុំមិនមានពាក្យអ្វីដែលថានិយាយឲ្យសមរម្យជាងនេះទៀតទេ។ ដូច្នេះ នេះជាពាក្យដែលខ្ញុំប្រើ ហើយខ្ញុំសូមលើកឡើងថា ជនជាប់ចោទនៅក្នុងរឿងក្ដីបានលើកឡើងចំណុចជាច្រើន។ ហើយអ្វីដែលយើងលើកឡើងម្សិលមិញមិនអាចយកមកដាក់ក្រោកកម្រាលព្រំនោះទេ។ វាជាព្រឹត្តការណ៍មួយ។ ដូចដែលលោកមេធាវី រ៉ូ បានលើកឡើង គឺចំណុចទាំងឡាយមានការផ្លាស់ប្ដូរ។ ហើយនៅពេលដែលយើងពិចារណាចំណុចទាំងអស់នេះ គឺយើងឃើញថា មានការសារភាពទោសទៅលើសម្ភារៈ និងព័ត៌មានជាច្រើន ហើយជនជាប់ចោទមានស្នើសុំពីជនជាប់ចោទឲ្យធ្វើការឲ្យគាត់រួចខ្លួនចំពោះការចោទប្រកាន់របស់សហព្រះរាជអាជ្ញាដាក់បន្ទុកទៅលើរូបគាត់។

[១៥:១៩:០៦]

យើងឃើញថា វាមានជំហរពីរខុសគ្នា ពីខាងមេធាវីការពារក្ដី។ ចំណុចនេះ គឺវាមិនមានភាពយុត្តិធម៌សម្រាប់ពលរដ្ឋកម្ពុជានោះទេ ហើយក៏មានភាពយុត្តិធម៌សម្រាប់ជនរងគ្រោះ ហើយក៏មិនមានភាពយុត្តិធម៌សម្រាប់លោកចៅក្រមក្នុងការស្វែងរកយុត្តិធម៌។ យើងមិនឃើញមានបទប្បញ្ញត្តិណាមួយស្រដៀងនឹងវិធាន៧១ ដែលទាក់ទងលើកឡើងអំពីភាពមិនផ្ទុយគ្នា ភាពមិនយល់ស្របគ្នារវាងមេធាវីការពារក្ដី។

យើងឃើញមានហេតុជាច្រើន។ ហេតុផលមួយនោះគឺថា គឺសហព្រះរាជអាជ្ញា និង-- យើង

ឃើញមានសហព្រះរាជអាជ្ញា ហើយឃើញមានមេធាវីការពារក្តី ដែលគាត់ផ្តល់ការណែនាំទៅដល់កូនក្តីរបស់គាត់។ តាមយន្តការនេះហើយ វាអាចមានភាពមិនស៊ីគ្នា ហើយវាមានភាពផ្ទុយគ្នាទៅលើអង្គហេតុមួយចំនួនដែលយើងត្រូវយកមកពិចារណា។ នៅពេលដែល-- ប្រសិនបើមានការលើកឡើង និងបញ្ជាក់ពីជនជាប់ចោទ យើងនឹងអាចយល់ទៅលើចំណុចនេះ។

ដូច្នេះ ខ្ញុំសូមលើកឡើងឆ្លើយតបទៅចំណុចនេះពិស្តារផងដែរ ហើយខ្ញុំសូមលើកឡើងថា មានឯកសារ១៦ទំព័រ បន្ទាប់ពីសវនាការជារយៈពេល៦-៧ ខែនេះ។ យើងឃើញថា វាមានកើតចេញជាលទ្ធ-ផល ហើយនៅលើកទីមួយ ដែលដើមបណ្តឹងរដ្ឋប្បវេណី ដែលគ្មានខ្ញុំជាមេធាវីតំណាង គាត់ប្រឈមនឹងជំហរមួយជាមូលដ្ឋាន ហើយគាត់មានរយៈពេលតែម្ភៃនាទីប៉ុណ្ណោះក្នុងការឆ្លើយតបទៅលើសេចក្តីសន្និដ្ឋាន។ ហើយប្រហែលជាចំណុចនេះ វាជាអកុសលដែរ ដោយយើងមិនពិចារណាទៅលើហេតុផលជាច្រើនផ្សេងទៀត។ ហើយឃើញថាវាមានទិដ្ឋភាពជាច្រើនទាក់ទងទៅនឹងដំណើរការជំនុំជម្រះក្តីនេះ។

[១៥:២១:១៣]

មេធាវីការពារក្តី ហ្វ្រង់ស្វ័រ រូ នៅក្នុងការប្រើប្រាស់ពាក្យរបស់គាត់ដ៏សមរម្យលើកឡើងអំពីសហព្រះរាជអាជ្ញា។ ថាសហព្រះរាជអាជ្ញាមិនបានពន្យល់ឲ្យច្បាស់នៅក្នុងប្រវត្តិសាស្ត្រទាក់ទងទៅនឹងរឿងក្តីនេះ ហើយខ្ញុំនិយាយចំណុចនេះនៅក្នុងការសោកស្តាយប៉ុណ្ណោះ មិនមែនជាកំហឹងរបស់ខ្ញុំទេ។ នេះគឺជាការដាក់ជូនសេចក្តីសន្និដ្ឋានតបរបស់ខ្ញុំ។ ជនជាប់ចោទគាត់ខក ឬក៏ខ្វះឱកាស ឬក៏ខ្វះឱកាសក្នុងការនិយាយឲ្យបានច្បាស់លាស់ក្នុងការឆ្លើយតបឲ្យបានសមហេតុផល និងដោយឯកឯងនៅក្នុងសវនាការរបស់យើង។

ដូច្នេះយើងឃើញថា វាមានលើកឡើងពីខាងសហព្រះរាជអាជ្ញា ដើម្បីឲ្យមានការបញ្ជាក់ និងទទួលស្គាល់ទៅចំណុចជាច្រើន ថាតើគាត់ គឺជាប្រធានក្នុងនាមដែលបានបំពេញការងារដោយបង្ខិតបង្ខំ ឬក៏យ៉ាងម៉េច? ឬក៏គាត់ គឺជនមួយរូបដែលជាអ្នកចូលរួមនៅក្នុងរបបនេះដោយឆន្ទៈ?

លោក លោកស្រីចៅក្រម បានជ្រាបហើយ គឺជនជាប់ចោទបែរមុខចេញនៅពេលដែលមានលើកឡើងដូច្នេះ ពីសហព្រះរាជអាជ្ញា ជាជាងការដែលគាត់មើលចំទៅខាងសហព្រះរាជអាជ្ញា។ ដូច្នេះជាការឆ្លើយតបទៅលើចំណុចនេះ វាហាក់ដូចជាការឈឺចាប់ចំពោះជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីដែលហាក់ដូចជាវាបានរៀបចំនៅក្នុងចំណុចសេចក្តីសន្និដ្ឋាននេះ យើងឃើញជនជាប់ចោទបានលើកឡើង

អំពីការលើកឡើងរបស់ខ្លួន ដោយមានជើងទំព័រ និងចំណុចយោងជាច្រើន។ ហើយគាត់បានរៀបចំនៅក្នុងពេលដែលគាត់ត្រូវបំពេញការងាររបស់គាត់។

ខ្ញុំមិនទាន់បានពិនិត្យប្រតិចារឹកនៅឡើយទេ។ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំដឹងថាគាត់លើកឡើងអំពីហេតុការណ៍ដែលថា គឺគេបាញ់គាត់ ហើយនៅក្នុងមុងមានរន្ធគ្រាប់កាំភ្លើង។ ដូច្នេះ ជាការសង្ស័យរបស់គាត់ទៅលើចំណុចនេះ។ ជនជាប់ចោទគាត់បានលើកឡើងទៅចំណុចទាំងអស់នេះពីអាការៈទៅនឹងលើជនសង្ស័យ ហើយខ្ញុំអាចសន្និដ្ឋានទៅលើចំណុចនេះ ថាតើវាជាការពិតដែរឬទេ នៅពេលដែលគាត់និយាយដូច្នោះ? ហើយប្រសិនបើវាពិតមែន ខ្ញុំសូមលើកឡើងថា វាជាបទពិសោធន៍ វាស្ថិតនៅជាការសម្រេចនឹងបទពិសោធន៍របស់លោក លោកស្រីចៅក្រម ក្នុងការពិចារណាទៅលើចំណុចទាំងអស់នេះនៅពេលដែលជនបុគ្គលមួយរូបគាត់ផ្តល់ទៅលើភ័ស្តុតាងរបស់គាត់ ហើយលោក លោកស្រីចៅក្រមធ្វើការពិចារណាឲ្យល្អិតល្អន់ និងដោយឥស្សរចិត្តទៅលើករណី ដែលគាត់ថា គាត់មានភាពវិប្បដិសារី ថាតើវិប្បដិសារីទាំងអស់នោះ មានភាពស្មោះត្រង់ពិតប្រាកដដែរឬទេ?

[១៥:២៤:៣៣]

ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ដែលខ្ញុំជាមេធាវីតំណាង ពាក្យថា "ស្មោះត្រង់" នេះ វាមានសារសំខាន់ណាស់ ដោយសារវាជាធាតុផ្សំនៃការស្វែងរកការពិត។ វាមានតម្លៃធំធេង ហើយវាជាចំណុចតែមួយគត់ប៉ុណ្ណោះដែលជនរូបនេះនៅក្នុងរង់ក្រចកសេះ អាចផ្តល់ជូនបញ្ជាក់ជូនដើមបណ្តឹងរដ្ឋ-ប្បវេណី ដែលជីវិតរបស់គេត្រូវបានវាយបំបាក់ កម្ទេច និងបង្កឲ្យមានការឈឺចាប់ដោយសារតែរបបរបស់លោកជនរូបនេះដែលបានប្រតិបត្តិការនៅមន្ទីរស-២១ ជាច្រើនឆ្នាំទៅហើយនោះ។

មេធាវីការក្តី លោក ហ្រ្វង់ស្វ័រ រូ នៅក្នុងការថ្លែងសេចក្តីសន្និដ្ឋានរបស់គាត់ គាត់បានលើក ឡើងថាតើនរណាអ្នកតវ៉ាទៅលើចំណុចនេះបាន ឬក៏ទឹកភ្នែកនោះ។ យើងមិនអាចពិចារណាទៅលើទឹកភ្នែកដែលជាការសោកស្តាយថា វាជាការពិត ជាភាពសោកស្តាយពិតប្រាកដ ឬក៏យ៉ាងម៉េចនោះទេ? វាហាក់ដូចជាមានភាពស្រពិចស្រពិលទៅលើចំណុចនេះ ហើយគាត់ហាក់ដូចជាចង់ឲ្យពិចារណាទៅលើអាការៈរបស់ជនរូបនេះ ហើយខ្ញុំសូមលើកឡើងថា ភ័ស្តុតាងដែលលោក លោកស្រីត្រូវពិចារណា ហើយយើងឃើញថា មេធាវីគាត់បានលើកឡើងអំពីវិធាន៨៧.២ យើងត្រូវយល់អំពីតម្លៃនៃភ័ស្តុតាងដែលបានដាក់ចំពោះមុខអង្គសវនាការ។ ដូច្នេះហើយខ្ញុំសូមដាក់ជូនដូច្នេះថា ត្រូវពិចារណាទៅលើចំណុចនេះ។ គឺការលើកឡើងរបស់មេធាវីការពារក្តី មិនមានភាពទាក់ពាក់ព័ន្ធ គ្រាន់តែជាការលើកឲ្យល្អមើលតែប៉ុណ្ណោះ

ហើយវាគ្រាន់តែជាការសន្និដ្ឋានទៅលើការបាក់ទឹកចិត្តរបស់ជនជាប់ចោទ។ នេះគឺជាតុលាការច្បាប់សម្រេចទៅតាមផ្លូវច្បាប់ មិនមែនជាវេទិកាសន្និដ្ឋានទៅលើឧបមានវិធី និងការសន្និដ្ឋាននោះទេ។

នៅដំណាក់ចុងក្រោយយើងនេះ ហើយខ្ញុំដឹងថា លោក លោកស្រីចៅក្រមនឹងពិចារណាឲ្យបានច្បាស់លាស់នៅចំណុចទាំងនេះនៅដំណាក់កាលចុងក្រោយ។

លោក លោកស្រីចៅក្រម, ទាក់ទងទៅនឹងទឹកភ្នែកទឹក ដែលបង្ហូរចេញនេះ ថាតើវាពាក់ព័ន្ធ ឬក៏មានតម្លៃយ៉ាងណា? យើងត្រូវពិចារណាទៅលើសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី គាត់លើកឡើងថាជនជាប់ចោទ បាននិយាយបីដង ហើយលោក លោកស្រីចៅក្រម បានឮជាច្រើននូវសក្ខីកម្មរបស់គាត់ ហើយនៅក្នុងប្រតិចារឹក ក៏យើងឃើញមាននៅក្នុងដំណាក់កាលជាច្រើន ដែលខ្ញុំបានមើលទៅលើប្រតិចារឹក ដែលខ្ញុំមិនបានចូលរួមនៅទីនេះ ដោយសារតែខ្ញុំជាប់រវល់នៅទីក្រុងឡាអេ ហើយវាហាក់ដូចជាមិនមានអារម្មណ៍រំជើបរំជួលទៅលើការសម្តែងនូវទឹកភ្នែកទាំងអស់នោះទេ ដែលយើងត្រូវពិចារណាទៅលើភ័ស្តុតាងជាច្រើនដែលគេបានផ្តល់ទៅលើចំណុចទាំងអស់នេះ ហើយយើងគិតថា តើភ័ស្តុតាងទាំងអស់នោះ វាសមស្របដែរឬទេ តាមសំណួរដែលតាំងដោយលោក លោកស្រីចៅក្រម។ ហេតុអ្វីបានជាវាពាក់ព័ន្ធ? អ៊ីចឹងវាជាចំណុចទាំងឡាយ ដែលយើងឃើញថា វាមានចំណុចតិចតែប៉ុណ្ណោះ ទៅលើភ័ស្តុតាង ប៉ុន្តែនៅពេលនេះយើងមានច្រើន ហើយយើងត្រូវសួរ ថាតើជនរូបនេះគាត់មានការសម្តែងយ៉ាងម៉េចទៅលើចំណុចទាំងអស់នេះ ហើយជាពិសេសទៅលើការឆ្លើយតបរបស់ជនរូបនេះ ដែលជាការដែលគួរឲ្យសោកស្តាយ ហើយគឺគាត់ហាក់ដូចជា គាត់មិនចង់ទទួលយកចំណុចទាំងអស់នេះ ហើយគាត់មិនបានបញ្ជាក់ឲ្យបានច្បាស់ នៅពេលដែលគាត់ចង់លេបទៅលើអ្វីដែលបានកើតឡើងនោះ។

[១៥:២៨:៣០]

នៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្ញុំ ទំហំនៃទឹកភ្នែក ហើយយើងមិនដឹងថាតើទឹកភ្នែករបស់គាត់បង្ហូរប៉ុន្មានដងទេ គឺវាមិនពាក់ព័ន្ធឡើយ ប៉ុន្តែនៅដំណាក់កាលចុងក្រោយ យើងមិនត្រូវគិតថាតើទទួលយកបាន ឬមិនទទួលយកបាននោះទេ យើងត្រូវពិចារណាទៅលើបុគ្គលរូបនេះ ថាតើគាត់យ៉ាងម៉េច? យើងបានឮឡើយហើយ ការប្តូរសាសនារបស់ជនជាប់ចោទ។ ដូច្នេះ យើងត្រូវពិចារណាទៅលើឃ្លាឃ្លោងដែលបានលើកឡើង ប៉ុន្តែការដាក់ទណ្ឌកម្មគឺជាចំណុចមួយដែលព្រះអាចជួយជនរូបនេះបាន។ ដូច្នេះ គាត់បានផ្លាស់ប្តូរទៅលើសាសនា។ ដូច្នេះ ការទទួលស្គាល់ទៅលើចំណុចទាំងអស់នេះ មិនមែននៅថ្ងៃនេះទេ។

នៅក្នុងរឿងក្តីនេះ យើងត្រូវឲ្យមានសេចក្តីសម្រេចឲ្យបានច្បាស់លាស់ទៅលើឧក្រិដ្ឋកម្មដែលបានកើតឡើង ហើយវាពាក់ព័ន្ធទៅនឹងអង្គហេតុទាំងអស់នេះហើយ ដែលលោក លោកស្រីចៅក្រមត្រូវមានកាតព្វកិច្ចក្នុងការបំពេញតួនាទីក្នុងសម្រេច។ មិនមែនជាការស្រមើលស្រម៉ៃ មិនមើលទៅលើភ័ស្តុតាងនោះទេ។ ហើយលោក លោកស្រីចៅក្រម ត្រូវមានបទពិសោធន៍រៀងៗខ្លួន ដើម្បីពិចារណាទៅលើអង្គហេតុទាំងអស់នេះ។ បញ្ហាចម្បងសំខាន់ ដែលយើងត្រូវពិនិត្យនោះ ពីម្សិលមិញជនជាប់ចោទបាននិយាយថា សេចក្តីសម្រេចដែលថា តើផ្លូវណាត្រូវដើរនោះ គឺបង្កើនខណៈពេលមួយ ថាតើផ្លូវនោះវាវែងចម្ងាយណា ប្រើពេលប៉ុនណា? ជាសំខាន់យើងត្រូវចាំថា មិនមែនជាពេលវេលាដែលកន្លងផុតទៅនេះ ជាពិសេសនៅក្នុងករណីនេះ វាត្រូវមានផលវិបាកសោកនាដកម្ម គឺជាករណីដែលថាម្នាក់ៗបានជួបប្រទះនូវជោគវាសនាអាក្រក់ដោយការសម្លាប់។ ប៉ុន្តែ ជនជាប់ចោទនិយាយថា នៅក្នុងរយៈពេលបីឆ្នាំ ប្រាំខែ ស-២១នោះ គឺថាគាត់មានឱកាសរៀងរាល់ថ្ងៃក្នុងការធ្វើសេចក្តីសម្រេចរបស់ជនរងគ្រោះ ១២.៣៨៣ នាក់នោះ គឺថាគាត់មានរយៈកាលចំនួនប៉ុណ្ណឹងដែរ ដែលថាជនជាប់ចោទគាត់អាចធ្វើសម្រេចឲ្យបានត្រូវ។

ចំពោះភ័ស្តុតាងដែលមានដ៏លើសលប់នៅក្នុងបណ្ណសារនៃស-២១ យើងនិយាយជូនជនជាប់ចោទថា ដូចដែលភ័ស្តុតាងយើងលើកឡើងកាលពីម្សិលមិញ ដែលបានបញ្ជាក់ដែលថាមានបញ្ហាខ្វែង មានបញ្ហាមិនច្បាស់លាស់ ដែលលើកឡើងដោយមេធាវីការពារ។ បញ្ហាពីម្សិលមិញខ្ញុំសូមលើកឡើងទាក់ទងទៅនឹងសេចក្តីសន្និដ្ឋានរបស់លោកមេធាវី ការ សាវុត្ថ ទាក់ទងទៅនឹងអាជ្ញាយុកាល។

ខ្ញុំមិនមានពេលនិយាយទេ ខ្ញុំនឹងពឹងផ្អែកទៅលើសេចក្តីសន្និដ្ឋានរបស់យើងដែលបានដាក់ជូនអង្គជំនុំជម្រះ។ ទាក់ទងទៅនឹងករណីដែលថា គោលជំហររបស់មេធាវីការពារនោះ គឺយើងបានសម្តែងហើយ ប៉ុន្តែការខ្វះ-- ដែលថាជនជាប់ចោទមិនមានការទទួលខុសត្រូវខ្ពស់ ដោយថាគាត់មិនមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតទេ ហើយខ្ញុំ យើងមើលវិធាន៨៩ ដែលនិយាយអំពីអញ្ញត្រកម្មនោះ គឺត្រូវតែធ្វើឡើងក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីដីកាដំណោះស្រាយ ប៉ុន្តែគឺវាអាស្រ័យទៅលើច្បាប់ករណីជាច្រើនដែលបង្ហាញថា ជនជាប់ចោទមិនអាចលើកឡើងអំពីការសារភាពទោសកំហុសនៅក្នុងករណីនោះ។

[១៥:៣២:២១]

ជនជាប់ចោទបាននិយាយតាមរយៈមេធាវីរបស់គាត់ម្សិលមិញនោះថា គាត់គឺជាជនរងគ្រោះនៃរបបនោះ គាត់ជាអ្នកបម្រើរបបនោះ ប៉ុន្តែយើងមិនអាចជឿបានទេ ទៅតាមលក្ខខណ្ឌ និងអំពើដែល

ទាក់ទងទៅនឹងជនរងគ្រោះដើម្បីនឹងស្វែងរកយុត្តិធម៌។ ប៉ុន្តែ ខ្ញុំមិនមានពេលគ្រប់គ្រាន់ដើម្បីសម្តែងនោះទៀតទេ។ ប៉ុន្តែ មីឡូសឺវិច បានឃោគទៅនេះដែរ។ ប៉ុន្តែនេះជារឿងក្តីទីមួយនៅក្នុងតុលាការ *អាយស៊ីធីវ៉ាយ* គឺរឿងក្តី *វិចថាឌិច* (?) នោះ។ នៅក្នុងតុលាការ *អាយស៊ីធីវ៉ាយ* នោះ គឺមានមេធាវីអន្តរជាតិ អន្តរជាតិមួយចំនួន ក៏បានគាំទ្រទៅលើយុត្តាធិការនៅក្នុងករណីនោះ ដើម្បីចំណុចមួយដែលថា ជនជាប់ចោទមានការទទួលខុសត្រូវយ៉ាងវែងឆ្ងាយ។

មេធាវី រូ បាននិយាយថា គាត់មិនដែលបាននិយាយបន្ទោសទៅមេរបស់គាត់ទេ ប៉ុន្តែលើកដាក់ការទទួលខុសត្រូវទៅឲ្យពួកអ្នកយាម។ ប៉ុន្តែមិនមែន ឌុច ទេ ដូចដែលមេធាវី ការ សាវុត្ថ បានលើកឡើងនោះ អានេះគឺមិនត្រឹមត្រូវ។ ហើយនិយាយថា ជនជាប់ចោទមិនមានស្វ័យសម្រេច មិនមានសិទ្ធិសម្រេច ដូចជានៅក្នុងប្រតិចារឹកដែលថាលោក ហ្វ្រង់ស្វ័រ រូ បានលើកឡើងមក ពាក់ទាក់ទងទៅនឹងលោក ដេវីដ ឆេនដ៏ល័រ។ លោក ឆេនដ៏ល័រ គាត់និយាយថា គាត់មិនជឿថា លោកជនជាប់ចោទមិនមានស្វ័យភាពនោះទេ។ ទាក់ទងនឹងករណីសហកម្មឧក្រិដ្ឋកម្មរួមវិញ ខ្ញុំជូនសេចក្តីសង្ខេបមួយក្នុងពេលដែលសេសសល់នេះ។

រឿងក្តីមួយបានយោងដោយសហព្រះរាជអាជ្ញានោះ ក្នុងរឿងក្តី *អាយស៊ីធីអ័រ* របស់រឿងក្តីរបស់ សេរ៉ុមបា នៅថ្ងៃទី១២ មីនា ឆ្នាំ២០០៨ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នោះ គឺថាបញ្ជាបញ្ជាក់ថាករណីដែលជនជាប់ចោទ មិនមែនជាអ្នកបើក ប៊ុលដូស្ស័រ ដើម្បីរុញព្រះវិហារចោលទេ ប៉ុន្តែគាត់បានធ្វើមានអំណាចទៅលើ អ្នកបើកបរគ្រឿងចក្រនោះ ដើម្បីឲ្យបំផ្លាញវិហារ ហើយគាត់ត្រូវទទួលខុសត្រូវចំពោះបទបញ្ជា ដែលបានគាត់ធ្វើអ៊ីចឹងពេលនេះ។ នៅក្នុងរឿងក្តីនោះ អង្គតុលាការសម្រេចថា អ្នកបញ្ជានោះ មានពិរុទ្ធភាពពីបទបញ្ជានោះ ប៉ុន្តែនៅក្នុងករណីនេះគឺថា មេធាវីការពារលើកឡើងថា ជនជាប់ចោទមិនមានដៃប្រឡាក់ឈាមទេ គឺកូនចៅរបស់គាត់ ជាអ្នកប្រឡាក់ឈាម ប៉ុន្តែផ្អែកទៅលើយុត្តសាស្ត្ររបស់ *អាយស៊ីធីអ័រ* នេះ គឺអង្គជំនុំជម្រះគប្បីតែសម្រេចផ្អែកលើនោះ គឺជាជនជាប់ចោទត្រូវតែមានពិរុទ្ធភាព ពីការដែលគាត់បញ្ជាកូនចៅរបស់គាត់នោះ។

[១៥:៣៥:០៤]

៣០ឆ្នាំ បន្ទាប់ពីហេតុការណ៍នោះកើតឡើង ដើមបណ្តឹងរដ្ឋប្បវេណីរង់ចាំការពិត គេមិនចង់បានជីវិតអ្នកដែលស្លាប់នោះមកវិញទេ គឺចង់បានការពិត ចង់បានយុត្តិធម៌។ គឺមិនត្រូវឲ្យស្ថានភាពហ្នឹងស្ថិតនៅក្នុងភាពមិនច្បាស់លាស់នោះទេ អ្វីដែលបានលើកឡើង គឺថាលោក រូ បញ្ជាក់ថា ជនជាប់ចោទបាន

សម្ដែងការសារភាពពីពិរុទ្ធភាព ប៉ុន្ដែមិនមែនក្នុងករណី អាល់ប៊ឺត ស្ពៀរ ដែលអ្វីដែលយើងលើកឡើងនោះ។ យើងមិនគ្រាន់តែអាចនិយាយថា ទទួលស្គាល់ គឺថាអាចនឹងចៀសវាងបាន នៅក្នុងករណីដែលខ្លួនដោះសានោះ។

ការពិតនិងយុត្តិធម៌ គឺមានតម្លៃបំផុតដែលកម្ពុជាចង់បាន ហើយដើមបណ្ដឹងរដ្ឋប្បវេណីក៏ចង់បាន ហើយខ្ញុំនឹងទុកចិត្តថា តុលាការនឹងអនុវត្តការប្រុងប្រយ័ត្ននិងវិចារណញ្ញាណ ដើម្បីសម្រេចស្របទៅតាមការអះអាង និងសំណើរបស់យើងខ្ញុំ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ជាបន្តសូមអញ្ជើញមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមពីរ។

**លោកស្រី ស៊ីលឃិ ស្ទូតហ្សីនស្គី៖**

សូមអរគុណ សូមគោរពលោកប្រធាន លោកស្រីចៅក្រម, ខ្ញុំសូមនិយាយតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ដែលអកុសលសហការីកម្ពុជាររបស់ខ្ញុំ លោក គង់ ពិសី គាត់មិនមានវត្តទេ ដូច្នេះគឺថាខ្ញុំនឹងនិយាយតែម្នាក់ឯងសម្រាប់ក្រុមពីរទាំងមូលតែម្ដងថ្ងៃនេះ។

សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់មេធាវីការពារក្ដី ដែលថាមិនមានការសារភាពចំពោះពិរុទ្ធភាពនេះ យើងមិនជឿទាល់តែសោះចំពោះជនជាប់ចោទ ដែលគាត់ហាក់បីដូចជាបានទះកំផ្លៀងដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏អាចនិយាយបានថា ទះកំផ្លៀងទៅលើជនរងគ្រោះទាំងអស់ផង។

ដើមបណ្ដឹងរដ្ឋប្បវេណីហាក់មានភាពរន្ធត់ណាស់នៅពេលដែលឮសួរ លោក ការ សាវុត្ថ និយាយថាគាត់មិនមានពិរុទ្ធភាព។ ខ្ញុំហាក់បីដូចជាភាំងនៅពេលដែលឮសួរបែបនេះ ដែលសុំឲ្យដោះលែងជនជាប់ចោទជាបន្ទាន់ ដូចដែលជនជាប់ចោទ ហើយនិងមេធាវីការពារក្ដីព្យាយាមអូសទាញដើម្បីបង្ហាញថា អ្វីដែលគាត់និយាយការសារភាពនេះ គឺថាជាការពិត ជាការស្មោះត្រង់។ ឥឡូវនេះ ដើមបណ្ដឹងរដ្ឋប្បវេណីហាក់មានវិមតិសង្ស័យថា គឺជនជាប់ចោទកំពុងតែលេងល្បែងមួយនៅក្នុងពេលឱកាសនេះ។

នៅពេលខ្ញុំសូមចូលទៅដល់ទឡ្ហីករណ៍ ដែលមេធាវីការពារក្ដីជាតិបានលើកឡើងកាលពីម្សិលមិញថា ហេតុអីបានជាគាត់មិនទទួលសារភាពចំពោះពិរុទ្ធភាពនេះ មេធាវីជាតិបានអះអាងទៅលើយុត្តាធិការរបស់តុលាការនេះ ហើយបានជំទាស់ថា កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ក៏ដូចជាច្បាប់របស់ អ.វ.ត.ក គឺមិនអាចអនុវត្តបានទេ សម្រាប់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តអំឡុងក្នុងឆ្នាំ១៩៧៤ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយមួយទៀតជនជាប់ចោទគឺថាមិនមែនជាអ្នកដឹកនាំជាន់ខ្ពស់ ឬក៏ជា

អ្នកទទួលខុសត្រូវជាន់ខ្ពស់នោះទេ។ មេធាវីការក្តីជាតិក៏បានធ្វើការជំទាស់តវ៉ាទៅលើយុត្តាធិការផងដែរ។ យោងទៅតាមវិធាន៨៩ ដែលការការពារបែបនេះអាចលើកឡើងតែនៅក្នុងសវនាការបឋមតែប៉ុណ្ណោះ។ [១៥:៣៩:៤១]

នៅថ្ងៃទី១ មេសា ២០០៩ នៅក្នុងទំព័រ២១៩ មេធាវីការពារក្តីបញ្ជាក់ថា គាត់មិនមានចេតនាបដិសេធចំពោះយុត្តាធិការទេ ខ្ញុំសូមដកស្រង់សម្តីដូចតទៅនេះ៖

“នៅពេលសហព្រះរាជអាជ្ញា ថាតើការជំទាស់ការតវ៉ាទៅលើយុត្តាធិការនោះ ខ្ញុំមិនមានបំណងជំទាស់ទេដោយសារខ្ញុំដឹងរួចទៅហើយ ហើយខ្ញុំបានលើកចំណុចនេះនៅក្នុងសវនាការបឋមរួចទៅហើយ ប្រសិនបើខ្ញុំចង់ធ្វើដូច្នេះ។ ដូច្នេះ អ្វីដែលខ្ញុំចង់និយាយ ខ្ញុំចង់ធ្វើការជំទាស់ការតវ៉ាទៅលើយុត្តាធិការបុគ្គលនោះទេ ខ្ញុំចង់ឲ្យតុលាការអនុវត្តទៅតាមវិធានផ្ទៃក្នុង៨៩.៧ ដែលគាត់គឺបុគ្គលម្នាក់មួយទទួលខុសត្រូវជាន់ខ្ពស់ ហេតុដែលគាត់មិនមែនជាអ្នកទទួលខុសត្រូវជាន់ខ្ពស់ដែលត្រូវទទួលការផ្តន្ទាទោសនោះទេ។ ខ្ញុំគិតថា នេះគ្រាន់តែជាគំនិតយោបល់របស់ខ្ញុំដាក់ជូនតុលាការដើម្បីធ្វើការពិចារណា”។

ខ្ញុំសូមលើកឡើងថា ជាលទ្ធផលយើងអាចឆ្លើយតបទៅនឹងសំណើក្នុងការបដិសេធ ដែលយើងមិនអាចទទួលបាននៅក្នុងដំណាក់កាលនីតិវិធីនេះទេ ប៉ុន្តែ សារណាទាក់ទងទៅនឹងសេចក្តីសម្រេចវិធាន៩៨.៧។

ទីមួយគឺយើងកត់សម្គាល់ឃើញថា ដែលកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ប្រទេសកម្ពុជាដែលត្រូវបានផ្តល់សច្ចាប័នដោយ ហើយក៏ដូចជាច្បាប់បង្កើត អ.វ.ត.ក ច្បាប់ស្តីអំពីការដាក់របបកម្ពុជាប្រជាធិបតេយ្យឲ្យនៅច្បាប់ ដោយច្បាប់នេះគឺថាមានគោលបំណងដើម្បីផ្តន្ទាទោសមេដឹកនាំខ្មែរក្រហមដែលជាអ្នកបន្តធ្វើការប្រយុទ្ធតទៅទៀតនោះ ដែលមិនមានចេតនាចង់ធ្វើសមាហរណកម្មចូលមករួមរស់ជាមួយរដ្ឋាភិបាលវិញ។ ប៉ុន្តែ ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដូចជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្ស ឬក៏ឧក្រិដ្ឋកម្មសង្គ្រាម។ ហេតុដូច្នេះ ច្បាប់ អ.វ.ត.ក គឺមានយុត្តាធិការត្រឹមត្រូវ មានសុពលភាពដោយសារតែអត្ថិភាពនៃច្បាប់នេះ។ ច្បាប់បង្កើត អ.វ.ត.ក មានគោលបំណងផ្តន្ទាទោសថ្នាក់ដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែល រំលោភធ្ងន់ធ្ងរប៉ុណ្ណោះ។

ទីពីរ យុត្តធិការបុគ្គលលើច្បាប់របស់ អ.វ.ត.ក គឺផ្តន្ទាទោសទៅលើថ្នាក់ដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់។ ដោយពិចារណាទៅលើអ្នកទទួលខុសត្រូវខ្ពស់ម្នាក់ ទាក់ទងទៅនឹងទស្សនទានខាងផ្លូវច្បាប់ដែលត្រូវយកមកពិចារណាដោយការិយាល័យសហព្រះរាជអាជ្ញា ដែលការិយាល័យនេះបាន

សម្រេចថា លក្ខណៈវិនិច្ឆ័យសម្រាប់ទស្សនៈនេះ គឺមាននៅក្នុងចំណោមឧក្រិដ្ឋកម្មជាច្រើនទៀត។ ភាពឃោរឃៅអំឡុងពេលដ៏វែងឆ្ងាយក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ហើយនិងអំណាចក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។ ឆន្ទានុសិទ្ធិគឺត្រូវបានលើកឡើងយកមកនិយាយ។ ជនជាប់ចោទគឺថាឋិតនៅក្រោមការត្រួតត្រារបស់គណៈអចិន្ត្រៃយ៍ដែលជាស្ថាប័នមួយខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ ហើយដែលបានសម្លាប់មនុស្សយ៉ាងហោចណាស់ ក៏សម្លាប់មនុស្ស ១២.៣៨២ នាក់ផងដែរ។ អង្គហេតុទាំងអស់នេះគឺថា អាចឲ្យយកមកពិចារណាថាគាត់គឺជាមនុស្សម្នាក់ដែលជាប់ពាក់ព័ន្ធទៅនឹងអ្នកដែលមានអំណាចខ្ពស់បំផុត មិនមែនគ្រាន់តែជាឧបករណ៍មួយដាច់ថ្លៃមួយប៉ុណ្ណោះទេ។

ទីបី មេធាវីការពារក្តីអះអាងថា មេពន្ធនាគារដទៃទៀតក៏ត្រូវយកមកផ្តន្ទាទោសដូចគ្នាដែរ យោងតាមយុត្តាធិការរបស់តុលាការ។ មេធាវីការពារក្តីយោងទៅតាមមាត្រា៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាដែលប្រជាជនកម្ពុជាត្រូវតែមានសិទ្ធិស្មើៗគ្នានៅចំពោះមុខច្បាប់។ មេធាវីការពារក្តីមិនបានយល់ទៅលើមាត្រានេះទេ ដែលមាត្រានេះគឺផ្តល់សិទ្ធិស្មើៗគ្នាឲ្យប្រជាពលរដ្ឋ នៅចំពោះមុខច្បាប់ មិនមែនធានាសិទ្ធិដែលថាស្មើគ្នានៅក្នុងភាពអយុត្តិធម៌នោះទេ សិទ្ធិនេះមិនមានទេ។

[១៥:៤៤:១១]

ផ្ទុយទៅវិញ ស្ថិតនៅក្នុងស្ថានភាពមួយដែលអយុត្តិធម៌ ខ្ញុំសូមបន្ថែម ជនជាប់ចោទមិនអនុញ្ញាតទាមទារនូវការប្រព្រឹត្តិស្មើៗឲ្យបានដូចៗគ្នានោះទេ ដូចជា គណៈកម្មាធិការសិទ្ធិមនុស្សបានដាក់ចេញនូវមាត្រា២៨ នៃកតិកាសញ្ញាស្តី អំពីសិទ្ធិ និងសិទ្ធិពលរដ្ឋ និងនយោបាយ ដែលបានអនុម័តនៅថ្ងៃទី២៣ សីហា ២០០៤ នៅក្នុងករណីនៅប្រទេសអូទ្រីស។ ខ្ញុំសូមដកស្រង់៖ “មាត្រា២៦ នៃកតិកាសញ្ញានេះគឺថាមិនអាចទៅរកឃើញបានទេនៅក្នុងស្ថានភាព ដែលមិនអាចយកមកធ្វើការប្រៀបធៀបគ្នាបានក្នុងពេលដែលមិនមានសិទ្ធិស្មើគ្នានៅក្នុងយុត្តិធម៌នោះទេ។ យោងតាមទៅលើតុលាការធម្មនុញ្ញនីត្យានុកូលភាពនៃសេចក្តីសម្រេចនេះ គឺថាអាចនឹងជំទាស់តវ៉ាបាន ដោយយោងទៅលើមូលដ្ឋាននៃច្បាប់ទាំងអស់នេះទាក់ទងទៅនឹងការដាក់ទណ្ឌកម្ម ការប្រព្រឹត្តមិនបានត្រឹមត្រូវនៅក្នុងរឿងប្រហាក់ប្រហែលគ្នានេះ ឬអាចនិយាយបានថា ច្បាប់ទាំងឡាយណាដែលមិនអាំចអនុវត្តបាននូវគោលការណ៍នៃច្បាប់នេះ គឺមិនអាចយកមកអនុវត្តបានទេ។ នេះគឺជាចេតនាទាក់ទងទៅនឹងសមភាពគ្នាចំពោះមាត្រា២៦ នៃកតិកា-សញ្ញានេះ”។

ដើម្បីនិយាយឲ្យងាយស្តាប់ទៅជនជាប់ចោទមិនអាចអះអាងថា គាត់មិនអាចទទួលការផ្តន្ទាទោស

ដោយសារថា អ្នកដទៃទៀតមិនត្រូវយកមកផ្តន្ទាទោសនោះទេ។

ទីបួន ការទាមទាររបស់មេធាវីការពារក្តីជាតិនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាក់ទងទៅនឹងចំនួនអ្នកទោស ឬការកាប់សម្លាប់មនុស្ស នេះគឺថាការបំភ្លេចនូវតម្លៃរបស់ជីវិតមនុស្ស តម្លៃរាល់តម្លៃជីវិតជនរងគ្រោះទាំងអស់ ក៏ដូចជាក្រុមគ្រួសាររបស់គេ។ ពេលដែលជីវិតមនុស្សបាត់បង់ទៅ គឺថាមានន័យថា ចប់ហើយ។ ស-២១ គឺវាពិសេសជាងគេ ហើយដូចជាជនជាប់ចោទបានសារភាពពីម្សិលមិញ គឺថាជាទីមួយហើយដែលពន្ធនាគារនេះពិសេសជាងគេ វាជាពន្ធនាគារកម្រិតខ្ពស់ ចិតនៅក្រោមការគ្រប់គ្រងរបស់គណៈអចិន្ត្រៃយ៍ ប៉ុន្តែមានហេតុផលច្រើនទៀត ថាហេតុអីបានជាស-២១ វាពិសេសជាងគេ? ដោយសារឈ្មោះរបស់វា ប្រធាន ស-២១ គឺមានភាពជិតដិតជាមួយមេដឹកនាំជាន់ខ្ពស់នៃរបបនោះ គណៈអចិន្ត្រៃយ៍ ហើយស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់គណៈអចិន្ត្រៃយ៍។

ជាចុងក្រោយ តែមិនមែនជាចុងបញ្ចប់ទេ មុខងាររបស់ស-២១ គឺថាប្រតិបត្តិការនៅក្នុងកម្រិតមួយខ្ពស់ ដែលមានបុគ្គលិករបស់ពន្ធនាគារនេះច្រើន ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពចិតនៅក្រោមកណ្តាប់ដៃរបស់ជនជាប់ចោទ។

[១៥:៤៨:១៥]

ទីប្រាំ មេធាវីការពារក្តីជាតិ គាត់និយាយថា ជនជាប់ចោទមិនអាចត្រូវបានផ្តន្ទាទោសទេ ដោយសារថា គាត់ធ្វើតាមតែបញ្ជារបស់មេតែប៉ុណ្ណោះ។ ច្បាប់ អ.វ.ត.ក បានចែងយ៉ាងច្បាស់នៅលើមាត្រាទី ២៩ ខ្ញុំសូមដកស្រង់៖ “ការដែលជនសង្ស័យ ធ្វើតាមបញ្ជារបស់របបកម្ពុជាប្រជាធិបតេយ្យ ឬក៏ថ្នាក់ដឹកនាំជាន់ខ្ពស់ គឺថាមិនអាចចាត់ទុកថាជនជាប់ទទួលខុសត្រូវតែឯងនោះទេ”។ មេធាវីការពារក្តីប្រាប់ថា ជនជាប់ចោទមិនមានពិរុទ្ធភាព ដោយសារគាត់ធ្វើតាមបញ្ជារបស់មេនេះ គឺថាមិនអាចច្រានចោលនូវពិរុទ្ធភាពរបស់គាត់បានទេ។ វាអាចគ្រាន់តែជាយកមកធ្វើជាស្ថានសម្រាលទោស តែមិនអាចច្រានចោលនូវបទចោទនេះបានទេ។

នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់របស់ខ្ញុំ ក៏ដូចជាខាងសហព្រះរាជអាជ្ញា ក៏បានលើកឡើងលម្អិតដែលរួមបញ្ចូលនៅការយោងផ្សេងៗចំពោះការជាប់ពាក់ព័ន្ធរបស់ជនជាប់ចោទដែលគាត់មានការត្រេកត្រអាលសាទរក្នុងការប្រព្រឹត្តិឧក្រិដ្ឋនេះ។

ជាថ្មីម្តងទៀត ការដែលអះអាងថាគាត់ជាជនរងគ្រោះនៃរបបនេះ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះទាំងមូល ដូចសហព្រះរាជអាជ្ញាបានលើកឡើង និងបានអះអាងហើយថា ទឡ្ហីករណ៍ដែលជន

ជាប់ចោទស្ថិតនៅក្រោមការគំរាមកំហែងដល់អាយុជីវិតរបស់គាត់នោះ ដែលថាគាត់ត្រូវបានគេបង្ខិតបង្ខំ គឺមិនមែនជាការអះអាងមួយមានប្រសិទ្ធភាពនោះទេ។

ជនជាប់ចោទត្រូវសួរខ្លួនឯងថា តើគាត់អាចអះអាងថា គាត់មិនមានពិរុទ្ធភាព។ នៅពេលដែលដំបូង គាត់បានសារភាពថា ឧក្រិដ្ឋកម្មទាំងអស់នេះ គឺថាបានប្រព្រឹត្តនៅស-១២ ក្រោមការគ្រប់គ្រងរបស់គាត់។ ចម្លើយគឺថា គាត់ចង់ឲ្យទ្វារទាំងអស់នោះបើកចំហដែលអនុញ្ញាតឲ្យគាត់លេងល្បែងមួយដើម្បីទទួលស្គាលនសម្រាលទោស សម្រាប់ការផ្តន្ទាទោសនៅក្នុងករណីដែលតុលាការអាចនឹងផ្តន្ទាទោសគាត់ ហើយគាត់បានសារភាពដោយស្មោះត្រង់ ដូចដែលគាត់មិនអាចគេចផុតពីការទទួលខុសត្រូវពីឧក្រិដ្ឋកម្មទេ ដែលមានតែអង្គការទេដែលជាអ្នកទទួលខុសត្រូវ។ មធ្យោបាយដែលងាយបំផុតដែលក្នុងទម្លាប់កំហុស ការទទួលខុសត្រូវទៅឲ្យអ្នកស្លាប់បាត់បង់ទៅហើយ ហើយនិងអង្គការ គឺបង្ហាញថាគាត់អនុវត្តនូវបន្ទុកដ៏ធ្ងន់ធ្ងរនេះ ហើយឧក្រិដ្ឋកម្មដែលទាំងអស់នេះ ដែលគាត់បានប្រព្រឹត្ត គាត់ត្រូវទទួលខុសត្រូវ។

[១៥:៥១:០៤]

ការប្រើប្រាស់យុត្តិសាស្ត្រដោយមេធាវីការពារក្តីរបស់គាត់ គឺជាឧទាហរណ៍មួយដែលមិនល្អសម្រាប់ចារីដទៃទៀតក្នុងការគេចចេញពីការទទួលខុសត្រូវ នេះមិនមែនជាការមួយចូលរួមទៅដល់ដំណើរការផ្សះផ្សានោះទេ។ ផ្ទុយទៅវិញ ដើមបណ្តឹងរដ្ឋប្បវេណីដែលស្វែងរកយុត្តិធម៌ និងការពិត គឺហាក់បីដូចជាមានការត្រូវបានជនជាប់ចោទ គឺថាវាយបកយ៉ាងធ្ងន់ធ្ងរ។ ដើម្បីបញ្ចប់យុត្តិសាស្ត្ររបស់មេធាវីការពារក្តីនេះ គឺផ្ទុយទាំងស្រុងទៅនឹងអ្វីដែលជនជាប់ចោទថា ខ្លួនមានវិប្បដិសារីដោយស្មោះត្រង់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានចូលរួមស្តាប់ដ៏យូរមកហើយនេះ គឺថាវិប្បដិសារី ក៏ដូចជាសំណើររបស់ជនជាប់ចោទ ដើម្បីផ្តល់នូវការអភ័យទោស ដូចជាពីម្សិលមិញផងដែរ គឺគាត់ទាមទារចង់ចូលរួមរស់នៅក្នុងសង្គមជាតិកម្ពុជាវិញនោះ គឺថាត្រូវតែច្រានចោល។

ខ្ញុំសូមអរគុណអង្គជំនុំជម្រះ។ សូមជូនវេទិកានេះទៅសហការីរបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី។

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមគោរពលោក លោកស្រី ចៅក្រម, ខ្ញុំនឹងធ្វើសេចក្តីថ្លែងតបមុនរយៈពេលប៉ុន្មាននាទី បន្ទាប់

មកសហសេវិករបស់ខ្ញុំ ហ្វីលីព កាណុន នឹងធ្វើសេចក្ដីសន្និដ្ឋានតបបន្ត។

លោក ឌុច លោកបានរៀបរាប់ ហើយលោកកឆ្លៀតយកឱកាសនេះដើម្បីបង្ហាញនូវវិប្បដិសារីរបស់លោកក្នុងពេលសវនាការ ដែលថាសវនាការនេះវាមានលក្ខណៈកត់ត្រាជាប្រវត្តិសាស្ត្រអំពីរបបកម្ពុជាប្រជាធិបតេយ្យដែលបានគ្រប់គ្រង។ ប៉ុន្តែលោក ឌុច លោកមិនអាចធ្វើដូច្នោះបានទេ។ ខ្ញុំមិនបានឮការសោកស្ដាយ ការសុំទោស និងការអត់ឱនទាំងឡាយពីជនរងគ្រោះនោះទេ។ ដោយសារតែលោកមិនបានបញ្ជាក់ទៅលើពាក្យទាំងអស់នេះឲ្យបានច្បាស់លាស់ ជាពិសេសទៅលើការបញ្ជាក់អំពីគោលនយោបាយកម្ទេចខ្មាំងនៃរបបនយោបាយដែលលោកបានចូលរួមដោយមានភាពក្លៀវក្លានិងពេញចិត្ត ពេញថ្លើម ដោយមិនមានការចោទសួរទៅលើរបបនោះ។

[១៥:៥៣:៥៧]

លោក ឌុច លោកមិនមែនជាអ្នកទទួលថ្នបាក់នោះទេ ដោយសារតែវាមានលក្ខណៈជាក់ស្ដែង។ លោកគឺជាតំណាងរបស់របបនេះ។ ហើយលោកគឺអ្នកបង្កទៅដល់ជនរងគ្រោះ ហើយដែលគេកំពុងតែចង់ទៅលើការទទួលខុសត្រូវរបស់លោកចំពោះករណីទាំងអស់នេះ។ ដូច្នេះ ហើយលោកមិនត្រូវធ្វើការលើកឡើងថា លោកមិនមានទោស ហើយសុំឲ្យតុលាការអនុញ្ញាតនោះទេ។ លោកជាអ្នកបង្កើតភាពភ័យខ្លាច លោកដកទៅលើភាពអមនុស្សធម៌របស់មនុស្ស។ ហើយនៅចំពោះមុខសវនាការនេះ លោកមិនមានសេចក្ដីក្លាហានចំពោះភាពយុត្តិធម៌សម្រាប់ប្រទេសរបស់លោកនិងពលរដ្ឋរបស់លោកនោះទេ។

មេធាវីរបស់លោកបានលើកឡើងទៅការសារភាពរបស់លោក ហើយនិងការសារភាពរបស់លោកការសម្ដែងឡើងវិញនៅកន្លែងឧក្រិដ្ឋកម្មនោះ ប៉ុន្តែលោកមិនបានបញ្ជាក់ទៅលើការសារភាពទាំងអស់នេះ។ លោកមិនបានសុំឲ្យមានការអត់ឱនទោសឲ្យច្បាស់លាស់។

[១៥:៥៥:០៩]

ដូច្នេះហើយនេះជាចំណុចដែលជនរងគ្រោះចង់បាន ហើយលោកមិនបានផ្ដល់ជូននូវជនរងគ្រោះនិងដើមបណ្ដឹងរដ្ឋប្បវេណីដែលនៅចំពោះមុខលោកនេះទេ។ ហើយខ្ញុំគិតថាលោកមិនមានឱកាស ហើយមិនបានឆ្លៀតយកឱកាសនេះធ្វើការសម្ដែងដូច្នោះចំពោះអ្នកទាំងអស់នេះនិងប្រទេសរបស់លោក។ យើងមិនអាចទទួលស្គាល់នូវការបញ្ជាក់ និងអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម និងស-២១ ដែលលោកបាន ដូចដែលលោកបានលើកឡើងនោះទេ។

លោកបានលើកឡើងថា កៅសិបប្រាំភាគរយនៃជនរងគ្រោះ ដូចដែលយើងបានបញ្ជាក់ គឺមិន

មានគ្រោះថ្នាក់អ្វីដល់របបនោះទេ។ ហើយលោកមិនយល់ទៅលើពួកគេ ហើយចំណុចទាំងអស់នេះគឺវាមានមូលដ្ឋាន ហើយវាមិនពាក់ព័ន្ធនឹងការអះអាងរបស់លោក។ យើងដឹងថាមានមនុស្ស១២.៣៨០នាក់ដែលបានស្លាប់នៅក្នុងមន្ទីរស-២១។ ហើយយើងអាចហៅលោកថា ជាឃាតកចំពោះអំពើទាំងអស់នេះ។ នៅពេលដែលនេះលោកនៅក្នុងសាលសវនាការ លោកនៅទីនេះតែម្នាក់ឯង លោកមានវ័យចាស់ ហើយលោកមិនដែលសម្តែងនូវការអត់ឱន ឬក៏ការអាណិតអាសូរទៅលើជនរងគ្រោះនោះទេ។ ប៉ុន្តែ នៅពេលនេះលោកចង់បាន ហើយនៅពេលនេះ លោកចង់បានពីជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីនូវការអាណិតអាសូរទៅដល់លោក។ ហើយគឺជាការផ្តន្ទាទោសនោះទេ ដែលវាបញ្ជាក់យ៉ាងច្បាប់អំពីទំនួលខុសត្រូវរបស់លោកចំពោះឧក្រិដ្ឋកម្មរបស់លោក។

ដូច្នេះ ពេលនេះខ្ញុំសូមផ្តល់វេទិកានេះបន្តទៅកាន់សហសេវិករបស់ខ្ញុំ មេធាវី ហ្វីលីព កាណុន។

**លោក ហ្វីលីព កាណុន៖**

លោក លោកស្រីចៅក្រមជាទីគោរព, ខ្ញុំនៅសល់តែដប់នាទីតែប៉ុណ្ណោះ ដូច្នេះហើយខ្ញុំនឹងនិយាយដោយខ្លីៗ។ ខ្ញុំបានចាប់អារម្មណ៍ ហើយបានស្តាប់ឮទៅលើសេចក្តីថ្លែងសន្និដ្ឋានរបស់លោកមេធាវី រូ ហើយយើងយល់ទៅលើចំណុចទាំងអស់នេះ។ លោកព្យាយាមដាក់នីតិវិធីនេះទៅក្នុងលក្ខណៈជាក់លាក់ និងពិសេសមួយដោយឡែក។ យើងបានយល់ទៅលើចំណុចទាំងអស់នេះ។ យើងយល់អំពីភាពមនុស្សធម៌ដែលទាញចេញពីសេចក្តីសន្និដ្ឋានរបស់គាត់។ ដែលគាត់បានលើកឡើង ប៉ុន្តែខ្ញុំបញ្ជាក់នៅថ្ងៃនេះថាលោកកំពុងតែបំពេញការងារនេះក្នុងនាមជាមេធាវី ហើយលោកយល់ច្បាប់ទៅលើចំណុចទាំងអស់នេះ។ យើងជាមេធាវីទាំងអស់គ្នា ហើយយើងក៏មិនមានអ្នកណាដកការងាររបស់យើងទៅលើចំណុចនេះ ហើយយើងបំពេញការងារទៅតាមឆន្ទៈរបស់យើង។

[១៥:៥៧:៤៨]

លោក លោកស្រីចៅក្រម ជាទីគោរព យើងខ្ញុំសូមបញ្ជាក់ទៅកាន់មេធាវីការពារក្តី។ ថាតើយើងមានការពេញចិត្តប៉ុនណា? តើយើងមានការថ្លែងអំណរគុណប៉ុនណា? ប្រសិនបើមានការបញ្ជាក់ឲ្យបានច្បាប់ទៅលើការទទួលយកទោសនោះ ដើម្បីឲ្យយើងរកការពិត ហើយវាជាការបញ្ជាក់មួយយ៉ាងច្បាប់ឲ្យមានការសម្រេចផ្តន្ទាទោសយើងយុត្តិធម៌។

ដូច្នេះ ជំហរ បើសិនជាមានការបញ្ជាក់ឲ្យបានច្បាស់លាស់ វាជាស្ថានមួយដែលយើងទាំងអស់គ្នាកំពុងតែកសាងនូវគ្រោះនៃស្ថាននេះ តាមរយៈការដាក់សេចក្តីសន្និដ្ឋានរបស់យើងទាំងអស់គ្នា រួមទាំង

ខ្ញុំផងដែរ ក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណី។

លោក កាំង ហ្កេកអ៊ាវ មានតែពេលនេះទេ ដែលយើងអាចបញ្ជាក់អំពីឋានៈរបស់មនុស្សជាតិទាំងអស់គ្នា ដើម្បីឲ្យជនរងគ្រោះអាចបញ្ជូនទៅលើភាពស្អប់ទាំងអស់នេះ ដើម្បីឈានចាប់ទៅយកអនាគតកាល។ សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីបានធ្វើឲ្យយើងទាំងអស់គ្នាយល់អំពីទំហំនៃវិសាលភាពនៃការទម្លាក់កំហុសដល់ជនជាប់ចោទនូវរបបនោះ និងការពាក់ព័ន្ធរបស់ជនជាប់ចោទនៅរបបនោះ។ យើងបានស្ដាប់ឮទាំងអស់គ្នាអំពីការលើកឡើងរបស់លោកមេធាវី រូ ទាក់ទងទៅនឹងពិរុទ្ធភាពរបស់ជនរូបនេះ និងការទទួលខុសត្រូវរបស់ជនរូបនេះ ហើយមិនមានចំណុចណាមួយដែលបានបញ្ជាក់ឲ្យបានច្បាស់លាស់។ ហើយខ្ញុំសូមបញ្ជាក់ពាក្យរបស់មេធាវីការពារក្ដី "យើងសង្ឃឹមពាក្យស្មោះត្រង់ពី ឌុច មិនមែនការសុំទោសដោយជាលក្ខណៈធ្វើឲ្យយើងមានអារម្មណ៍ស្រួល សុខស្រួលនោះទេ គឺជាការសោកស្ដាយក៏ពិតប្រាកដ។ យើងត្រូវការចំណុចពិស្ដារទៅលើចំណុចទាំងអស់នេះ"។

ដូច្នេះ អ្វីដែលយើងបានឮ គឺគ្រាន់តែជាការចាក់គរនូវហេតុការណ៍ដែលបានកើតឡើង។ យើងបានឮតែឈ្មោះរឿងក្ដី លេខរឿងក្ដី លេខឯកសារ។ មេធាវីបានរៀបរាប់អំពីកំហុស ខុស ត្រូវ និងមូលដ្ឋានផ្លូវច្បាប់ចំពោះឧក្រិដ្ឋកម្មដែលដាក់បន្ទុកទៅលើជនជាប់ចោទតែប៉ុណ្ណោះ។ ប៉ុន្ដែ នៅចំពោះមុខសវនាការនេះ នៅពេលដែលយើងបញ្ចប់នាពេលនេះ នៅពេលដែលយើងពិចារណាទៅលើជីវិតរបស់នៅប្រចាំថ្ងៃឡើងវិញ។ ហើយប្រសិនបើទោស៤0ឆ្នាំ អាចកំណត់នោះ គឺគាត់ត្រូវតែបើកចិត្តរបស់គាត់ដោយសារតែវាមានចំណុចជាច្រើនមានកើតឡើងលើសលប់ទៅលើចំណុចទាំងអស់នេះ។ ចំណុចនេះយើងអាចយល់ថា ប្រហែលបុរសរូបនេះគាត់អាចយល់ទៅលើចំណុចទាំងអស់នេះ ហើយគាត់អាចយល់នៅក្នុងចិត្តគំនិតរបស់គាត់នូវអ្វីដែលបានកើតឡើង។ ហើយគាត់បានសរសេរកំណត់បញ្ជាក់យ៉ាងច្បាប់ ឬក៏គាត់យល់ច្រឡំនៅក្នុងកំណត់ជើងទំព័ររបស់គាត់ នៃឯកសារសេចក្ដីបញ្ជាក់របស់គាត់ ដែលនៅក្នុងនោះមានការលើកឡើងអំពីការបញ្ជាក់នូវហេតុផលមួយចំនួន ដែលបើសិនយើងពិចារណាទៅគឺហាក់ដូចជាគ្មានសោះសម្រាប់យើងទាំងអស់គ្នា។ ហើយមេធាវីការពារក្ដីសុំឲ្យកាត់សេចក្ដីលើជននេះឲ្យរួចផុតពីបទចោទ។

[១៦:០២:០៣]

ចំណុចទាំងអស់នេះ គឺជាការមិនទទួលខុសត្រូវទៅលើអំពើរបស់ជនជាប់ចោទឡើយ។ គាត់ប៉ានសុំឲ្យធ្វើដូច្នេះ ប៉ុន្ដែគាត់មិនប៉ានទទួលនូវអ្វីដែលគាត់បានធ្វើ។ ហើយខ្ញុំជឿថា លោក លោកស្រី

ចៅក្រមអាចធ្វើការយល់ទៅលើចំណុចទាំងអស់នេះ។ យុទ្ធសាស្ត្រអន្តរជាតិបាននិយាយអំពីប្រព័ន្ធច្បាប់នានា។ សូមលោកប្រធានអនុញ្ញាតឲ្យខ្ញុំធ្វើការរៀបរាប់ទៅលើយុទ្ធសាស្ត្រ និងទ្រឹស្តីនៅក្នុងច្បាប់ព្រហ្មទណ្ឌ។ ជាពិសេសនៅក្នុងច្បាប់ទ្រឹស្តី ច្បាប់ទាក់ទងទៅនឹងទ្រឹស្តីចំនួនបី ទាក់ទងទៅនឹងការគោរពបទបញ្ជាថ្នាក់លើដែលលោកមេធាវី ហ្វ្រង់ស្វ័រ រូ គាត់យល់ច្បាស់។ គឺផលវិបាកនៃការទទួលបញ្ជាធ្វើតាមបញ្ជា ប៉ុន្តែវាមានលក្ខណៈពិបាកក្នុងបញ្ជាក់ទៅលើការអះអាងដូច្នោះណាស់។ ទ្រឹស្តីនេះគឺត្រូវបញ្ជាក់ថាការដែលមានបញ្ជាដោយបង្ខំនោះ គឺធ្វើឲ្យបុគ្គលម្នាក់គាត់ទទួលយក។ ហើយបុគ្គលម្នាក់គាត់មិនត្រូវទទួលទៅតាម ធ្វើទៅតាមបញ្ជាទេ ប្រសិនបើបញ្ជានោះមានភាពសាហាវនិងខុសច្បាប់។ ហើយទ្រឹស្តីបញ្ជាក់ថា បើសិនដូច្នោះ បុគ្គលម្នាក់ដែលគាត់មានហេតុផលត្រឹមត្រូវ គាត់ត្រូវបដិសេធទៅលើបញ្ជាទាំងអស់នោះដែលបានដាក់មកលើគាត់។ បុគ្គលរាល់គ្នា គាត់មានសិទ្ធិក្នុងការបដិសេធទៅលើបញ្ជាទាំងអស់នេះ ហើយជនជាប់ចោទគាត់មានលទ្ធភាពនិងឱកាសក្នុងការបដិសេធទៅលើបញ្ជាទាំងអស់នោះ។

ចំណុចចុងក្រោយ ខ្ញុំសូមបញ្ចប់ យើងមិនត្រូវភ្លេចទេថា សវនាការមួយនេះ គឺវាបានជំនុំជម្រះហើយមេធាវីការពារក្តីបានលើកឡើងហើយ តុលាការគឺជាគំរូ ដែលគំរូកំពុងតែសង្កេតមើលពីសហគមន៍អន្តរជាតិទាំងមូល។ យុទ្ធសាស្ត្រមួយទៀត គឺវាក៏មានបញ្ជាក់ទៅលើចំណុចនេះផងដែរ ហើយយើងត្រូវសិក្សា និងយល់អំពីរឿងក្តី អុប្រេ៍ណូវិច ប៉ុន្តែវាមានចំណុចខុសគ្នានៅក្នុងករណីនោះ និងករណីនេះ។ វាមានភាពខុសគ្នា ដែលយើងត្រូវបែងចែក និងការកំណត់ឲ្យឃើញទៅលើរឿងក្តីទាំងពីរ។ មិនមានដើមបណ្តឹងរដ្ឋប្បវេណីចូលរួមនៅក្នុងរឿងក្តី អុប្រេ៍ណូវិច នោះទេ ហើយ អុប្រេ៍ណូវិច បានដឹកនាំអ្នកស៊ើបអង្កេតទៅដល់ផ្នូរ ហើយគាត់មិនមានការរត់គេចខ្លួននោះទេ។ គ្រួសារជនរងគ្រោះ ត្រូវបានគេប៉ះប៉ូវទៅលើសំណង ហើយសំណងត្រូវបានបង្កើតឡើងផងដែរ។ ថាតើនៅតុលាការនេះ ខ្ញុំធ្លាប់បានឮដែរឬទេអំពីការវិភាគ ឬក៏ការពិភាក្សាទៅលើសំណង សូម្បីតែមួយម៉ាត់នោះ។ ហើយប្រសិនបើខ្ញុំឮពីជនជាប់ចោទនោះ គឺខ្ញុំសង្ឃឹមថា ខ្ញុំមិនឮសោះពាក្យទាំងអស់នេះ។

[១៦:០៥:៤១]

ហើយយើងឃើញថា ការលើកឡើងជាច្រើនទាក់ទងនឹងលោកស្រី ម៉ាទីន លើហ្វ៊ីវ ផងដែរ។ ហើយយើងដឹងហើយ ឌុច គឺជាបុគ្គលដែលធ្វើការនៅមន្ទីរស-២១ គាត់បម្រើទៅលើសង្គមនោះ។ ហើយដឹងថានៅពេលដែលកិត្តិយសដែលយើងកំពុងស្វែងរកសម្រាប់ជនរងគ្រោះនោះ គឺវាសម្រាប់ជនរង-- ជនដែលសល់ពីជីវិតពីរបបនោះចំនួនបីរូប មិនមែនសម្រាប់ជនរូបនេះដែលជា ឌុច នោះទេ។

ដូច្នេះនៅពេលដែលយើងជំនុំជម្រះ គឺយើងបង្កើតប្រវត្តិសាស្ត្រ មិនមែនសរសេរប្រវត្តិសាស្ត្រឡើងវិញនោះទេ។

លោក លោកស្រីចៅក្រមជាទីគោរព, ថាតើដើមបណ្តឹងរដ្ឋប្បវេណីអាចស្តាប់ពាក្យទាំងអស់នេះដោយមិនមានប្រតិកម្មបានដែរឬទេ? មួយម៉ឺនពីរពាន់បីរយប៉ែតសិបបីនាក់ស្លាប់នៅមន្ទីរស-២១ ហើយវាតំណាងតែមួយភាគរយនៃអ្នកស្លាប់តែប៉ុណ្ណោះ។ ដោយសារតែមេធាវីការពារក្តីបានលើកឡើងអំពីអ្នកដែលរស់រានមានជីវិតពីមន្ទីរស-២១ តើលោកចង់រំឭកឡើងវិញអំពីអ្នកដែលបានស្លាប់នៅមន្ទីរនេះនោះឬក៏យ៉ាងម៉េច?

មេធាវីការពារក្តីបានលើកឡើងអំពីតួលេខស្ថិតិទាំងអស់នេះ ដែលវាបន្ទុកធ្ងន់ទៅលើព្រលឹងរបស់ជនរងគ្រោះ ហើយខ្ញុំគិតថាខ្ញុំបញ្ចប់សេចក្តីសន្និដ្ឋានរបស់ខ្ញុំហើយ។ សូមអរគុណច្រើនលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួន។

**លោក ហុង គីមសួន៖**

ខ្ញុំបាទសូមអរគុណលោកប្រធាន ដោយពេលវេលាកាន់តែខ្លីពេកហើយ ខ្ញុំសូមបាទអនុញ្ញាត និងសុំការអធ្យាស្រ័យពីលោកប្រធាន ព្រោះក្នុងនាមខ្ញុំបាទជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ ស្តាប់ទៅគឺឈឺចាប់ណាស់ វាចុកលើសពីការពិតទៅទៀត។ មេធាវីបរទេសនិងលោកចៅក្រម លោកព្រះរាជអាជ្ញាបរទេស មិនធ្លាប់រស់នៅក្នុងរបបខ្មែរក្រហម មិនឈឺដូចយើងខ្ញុំទេ។ ស្តាប់នូវការលើកឡើងរបស់លោកមេធាវីប្រាំងស្វ័រ រូ និងលោកមេធាវី ការ សាវុត្ថ វាផ្ទុយគ្នានឹងសម្តីជនជាប់ចោទ ដែលសុំទទួលស្គាល់អំពើឧក្រិដ្ឋនៅក្នុងកណ្តាប់ដៃនៃយន្តការស-២១ តែគាត់លើកឡើងពីភាពគ្មានទោស នេះជាសិទ្ធិនេះជាការការពារស្របច្បាប់របស់គាត់ គាត់មានសិទ្ធិនិយាយអ្វីក៏បានឲ្យតែនៅក្នុងច្បាប់។ ប៉ុន្តែ ខ្ញុំសូមអនុញ្ញាតនិយាយក្នុងន័យក្នុងផ្លូវច្បាប់ដូចគ្នា បើមានការលើសលួស ខ្ញុំបាទសូមអនុគ្រោះ ព្រោះភាពឈឺចាប់របស់--។

[១៦:១០:៣០]

លោកប្រធានជាទីគោរព, តើគួរជឿទេ ថា ឌុច មិនមែនជាអ្នកទទួលខុសត្រូវមួយដែលស្ថិតនៅក្នុងលំដាប់ខ្ពស់? ជនរងគ្រោះទាំងអស់-- ខ្ញុំបាទក៏ជាជនរងគ្រោះមួយដែរ ខ្ញុំទុកចិត្តអត់បានទេ។ ខ្ញុំបាទដឹងថា ពេលវេលាខ្ញុំមានតិច ប៉ុន្តែខ្ញុំសូមអនុញ្ញាតម្តងហើយម្តងទៀត ថាខ្ញុំបាទទុកចិត្តមិនបាន ខ្ញុំបាទ

សុំពេលវេលាបន្តិចបន្ថែម។ ហើយខ្ញុំបាទសូមឲ្យលោកប្រធាន និងអង្គជំនុំជម្រះមេត្តាទទួលយកនូវអ្វីដែលបានលើកឡើងនេះ គឺខ្ញុំបាទនៅតែយល់ឃើញថា ជឿថា គឺឌុច ឬជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច គឺជាអ្នកទទួលខុសត្រូវខ្ពស់នៅក្នុងមន្ទីរស-២១ ដែលបណ្តាលឲ្យមនុស្សជាង១២.៣៨០នាក់ ឬក៏លើសពីនោះ បានស្លាប់យ៉ាងវេទនា យ៉ាងឈឺចាប់គ្មាន ថ្ងៃគ្មានពេលវេលាបំភ្លេចបានទេ។

ឌុច គឺជាមនុស្សដ៏ល្អ គឺមនុស្សដែលទទួលខុសត្រូវដែលបក្ស ឬក៏អង្គការ ជាពិសេស គឺ សុន សេន ដែលជាមេទាហាន ឬមេទ័ពនៅក្នុងប្រទេសកម្ពុជានៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយក៏ជាមេនគរបាលមួយដែលមានអំណាចផ្តាច់ផ្តិលជីវិតរបស់ប្រជាពលរដ្ឋនៅពេលដែរ។ ដូច្នេះ អ្វីដែលខ្ញុំបាទចង់លើកឡើងគឺប្រៀបធៀបទៅម-១៣ មក ស-២១ មិនខុសគ្នាទេ។ ឌុច បានថ្លែងកាលពីម្សិលមិញហើយថា របបឬការសម្លាប់នៃការកាប់សម្លាប់រង្គាលមានតាំងពីជំនាន់រំដោះ មុនថ្ងៃ១៧ មេសា ១៩៧៥ ដូច្នេះ អ្វីដែលឌុច ដឹង អ្វីដែល ឌុច មានបទពិសោធ គឺឌុច ត្រូវបានអង្គការ ឬបក្សជឿ បក្សទុកចិត្តទទួលឲ្យ ឌុច ទៅធ្វើជាប្រធាននៅមន្ទីរស-២១ ទៀត។ ព្រោះងាយស្រួលរបៀបស្វែងរកការទោស ការយកចម្លើយដែលមិនពិត ដើម្បីយកមនុស្សទៅកម្ទេចចោលជាងសត្វតិរច្ឆានទៅទៀត។ ដូច្នេះ នៅម-១៣ កន្លែងឃុំឃាំងមនុស្សកន្លែងសួរចម្លើយមនុស្សគឺនៅនឹងអមលាំង។ កន្លែងកប់សាកសព ឬក៏សម្លាប់នៅត្រើយម្ខាងនៃស្ទឹងដែល ឌុច បាននិយាយ ហើយកន្លែងដែល ឌុច និយាយថា ជាកន្លែងធ្វើស្រែចម្ការ គឺជាកន្លែងលត់ដំនៅកន្លែងម-១៣(ខ)។ ដូច្នេះ នៅស-២១ គឺជាមន្ទីរឃុំឃាំង និងធ្វើទារុណកម្ម ហើយកន្លែងដែលកាប់សម្លាប់នៅបឹងជើងឯក។ ឯកន្លែងដែល ឌុច និយាយថាជាកន្លែងលត់ដំ ឬក៏កន្លែងសភាពនៅព្រៃស គឺវាមានសភាពដូចគ្នា។

អ៊ីចឹង មុន១៧ មេសា ១៩៧៥ អ្វីដែល ឌុច ធ្វើ ឌុចដឹងទាំងអស់ ឌុច ចេះតែទាំងអស់ របៀបសួរចម្លើយ របៀបចាប់ចង របៀបធ្វើទារុណកម្ម គឺដូចគ្នាបេះបិត។ ហើយ ឌុចបាននិយាយថា ឌុច មិនអាចគេចទៅណារួចទេនៅក្នុងរបបនោះ ឌុច ដូចជានៅក្នុងចង្កោមខ្លា ឬក្នុងនៅក្នុងស្ពឺមួយនៃគ្រាប់ម៉ាស៊ីនកំពុងដើរ គឺគ្រាន់តែជាដោះសាតែប៉ុណ្ណោះ។ ដូច្នេះ ត្រង់នេះហើយ ដែរថា ឌុច គឺជាអ្នកទទួលខុសត្រូវ ឌុចមិនមែនជាអ្នកសម្រេចចិត្តចាប់មនុស្ស ឌុច មិនមែនជាអ្នកកម្ទេចមនុស្ស។ ប៉ុន្តែ ឌុច ជាអ្នកចារលើចំណារ ពីព្រោះមេមិនមែនមកពិនិត្យមើល ឌុច សព្វថ្ងៃនៅទួលស្លែង ឬមន្ទីរស-២១ ទេ។ ឌុច ចារឲ្យអ្នកណារស់បានយូរ គឺឌុច ចារបាន។ ឌុច ចង់ឲ្យអ្នកណាស្លាប់ គឺឌុច ចារដាក់ថា ដក ឬកម្ទេច ហើយមេក៏ធ្វើតាម។

ដូច្នេះ នៅក្នុងនេះ ខ្ញុំបាទមានឯកសារ តែឌុច បានបដិសេធហើយ នៅក្នុងលេខD29/9 ឬក៏ ERN000162649 ដែលសរសេរចារនៅក្នុង បានសម្រេចនៅថ្ងៃ១៧ ខែ២ ៧៧ ឲ្យ។ ១) កម្ទេច១១៥ នាក់។ ២) ទុក២៣ បូកនិង២១ ស្មើនឹង៤៤នាក់។ សមមិត្ត ឌុច ស្នើអង្គការហើយ អង្គការយល់ព្រម។ អ្វីដែល ឌុច សរសេរហើយ ឌុច គ្រាន់តែជាលេសនៃការសរសេរ។ អ៊ីចឹងហើយចុះនៅពេលគេចោទប្រកាន់ប្អូនថ្លៃ ឌុច និងប្អូនបង្កើត ឌុច។ ឌុច អត់ធ្វើតាមទេ ម៉េចក៏គេមិនយក ឌុច ទៅសម្លាប់ទៅ។ ហើយអ្នកដែលបានរស់ ទាំងនៅព្រៃស ទាំងក្នុងទួលស្លែងស្រាប់ដែលនៅរស់ មុននឹង ឌុច បាក់ទ័ព ឬក៏ក្រុមរបស់ខ្មែរក្រហមបាក់ទ័ពទៅ មិនមែនគេមានចេតនាចិត្តឈប់សម្លាប់មនុស្ស ឬបញ្ឈប់ការសម្លាប់ទេ គឺពួកគេបាក់ទ័ព គឺពួកគេរត់ចោលស្រុក ហើយគេបន្តយកអ្នកទោសដែលគិតថា គេនឹងសម្លាប់យកទៅជាមួយទៀត ដោយភ្លង់ទៀត មានអ្នកស្រី ជុំនៅ មាន ជុំ ម៉ី មាន ប៊ូ ម៉េង ដែលត្រូវបានគេភ្លង់ហើយ ប្រពន្ធរបស់លោក ជុំ ម៉ី ទៅទៀតដែលគេសម្លាប់នៅអមលាំងទៅទៀត។ នេះហើយឬ ដែលហៅថាចេតនារបស់គេចង់ចៀសឲ្យផុតអំពីអំពើប្រល័យពូជសាសន៍មនុស្ស។

[១៦:១៤:៣៧]

ដូច្នេះ ខ្ញុំបាទសូមឲ្យលោកចៅក្រមមេត្តាពិចារណាឡើងវិញថា ភាពឈឺនេះមានតែខ្មែរទេ ឬក៏ជនជាតិដែលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ដែលឈឺដែលចុកចាប់ខ្លួនឯង។ ដូច្នេះ ខ្ញុំបាទមិនមែនជាអ្នកសុំឲ្យផ្តន្ទាទោសទេ ប៉ុន្តែសូមឲ្យលោកព្រះរាជអាជ្ញា និងសហព្រះរាជអាជ្ញា សូមមេត្តារំឭក ឬក៏ពិចារណាឡើងវិញថា ការស្នើសុំរបស់លោកត្រឹម៤០ឆ្នាំនោះ គឺស្មើរតែជាការសុំឲ្យជនរងគ្រោះដែលនៅរស់វាស្លាប់ទៅទៀត។ អ៊ីចឹង សុំឲ្យពិចារណាឡើងវិញ យើងខ្ញុំគិតថាអ្វីដែល ឌុច ថ្លែងសុំទោសជាសាធារណៈនោះសុំឲ្យលោកចៅក្រម ឬលោកប្រធាន មេត្តាយក ទទួលយកនៅពេលចេញសាលក្រម ឲ្យយកចម្លើយសារភាពរឿងសុំទោសរបស់ ឌុច ដោយសុំឲ្យចាក់ផ្សាយតាមវិទ្យុជាតិក្នុងរដ្ឋាភិបាល ឬក៏សុំឲ្យធ្វើរូបសំណាក ឌុច ជាជាងដាក់រូបថត ដែលវាងាយខូចខាតទៅវិញ។ សូមអគុណ។

**ប្រធានអង្គជំនុំ៖**

មានទៀតទេ? អាចនិយាយបាន ប៉ុន្តែអំមិញហ្នឹងគឺលឿនពេក។ មានអីទៀតទេ? មិញហ្នឹងចង់ឲ្យយឺតទេនែ៎ ឲ្យប្រាំមីនុតទៀត បើសិនជាមានអ្វីចង់និយាយ។ សូមនិយាយឲ្យយឺតដើម្បីឲ្យអ្នកបកប្រែភាសាហ្នឹង ពីព្រោះបកប្រែស្តាប់-- គ្នាបកប្រែមិនទាន់នែ៎។

**លោក ហុង គីមសួន៖**

សូមអគុណលោកប្រធាន។ ខ្ញុំបាទមានតែបន្តិចទៀតទេ។ ដោយសារតែនេះគឺជាតុលាការខ្នាត អន្តរជាតិ និងខ្នាតជាតិ យើងមិនរំលោភសិទ្ធិមនុស្ស យើងមិនអមនុស្សធម៌ យើងមិនអយុត្តិធម៌ ដូចអ្វី ដែលភាគីជនជាប់ចោទ ឌុច លើកឡើងនោះទេ។ បើសិនជាយើងជាមនុស្សអយុត្តិធម៌ ម្ល៉េះសមមានអំពើ ហិង្សាកើតឡើងហើយ។ ដូច្នេះ ពួកយើងខ្ញុំជាមេធាវីឲ្យដើមបណ្តឹងរដ្ឋប្បវេណី សុំឲ្យលោកប្រធានពី ពេលនេះទៅមុខទៀត ទោះដប់ឆ្នាំ ម្ភៃឆ្នាំ ឬហាសិប មួយរយ ឬប្រាំរយឆ្នាំទៅទៀតក៏ដោយ ដើម្បីកុំ ឲ្យប្រជារាស្ត្រ ឬប្រជាពលរដ្ឋ ទោះបងប្អូនកូនចៅយុវជនកុមារភ្លេចភ្លាំង គឺសូមរំឭកហើយ រំឭក ទៀតថា ឆ្លាក់រូប ឌុច នៅក្នុងមន្ទីរទួលស្លែងឈរស្លៀកពាក់ខោអាវខ្មៅពាក់ស្បែកជើងកងឡាន បងក ក្រមា និងពាក់មួកកន្តឹបខ្មែរក្រហម ជាទីរំឭក ជាពេលវេលាដែលនេះហើយជាអំពើអមនុស្សធម៌នោះ។ សូមអគុណ។

[១៦:១៧:០៨]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ កិច្ចនីតិវិធីនៃការធ្វើសេចក្តីសន្និដ្ឋានតបរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំង បួនក្រុម ដែលតាមផែនការគឺផ្តល់ពេលវេលាឲ្យមួយម៉ោង។ ឥឡូវនេះ គឺពួកគាត់បានចំណាយពេល វេលាសមស្រប គឺបួនម៉ោង គឺតាមអ្វីដែលអង្គជំនុំជម្រះបានបែងចែកឲ្យ ហើយឃើញថាដល់ទីបញ្ចប់ ហើយ ហើយឥឡូវនេះ ដល់ពេលឈប់សម្រាកនៅពេលល្ងាចហើយ អង្គជំនុំជម្រះប្រកាសផ្អាកដំណើរ ការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការនឹងលើកទៅបន្តទៅធ្វើនៅថ្ងៃស្អែក ថ្ងៃទី២៧ ខែ វិច្ឆិកា ឆ្នាំ២០០៩ ចាប់ពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបផងដែរថា ភាគី និង សាធារណជនថា នៅព្រឹកថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងផ្តល់វេទិកាឲ្យទៅសហព្រះរាជអាជ្ញាឲ្យឡើងធ្វើ សេចក្តីសន្និដ្ឋានតប។ រួចបន្ទាប់មក អង្គជំនុំជម្រះនឹងផ្តល់វេទិកាទៅដល់ជនជាប់ចោទ និងសហមេធាវី ការពារក្តី ឡើងធ្វើសេចក្តីសន្និដ្ឋានតបចុងក្រោយបង្អស់។

ហេតុដូច្នេះ សូមភាគីនិងសាធារណជនជ្រាប និងអញ្ជើញចូលរួមនៅក្នុងសវនាការឲ្យបានមុន ពេលកំណត់។ អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យគាត់នាំមក កាន់សាលសវនាការនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនជាកំហិត៕

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការផ្អាកនៅម៉ោង១៦:១៨នាទីរសៀល]*